CAMBODIA EXPRESS NEWS

# រឿង

# នៅក្នុងលោកនេះបើគ្មានបង

ប្រលោមលោកជីវិតស្នេហាសោកសៅ

**និពន្ធដោយ ហាក់ ឆៃហុក**

សមាជិកសមាគមអ្នកនិពន្ធខ្មែរ

រក្សាសិទ្ធិ

**ព.ស.២៥០៨ គ.ស.១៩៦៥**

## អារម្ភកថា

ស្លាកស្នាមប្រវត្តិសាស្ត្រជាច្រើនបានបង្ហាញឱ្យឃើញថាជនជាតិខ្មែរជា ជនជាតិមួយមានខឿនអរិយធម៌-វប្បធម៌ដ៏រុងរឿង។ ទោះបីជាមានការរុកទន្ទ្រានពីសត្រូវជិតខាងឬមានចំបាំងរាំងជល់ផ្ទៃក្នុងក៏ដោយក៏វិស័យសិល្បអក្សរសិល្ប៍របស់ខ្លួននៅ តែបន្តការវិវត្តន៏ឥតឈប់ឈរ។ ប៉ុន្តែគួរឱ្យអនិច្ចាឆ្នាំ ១៩៧០ រដ្ឋប្រហារមួយបានទម្លាក់ព្រះមហាក្សត្រព្រះបាទសម្តេចព្រះ **នរោត្តមសីហនុ** ដែលព្រះអង្គតែងយកព្រះទ័យទុកដាក់លើវិស័យអក្សរសាស្ត្រជាតិ រហូតប្រជាពលរដ្ឋបានថ្វាយព្រះនាមព្រះអង្គជាព្រះបិតាអក្សរសាស្ត្រជាតិ។ សង្គ្រាម,របបប្រល័យពូជសាសន៏បានបំផ្លិចបំផ្លាញជាតិគ្រប់វិស័យស្ទើរដល់កម្រិតសូន្យក្នុងនោះមានស្នាដៃអក្សរសិល្ប៏ផងដែរ។ ក្រោយពីមានការបង្រួបបង្រួមជាតិក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះមហាក្សត្រ ជនជាតិខ្មែរបានរួបរួមសាមគ្គីគ្នាជាធ្លុងមួយស្តារនិងកសាងជាតិឡើងវិញ។ ដោយយល់ឃើញពីសារៈសំខាន់នៃវិស័យអក្សរសិល្ប៏ក្នុងការលើកស្ទួយវប្បធម៌របស់ខ្លួនបណ្ណាគារ **"អង្គរធំ"**យើងខ្ញុំក៏បានសម្រេចលើកយកស្នាដៃប្រលោមលោកចាស់ៗរបស់អ្នកនិពន្ធដែលធ្លាប់មានឈ្មោះល្បីមកធ្វើការបោះពុម្ពឡើងវិញ ក្នុងគោលបំណងថែរក្សានូវសម្បត្តិរួមរបស់ជាតិដើម្បីឱ្យកូនខ្មែរជំនាន់ក្រោយៗបានចេះដឹងគ្រាន់ជាគុណប្រយោជន៏រួមដល់សង្គមជាតិ ។

ភ្នំពេញ, ថ្ងៃទី ០៧ ខែតុលា ឆ្នាំ២០០២

## អារម្ភកថា

សួស្តី ! អស់លោកអ្នកនាងកញ្ញា !

អ្នកនិពន្ធខ្ញុំ បានមកជួបអស់លោកអ្នកនាងកញ្ញាម្តងទៀត ក្នុងរឿងនៅក្នុងលោកនេះបើគ្មានបង ដែលជាវណ្ណកម្មពិសេសរបស់អ្នកនិពន្ធខ្ញុំ ។

នៅក្នុងលោកនេះបើគ្មានបង ឬនៅក្នុងលោកនេះបើគ្មានសេចក្តី ស្នេហា ពិភពលោកទាំងមូលនឹងប្រែក្លាយទៅជាស្ថានគ្មានន័យសំរាប់ជីវិតមនុស្ស។ ដូច្នេះហើយ បានជានារីកំសត់ក្នុងរឿងទន្ទេញជាប់មាត់ថា នៅក្នុងលោកនេះបើគ្មានរូបបងជាអ្នកចងក្រងវាសនាឱ្យខ្ញុំខ្ញុំត្រូវរស់នៅយ៉ាងសែនខ្លោចផ្សាជាទីបំផុត ។

ដើម្បីឱ្យដឹងច្បាស់ ថានរណាដែលនារីកំសត់ យើងស្រមើលស្រម័យទុកជាកំពូលដួងចិត្ត ? បុរសនោះជាបុរសស្ថិតនៅក្នុងសភាពណា ? វណ្ណៈណា ? អ្នកនិពន្ធខ្ញុំសូមអញ្ជើញអស់លោក អ្នកនាងកញ្ញា បើកទំព័រវគ្គដើមអានរឿង នៅក្នុងលោកនេះបើគ្មានបងនឹងមានដោះស្រាយរែកញែកអំពីវិថីជីវិត ជោគវាសនា ជតាកម្មជូន អស់លោក អ្នកនាងកញ្ញាយ៉ាងក្បោះក្បាយ ។

ភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៦៥

អ្នកនិពន្ធ

ហាក់ ឆៃហុក

~១~

# ស្រមោលជីវិត

ស្រមោលជីវិតរិតដួងចៃ ស្មើរតែក្បិណក្ស័យទ្រូងខ្លោចផ្សា
ឆ្នាំទៅម្ដាយស្លាប់នៅតែបា ឥឡូវមរណាឪទៅទៀត ។
ដើរចេញពីស្រុកទាំងយប់ជ្រៅរថភ្លើងបោលស្លៅផ្កាភ្លើងព្រាត
សំដៅភ្នំពេញទាំងអធ្រាត ចិត្តស្រើចង្អៀតឃ្លាតស្រុកភូមិ ។

វ៉ូម ! វ៉ូម ! ឈុកឈាក់ ! ឈុកឈាក់ ! ... រថភ្លើងបាត់ដំបង កំពុងបោលកាត់លើផ្លូវដែក កណ្ដាលសន្ធិយារាត្រីស្ងាត់ឆ្ពោះមុខមកកាន់រាជធានីភ្នំពេញ ។ ផ្កាភ្លើងរត់ប្រឡែងនឹងជំនោរខ្យល់គួចអណ្ដែតហោះហើរទៅលើវេហាស៍ ដូចគេអុចកាំជ្រួចភ្ញីទៀន តែមិនយូរប៉ុន្មានកំញ៉ូមព្រះអគ្គិនេះក៏រលត់អស់ទៅវិញក្នុងរយៈពេល ដ៏ខ្លី ។

អ្នកដំណើរគ្រប់រូប ដេកលង់លក់តាមកន្លែងរៀងៗខ្លួន បណ្ដោយឱ្យពស់ដែក ដឹកនាំអាត្មាកាត់គីរីបពិត នាយាមអាធ្រាត្រខាងរនោចងងឹតសូន្យសុងគួរឱ្យព្រឺស្មើច ។ នៅខាងក្រោយបង្អស់នៃទូរថថ្នាក់លេខពីរ នារីមួយរូបប្រកបទៅដោយរូបឆោមលោមពណ៌ តែមុខនាងក្រៀមស្រពោនបញ្ជាក់ឱ្យដឹងថា នាងកំពុងមានទុក្ខអ្វីម្យ៉ាងអង្គុយមើលទេសភាពរាត្រីតាមប្រឡោះបង្អួចមិនព្រមទំរេតខ្លួនដេកដូចជាអ្នកដំណើរឯទៀតៗឡើយ។ យូរៗនារីពនេចរលើកកូន កន្សែងមកជូតតំណក់ទឹកភ្នែក ដែលចេះតែហូរហៀរតាមថ្ពាល់ រួចពីហ្នឹងនាងក៏អង្គុយធ្មឹងធ្មៃសម្លក់សម្លឹងមើលទៅលំហអាកាសរបៀបមនុស្សបាត់វិញ្ញាណតទៅទៀត ។

រត្ន មណី ជាឈ្មោះយុវតី កំសត់ដែលយើងឃើញក្នុងខណៈនេះ។ តើមណី ជានារីប្រភេទណា ? ហើយនាង កើតទុក្ខពីពីរឿងអ្វីបានជាធ្វើដំណើរតាមអយស្ម័យយានពីបាត់ដំបងមកភ្នំពេញតែម្នាក់ឯង ឯកាពេលយប់អធ្រាត្រដូច្នេះ ? ដើម្បីបោសសំអាតឱ្យជ្រះស្រឡះពីអាការងឿងឆ្ងល់ អ្នកនិពន្ធសូមបើកទំព័រជីវិតនាងដូចតទៅ ។

រត្ន-មណី បានទទួលទេពកោសល្យខាងសម្ផស្សសោភ័ណ ភាពពីធម្មជាតិយ៉ាងស្រស់ប្រណិត តែនាងអកុសលណាស់ ដែលត្រូវកើតឡើងក្នុងត្រកូលអធនមិនសាក់សមនឹងរូបឆោម ខ្វះគ្រឿងអលង្ការខ្វះសេចក្ដីសុខសុភមង្គលក្នុងជីវិត និងខ្វះអ្វីៗជាច្រើនទៀតដែលកូនធនបតីមាន ។

ព្យុះវាសនាដាក់ទណ្ឌកម្ម មកលើរូបនាងគ្មានស្រាកស្រាន្ត ពីឆ្នាំទៅ ម្ដាយនាងស្លាប់ដោយកើតឧបទ្ទវហេតុក្រឡាប់រថយន្តលុះពីរបីថ្ងៃមុននេះ ឪពុកជាទីស្នេហាស្មើជីវិតរបស់នាងក៏ស្លាប់បាត់ទៅទៀត ទុកឱ្យនាងរស់នៅតស៊ូនឹងកំណាចព្រហ្មលិខិតលើ វាលវដ្ដសង្សារតែម្នាក់ឯងគត់។ រត្ន-មណី នាងតាំងពីកើតមកពុំដែលស្គាល់ភ្នំពេញបានម្ដងណាសោះ នាងដាច់ចិត្តប្រថុយមកភ្នំពេញ ក៏ដោយសារអាងទៅលើកូនសំបុត្រមួយតូច ដែលជាកេរ្ដិ៍មតកិសល់ពីឪពុកប្រគល់ឱ្យនៅពេលរៀបដាច់ខ្យល់ដោយនិយាយផ្ដែផ្ដាំនាងថា :

-មណី កូនស្រីមាសឪពុក ... ! ឪពុកដឹងខ្លួនឯងច្បាស់ថា ឪពុកមិនបានរស់នៅថែរក្សាកូនតទៅទៀតទេ តែមុននឹងឪពុកស្លាប់ឪពុកសូមផ្ដាំកូនបន្តិច ចូរកូនយកសំបុត្រនេះទៅជូនលោក ឧប-ស៊ីផាន់ នៅភ្នំពេញណាកូនណ៎ា .... ! លោកពីដើមធ្វើចៅហ្វាយស្រុកនៅបាត់ដំបង ម៉ាក់កូន គេធ្លាប់ធ្វើមេដោះបំបៅកូនប្រុសលោក....លោកនឹងលោកស្រីស្រឡាញ់រាប់អានឪពុកនឹងម៉ាក់ឯងណាស់ ! .... មុនលោកត្រូវរាជការផ្លាស់លោកឱ្យទៅភ្នំពេញ លោកបានបបួលឪពុកនិងម៉ាក់ឯង ឱ្យតាមទៅនៅជាមួយលោក តែពេលនោះ .... យើងទាំងពីរមិនបានទៅតាមពាក្យលោកបបួលទេ ពេលលោករៀបចំចេញដំណើរ លោកកត់អាសយដ្ឋានលោកទុកឱ្យ .... ក្នុងសំបុត្រនេះ .... អូយ !

.... ពុកហត់ណាស់...មណីកូនស្រីសម្លាញ់ឪពុក....អត់ពីឪពុកទៅកូនត្រូវចេះខាំមាត់ អត់ធ្មត់តទល់នឹងសេចក្តីក្រីក្រវេទនាគ្រប់ជំពូកណា៎ កូនណា៎ អត្តាហិ អត្តណោនាថោ ខ្លួនត្រូវទីពឹងខ្លួន ....! ។

ពោលទូន្មាន ប្រៀនប្រដៅបានត្រឹមណេះ មច្ចុរាជក៏មកកញ្ឆក់យកទង់ព្រលឹងគាត់ចេញពីរាងកាយបាត់ទៅទុកនៅសល់លើលោកដ៏ធំធេង គឺនាងរត្ន-មណី នារីអភ័ព្វវាសនា ។

ម៉ោង ៦,១៥នាទី រថភ្លើង ក៏បានមកឈប់ចតនៅស្ថានីយ៍ រាជអាយស្ម័យយានភ្នំពេញ ។ អ្នកដំណើរគ្រប់រូបប្រញាប់ប្រញាល់ ភ្ញាក់ពីដំណេកលុបមុខសិតសក់ យួរកាតាបវ៉ាលីសចុះដើរតំរង់ទៅកាន់ទ្វារចេញ ខ្លះទៀតក៏ញញឹមញញែមលើកដៃគ្រវីគ្រវាត់ កាលបើឃើញមានមិត្តភ័ក្ត ឬញាតិមិត្តមកឈរចាំទទួល។

រត្ន-មណី ឈានជើងចុះពីទូរថភ្លើង ដៃម្ខាងកំពៀកកាតាប កញ្ចាស់ដាក់សំពត់អាវ ដៃម្ខាងទៀតក្តាប់សំបុត្រ ដើរចេញពីស្ថានីយ៍រថភ្លើងមានដំណើរ យឺត១ រេរា១ ដោយគ្មានគោលដៅពិតប្រាកដឆ្ពោះទៅកន្លែងណា ។

- អត់ទោសនាង អញ្ជើញទៅកន្លែងណា ? ត្រូវការស៊ីក្លូទេ !

អ្នកធាក់ត្រីចក្រយានម្នាក់សួរនាង។

រត្ន-មណី ឈររារែកបន្តិច ក៏ដាច់ចិត្តឡើងអង្គុយលើស៊ីក្លូ ហើយ និយាយប្រាប់ទៅអ្នកធាក់ថា :

-សូមពូជូនខ្ញុំទៅម្តុំផ្សារសួន ខាងលិចសាលាព្រះអង្គអេង !

-បាទ !

អ្នកធាក់ត្រីចក្រយាន បាននាំនាងមកខាងលិចសាលាព្រះអង្គ អេងតាមបញ្ជា។ ក្រោយពីដើរស៊ើបសួរអស់ពេលមួយសន្ទុះធំ នាងក៏រកផ្ទះលោក ឌុប-ស៊ីផាន់ ឃើញ ។

ថ្ងៃនេះជាថ្ងៃអាទិត្យ លោកឌុប-ស៊ីផាន់ មិនបានទៅធ្វើការទេ កាលបើឮដំណឹងពីអ្នកបំរើថា មានគេសុំជួបលោកកអនុញ្ញាតឱ្យនាំចូលមកជួបលោកនៅក្នុងបន្ទប់ទទួលភ្ញៀវ។

-នាងជាកូនចៅអ្នកណា ហើយធ្លាប់ស្គាល់ខ្ញុំពីអង្កាល់ ? ខ្ញុំដូច ជារកនឹកនាងមិនឃើញសោះ ?

លោកឌុប-ស៊ីផាន់សួរ ក្រោយពីនារីកំសត់ធ្វើគារវកិច្ចចំពោះលោករួចហើយ ។

-ចា៎ ! នាងខ្ញុំជាកូននាយសែម នាងរឿន នៅបាត់ដំបងនេះជា សំបុត្រដែលឪពុកនាងខ្ញុំឱ្យយកមកជូនចំពោះលោកអ៊ុំ។

លោកឌុច-ស៊ីផាន់ ទទួលសំបុត្រពីដៃ មណី យកមកលាវអានសេចក្តី អានចប់លោកភ្ញាក់ព្រើត ដោះវ៉ែនតាសចេញពីភ្នែក គយគន់ មើលរូបរាងនារីអភ័ព្វ តាំងពីក្បាលរហូតចុងជើងដោយងឿងឆ្ងល់ ។

-យី ! នាងជាកូនសែមអ្នករឿន ? បើតចឹងនាង ឈ្មោះ មណី មែនទេ ?

-ចា៎ ! ត្រូវហើយលោកអ៊ុំ ...!

-មណី ! យី ! មណី ឥឡូវធំពេញក្រមុំស្អក កាលអ៊ុំផ្លាស់ពីបាត់ដំបងមកក្មួយនៅតូចណាស់ បានជាអ៊ុំមើលមិនស្គាល់ ចុះសែមនិងអ្នករឿនគេមានមកជាមួយក្មួយទេ ?

-ចា៎ ! ... ឪពុកម្តាយខ្ញុំ ... គាត់ស្លាប់អស់ទៅហើយ

-អុស ! សែមនិងអ្នករឿនស្លាប់ !

លោកឌុច-ស៊ីផាន់ ឧទានខ្លាំង១ ចេញមកដោយតក់ស្លុត។

-សែមនិងអ្នករឿនស្លាប់ ... ! ហ៊ឹ ... ចុះគេស្លាប់ប៉ុន្មានខែហើយក្មួយ មណី ?

-ចាំ ! ម្ដាយខ្ញុំទទួលអនិច្ចកម្មពីឆ្នាំទៅ គ្រោះថ្នាក់ក្រឡាប់ឡានស្លាប់ ចំណែកពុកគាត់ត្រឡប់មកពីរកត្រីងព្រៃរនាមក៏ឈឺគ្រុនចាញ់ ស្លាប់ផុតបួនប្រាំថ្ងៃមុននេះ ... !

-ហ៊ឺ ! គ្រោះថ្នាក់ប្រចាំជីវិត គ្មាននរណាយល់បានស្មានត្រូវទេ អ៊ុំនឹកអាណិត ឪពុកម្ដាយក្មួយណាស់ ក្មួយមកនេះដើម្បីមកនៅជាមួយអ៊ុំឬ ?

-ចាំ ! បើលោកអ៊ុំ មិនយល់ទាស់ទេ ខ្ញុំតាំងចិត្តថា នឹងនៅបំរើ លោកអ៊ុំរៀងរហូតទៅ ... !

និយាយផុតមាត់ ទឹកភ្នែកថ្លាដូចគ្រាប់ពេជ្រពីរតំណក់ក៏រមៀលធ្លាក់មកលើកំពាលឥដ្ឋ នារីកំសត់យំអួលអាក់ម្ដងទៀត កាលបើនឹកឃើញរឿងដើម ។

លោកឌុច-ស៊ីផាន់ មន្ត្រីចិត្តធម៌ លើកនារីកំព្រាឱ្យអង្គុយលើ សាឡុងទល់មុខលោកស្រួលបួល លោកមិនស្អប់ខ្ពើម មណី ទេ លោកនឹកឃើញទៅដល់កាលគ្រាលោកធ្វើជាចៅហ្វាយស្រុកនៅបាត់ដំបង ពេលមួយលោកស្រីភរិយាលោកឈឺធ្ងន់ ដោយជម្ងឺទាស់កូនខ្ចី នាយសែម សុខចិត្តបើកឡានទៅជីកឫសឈើនៅឯប៉ោយប៉ែត ព្រំប្រទល់ដែនខ្មែរសៀម ទាំងយប់អធ្រាត្រ យកមកផ្សំជាថ្នាំឆ្នាំងឱ្យលោកស្រីផឹក ត្រាតែបានជាឆ្លងផុតពីអន្លង់មរណៈ ។ មិនត្រឹមប៉ុណ្ណោះនាងរឿន ជាភរិយាបានមកធ្វើមេដោះបំបៅកូនលោកអស់ពេលរាប់ឆ្នាំគិត១ ទៅនាយសែមនិងនាងរឿនមានគុណលើគ្រួសារលោកធ្ងន់ណាស់ គួរតែលោកចិញ្ចឹមបីបាច់ថែរក្សា មណី ឱ្យដូចជាកូនលោកបង្កើត ។

-ឈប់យំសោកទៅក្មួយ មណី ! ពីថ្ងៃនេះទៅក្មួយផុតគ្រោះថ្នាក់ហើយ អ៊ុំនិងចិញ្ចឹមបីបាច់ថែរក្សាក្មួយ ឱ្យដូចជាកូនអ៊ុំបង្កើតកាល អាសត្យា កូនអ៊ុំនៅពីតូច វាក៏បៅដោះម្ដាយក្មួយដែរ ។

មណី ស្ដាប់មធុរវាចាលោកឌុច-ស៊ីផាន់ សែនត្រេកអររំភើបក្នុងដួងចិត្តឥតឧបមា នាងសំរុតខ្លួនចុះពីសាឡុងលូនទៅឱបបាទជើងលោកមន្ត្រីចិត្តធម៌ បង្ហើបវាចាមួយ១ ទៅកាន់លោកថា :

-ជាព្រះគុណដ៏ធ្ងន់ លើសលប់ណាស់លោកអ៊ុំ ខ្ញុំសូមនៅបំរើ លោកអ៊ុំប្រុសលោកអ៊ុំស្រី ព្រមទាំងអ្នកប្រុសសត្យារហូតអស់មួយជីវិត... !

-ហះ ! ហា ! ហា ...! កុំដាក់ខ្លួនឥចឹងក្មួយ មណី អ៊ុំមិនបាន រាប់ក្មួយចូលទៅក្នុងជំពូកបាវបំរើទេ ចូរក្មួយរស់នៅយ៉ាងសែនសុខលើគេហដ្ឋាននេះចុះ ...

លោកឌុច-ស៊ីផាន់ ឈប់ស្ងៀមអុជខ្សៀបន្តិច ទើបលោក និយាយថា :

-បន្តិចទៀតអ៊ុំស្រីឯង គេត្រឡប់មកពីផ្សារ គេមុខជាត្រេកអរណាស់កាលបើឃើញក្មួយ ចំណែកសត្យាកូនប្រុសអ៊ុំសព្វថ្ងៃគេនៅសិក្សាឯប្រទេសបារាំងឯណោះ បំណាច់ឆ្នាំចប់ការសិក្សាទើបបានត្រឡប់មកមាតុប្រទេសវិញ ! ....

សួរថយន្តលោកស្រីសេដ្ឋារោទិ៍ម៉ាស៊ីនពន្លត់ ។ លោកស្រីដើរ ឡើងទៅលើផ្ទះ លោកឌុច-ស៊ីផាន់ ក៏ណែនាំឱ្យភរិយាលោកស្គាល់ :

-នេះកូនក្រមុំសែមអ្នករឿនណាអូន !

-ជំរាបសួរលោកអ៊ុំ !

-ចាំ ! ចាំ ! លើកដៃថ្វាយព្រះនាង !

លោកស្រីសេដ្ឋា លើកដៃសំពះតបទៅ មណី រួចបែរមកសួរប្ដី :

-អ្នកសែមរឿននៅបាត់ដំបងនោះឬនាង ?

-ត្រូវហើយអូន ! តែឥឡូវសែមនិងអ្នករឿនស្លាប់បាត់ទៅ ហើយទុកនៅសល់តែកូនស្រីកំព្រាមួយនេះ ហ៊ឺ ! ... បងនឹកអាណិតខ្មោចសែមនិងអ្នករឿនណាស់អូន មនុស្សល្អចេះដឹងខុសត្រូវដូច្នេះមិន

គួរណាមកអាយុខ្លីសោះ ...!

ប្រមុខគេហដ្ឋានដូងតារា មានប្រសាសន៍បានត្រឹមណេះអួល ដើមក ធ្វើភ្នែករលីងរលោងរកកល់ចង់យំ ។

លោកស្រីសេដ្ឋាដកដង្ហើមធំ មានប្រសាសន៍មួយៗទៅកាន់ លោកប្រុសដោយសង្វេគថា :

-ហ៊ឺ ! សេចក្ដីស្លាប់រកកំណត់ឱ្យទៀងទាត់មិនបានទេបង ....! អ្វីៗនៅក្នុងលោកនេះសុទ្ធតែប្រែប្រួលទាំងអស់សេចក្ដីស្លាប់ប្រៀបដូច ស្រមោលអន្ទោលតាមខ្សែជីវិត ...!

-ប្រាកដណាស់អូន ...! សែមនិងអ្នករឿនគេធ្លាប់មានគុណ លើគ្រួសារយើង ឥឡូវបើសែមនិងអ្នករឿនរលត់ជីវិតពីលោកនេះទៅហើយ បងត្រូវតែជួយទំនុកបំរុងកូនគេ ឱ្យដូចជាកូនយើងបង្កើត តើអូនយល់ដូចម្ដេច ?

លោកស្រីសេដ្ឋា ជានារីប្រកាន់វណ្ណៈ លោកស្រីមិនពេញចិត្ត ចំពោះសំដីលោកឌុច-ស៊ីផាន់ ថាស្រឡាញ់រាប់អាននាងដូចជាកូនបង្កើតទេ តែលោកស្រីក៏មិនហ៊ានបញ្ចេញអាការៈអ្វីជាពិរុធឱ្យលោកស៊ីផាន់ដឹងឡើយ ។

-ចាំ ! តាមចិត្តបងចុះ ! ... អូនជាជើងជើងក្រោយស្រេចទៅលើជើងមុខ បើបងឃើញថាល្អ អូនក៏ល្អដូចបងដែរ ។

លោកឌុច-ស៊ីផាន់ ញញឹមពេញចិត្តនឹងសំដីភរិយា លោកបានហៅអ្នកបំរើឱ្យរៀបចំបន្ទប់ពិសេសមួយសំរាប់ មណី នាងស្នាក់អាស្រ័យ ។

បីខែកន្លងផុតទៅ រត្ន-មណី បានទទួលសេចក្ដីសុខពីក្រោមដំបូលគេហដ្ឋាន ដូងតារាយ៉ាងគ្រប់គ្រាន់ ។ លោកឌុច-ស៊ីផាន់ស្រឡាញ់ហើយអាណិតនាងទុកដូចកូនបង្កើត លោកតែងនិយាយប្រាប់ភ្ញៀវមិត្តភ័ក្ដដែលមកលេងផ្ទះលោកថា មណី ជាក្មួយ លោកបង្កើតទើបនឹងយកមកពីស្រែ ។ លោកស្រីសេដ្ឋាមិនពេញចិត្តនឹងស្វាមីលើកតំកើង មណី ខ្ពង់ខ្ពស់ដូច្នេះពេកទេ ព្រោះលោកស្រីធ្លាប់ស្គាល់ ហើយត្រកូលនាយសែមនាងរឿន ជាវណ្ណៈអធន ធ្លាប់នៅបំរើលោកស្រីរាប់ខែឆ្នាំ មណី គួរស្ថិតនៅជាឈ្នួលពិសេសរបស់លោកស្រី ដូចកាលខ្មោចឪពុកម្ដាយនាងនៅរស់ទើបសម ។

ល្ងាចថ្ងៃមួយ លោកស្រីសេដ្ឋាពិគ្រោះគ្នា ឮសូរមាត់រអ៊ូសៗនៅក្នុងបន្ទប់ជាមួយស្វាមីថា :

-នៅសល់ជាងពីរខែទៀត សត្យាកូនយើងវាត្រឡប់មកពី បំពេញវិជ្ជាឯស្រុកបារាំងហើយណាបង ! រឿងនាងភួងផល្លីន កូនក្រមុំលោកភួង-សំអាន យើងគិតរៀបចំយ៉ាងម៉េចទៅ ?

-ចាំបាច់គិតអីច្រើន ! លោកភួង-សំអាន លោកចង់តែភ្ជាប់សាច់ ភ្ជាប់ឈាមនិងគ្រួសារយើងទេ កាលបើអាសត្យាវាមកដល់ស្រុកខ្មែរវិញ យើងរៀបចំការឱ្យវាទៅក៏រួចរឿងអស់ទៅហើយ !

-ខ្ញុំសប្បាយចិត្តណាស់ កាលបើសត្យាវាមានប្រពន្ធ ! តើបងមានគំនិតដូចខ្ញុំទេ ?

លោកឌុច-ស៊ីផាន់ ងក់ក្បាលដាក់លោកស្រីជំនួសពាក្យឆ្លើយ ក្រោកដើរទៅឈរមាត់បង្អួចក្រឡេកមើលដើមចំប៉ីពីរបីដើម កំពុងរេរាំពត់ពេនតាមសរសៃវាតា ដូចជារកគិតពីរឿងអ្វីម្យ៉ាង ។

បរិយាកាសស្ងប់ស្ងាត់បានកើតឡើង មួយខណៈ លោក ឌុច-ស៊ីផាន់ ដើរមកអង្គុយកន្លែងដដែលម្ដងទៀត ពេលនោះលោកស្រីក៏មានប្រសាសន៍ឡើងថា :

-អ្នកជិតខាងគេចេះតែសួរខ្ញុំថា មណី ត្រូវជាអ្វីនឹងគ្រួសារយើង ខ្ញុំដូចជាពិបាកប្រាប់គេណាស់ ... !

-មិនជាក្រងាយអ្វីទេអូន ! គ្រាន់តែយើងឆ្លើយថាក្មួយយើង បង្កើតទៅវារួចទៅហើយ !

លោកឌុច-ស៊ីផាន់ មានប្រសាសន៍ធ្វើវាហី ។

-បងដូចជាលើកដំកើង សាច់គេអ្នកក្រៅជ្រុលបន្តិចហើយ សាច់ឈាមពណិសម្បុរ មណី មិនសាកសមជាក្មួយយើងទេ យើងខំអួតខ្លាំងពេកខ្លាចគេសើចណាំបង !

-អ្នកណាចង់យំចង់សើច ស្រេចលើក្បាលចិត្តគេចុះ! មណី ក៏ជាមនុស្សដូចយើងដែរ ខុសប្លែកត្រង់គ្នាកើតឡើងក្នុងត្រកូលអ្នកក្រី ក្រប៉ុណ្ណោះ អូនភ្លេចហើយ ឬកាលអូនឈឺបានអ្នកណាបើកឡានទៅរកថ្នាំឬសឈើឯបោយប៉ែតទាំងយប់ ? ហើយអ្នកណាជាមេដោះចិញ្ចឹម អាសត្យា ? បងមើលមិនឃើញ មណី ទាបថោកកន្លែងណាសោះ !

ទាល់ប្រាជ្ញខ្វាចចិត្តប្តី លោកស្រីសេដ្ឋា ក៏ត្រូវបិទមាត់នៅស្ងៀម លែងហ៊ានបង្ហាញហេតុផលអ្វីតទៅទៀត ។

❀ ❀

❀

~២~

## ស្នេហានិងវណ្ណៈ

អាក្រក់ផុតលេខគឺសត្វមនុស្ស
ឃើញគ្នាកំព្រាក្រតោកយ៉ាក
អាសូរនាងនាថទុក្ខគ្មានល្ហែរ
ដឹងដែរថាគេជិតរៀបការ

ស៊ីជុះស៊ីជុះចែកជាន់ថ្នាក់
វាយដំច្រំធាក់តតមេត្តា។
ជាប់ចិត្តមូលស្នេហ៍ប្រុសជីវ៉ា
អនិច្ចា ! ស្នេហានិងវណ្ណៈ!

ប្រាំខែក្រោយមក ....

ឌុច-សត្យា និស្សិតមហាវិទ្យាល័យច្បាប់ ដែលនៅសិក្សា ឯប្រទេសបារាំង ក៏ត្រូវត្រឡប់និវត្តន៍មកកាន់មាតុប្រទេសវិញ ។

លោកឌុច-ស៊ីផាន់ ឧត្តមមន្ត្រី និងលោកស្រីសេដ្ឋាភរិយា មានសេចក្តីត្រេកអរជាអតិបរមា កាលបើបានជួបភ័ក្ត្របុត្រសម្លាញ់ ត្រួយជីវិត ដែលឃ្លាតចាកពីដំបូលគេហដ្ឋានដួងតារា ទៅសិក្សាឯបរទេសអស់រយៈពេលបួនឆ្នាំ ។

លោកស្រីសេដ្ឋា បានរ៉ាយរ៉ាប់ប្រាប់ដំណើររឿងលោកស្រី ទៅស្តីដណ្តឹង នាងភួង-ផល្លីន កូនលោក ភួង-សំអាន ពាណិជ្ជករធំនៅ ទីក្រុងភ្នំពេញដល់សត្យាសព្វគ្រប់នរៈពុំបានជំទាស់អ្វីទេ អ្នកគ្រាន់តែសុំពន្យាពេលកុំឱ្យប្រញាប់ពេក និងបង្ហាញហេតុផលទៅលោកស្រីថា :

-ខ្ញុំទើបនឹងមកពីសិក្សាឯបរទេសដូច្នេះ ខ្ញុំមិនទាន់ចង់រៀបការប្រពន្ធកូនភ្លាមទេ ខ្ញុំនៅស្តាយវ័យកម្លោះស្តាយការសិក្សា ហើយ ជាពិសេស នារីដែលខ្ញុំត្រូវរើសជាមិត្តរួមជីវិតទៅអនាគត សូមម៉ាក់អាណិតទុកពេលឱ្យខ្ញុំបានស្និទ្ធស្នាល ស្គាល់ចិត្តស្គាល់ថ្លើមគេយូរបន្តិច សិន ការរៀបអាពាហ៍ពិពាហ៍ជាការងាយស្រួលទេ តែការរួមរស់ស្វែងរកសេចក្តីសុខ វាជាភារៈធ្ងន់ធ្ងរចំពោះគូស្វាមីភរិយាណាស់ ដូចពាក្យ ចាស់បូរាណលោកពោលថា ធ្វើស្រែបើខុសមួយឆ្នាំនៅសង្ឃឹមមួយឆ្នាំទៀត រឿងប្តីប្រពន្ធតែខុសហើយគឺខុសអស់មួយជីវិត ហេតុដូច្នេះ សូមម៉ាក់អាណិតជំរាបទៅលោក មា សំអាន ឱ្យពន្យាពេលដើម្បីទុកឱកាសឱ្យខ្ញុំបានស្គាល់ចិត្តថ្លើមផល្លីន យូរបន្តិចណ៎ា ម៉ាក់....!

កាលបើត្រូវបុត្រសម្លាញ់ បង្ហាញហេតុផលសមសួនគួរឱ្យស្តាប់បាន លោកស្រីសេដ្ឋា ក៏ត្រូវបិទមាត់នៅស្ងៀមលែងហ៊ានបង្ខិតបង្ខំ អ្វីតទៅទៀត ។

រត្ន-មណី  នារីកំសត់ ចាប់តាំងពីថ្ងៃ ឌុច-សត្យា ត្រឡប់ពី បរទេសមក នាងខំបំរើផ្គាប់ផ្គុណ ប្រុសកម្លោះមិនឱ្យទាស់ចិត្ត ដូចជាបោកខោអាវ រៀបចំដំណេក ខាត់ស្បែកជើង ។ ល ។ ទាំងនេះ មកពីនាងយល់ថា នាងជាក្មេងបំរើរបស់ផ្ទះដូងតារា នាងពុំបានយករឿងពីអតីតកាលរវាងនាង និងសត្យាមកគិតឡើយ ។ រៀងរាល់លើកដែលសត្យាហៅនាង នាងតែងអង្គុយលុតជង្គង់ឱនមុខ មិនហ៊ានថ្លែងវាចារអ្វីមុន ក្រោយពីបានទទួលបញ្ជាពីប្រុសកម្លោះ ។

ឌុច-សត្យា មានទស្សនៈប្លែកពី រត្ន-មណី យុវជនពុំដែលគិតថា មណី ជាបាវបំរើរបស់គេឡើយ គេស្រឡាញ់រាប់អាននាងក្នុងឋានៈជាប្អូនស្រីគេបង្កើត គេនៅចាំមិនភ្លេចកាលគេនៅពីតូចបានម្តាយនាងជាមេដោះបំបៅគេ នៅពេលដែលម្តាយគេមានជម្ងឺឈឺជាទម្ងន់។ ហេតុដូច្នេះ ដែលគេរាប់អាន មណី ក្នុងឋានៈជាប្អូនស្រីរួមខ្សែលោហិត  ក៏ឃើញថាគ្មានអ្វីជាទីរង្កៀសទាល់តែសោះ ។ តែគំនិតដែលនាយសត្យាមិនប្រកាន់វណ្ណៈនេះ បានត្រូវលោកស្រី សេដ្ឋា  ប្រឆាំងយ៉ាងខ្លាំង លោកស្រីមិនពេញចិត្តឱ្យកូនប្រុសលោកស្រី ទៅរាប់រក មណី ឱ្យហួសពីឋានៈក្មេងបំរើក្នុងផ្ទះទេ ។ ដូច្នេះ លោកស្រី សេដ្ឋា  ក៏បង្ករហេតុរករឿងស្តីគំរាមឱ្យមណី រៀងរាល់ថ្ងៃ ។

ស្រមោលទុក្ខចូលមកគ្របដណ្តប់លើខ្សែជីវិតយុវតីកំសត់ម្តងទៀត សេចក្តីសុខ ដែលនាងធ្លាប់បានទទួលមកពីមុនៗក៏ត្រូវរលាយអស់រលីងទៅវិញនៅពេលដែលសត្យាត្រឡប់មកពីបរទេស ។

លោកឌុច-ស៊ីផាន់ ជាមនុស្សចិត្តធម៌ មិនចេះប្រកាន់វណ្ណៈខ្ពស់ទាប ព្រោះលោកយល់ថា មនុស្សម្នាក់ៗកើតមកសុទ្ធតែចង់មានចង់ថ្លៃថ្នូរគ្រប់គ្នាទាំងអស់ គ្មានអ្នកណាម្នាក់ចង់ក្រចង់ថោកទាបទេ  តែធ្វើម្តេចបើវាសនាអាក្រក់ធ្លាក់ចំមកលើរូបគ្នាទៅហើយ គ្នាត្រូវតែទទួលទុក្ខទាំងក្រៀមក្រំ ។

រាល់លើកដែលលោកត្រឡប់មកពីធ្វើការ ឃើញលោកស្រី  ជេរស្តីបន្ទោស មណី លោកតែងចេញមុខអះអាងការពារជានិច្ច តែកំបាំងពីភ្នែកលោក  លោកស្រីក៏ជេរស្តីនាងដដែល ។

មណី ពុំដែលហ៊ានជំរាបការពិតដល់លោកស៊ីផាន់ទេ នាង ខំខាំមាត់អត់សង្កត់ចិត្ត នឹងអំពើទារុណកម្ម ព្រៃផ្សៃរបស់លោកស្រីសេដ្ឋា គ្រប់ពេលវេលា ទោះជាលោកស្រីធ្វើបាបរហូតដល់ទៅវាយដំច្រំធាក់បែកមុខមាត់យ៉ាងណាក៏ដោយ ។

ថ្ងៃនេះ ក្រោយពីលោកឌុច-ស៊ីផាន់ ទៅធ្វើការ ហើយសត្យា បើកឡានចេញទៅក្រៅបាត់ទៅ លោកស្រីក៏ដើរទៅជន្ទាលជេរមណី ឡូងៗនៅឯផ្ទះបាយ ខណៈដែលនាងកំពុងរៀបចំដណ្តាំស្ល :

-នែ៎ ! មីមណី ! មួយព្រឹកៗរវល់ធ្វើអីបានជាមិនលាងចានឆ្នាំង?

-ចា៎ ! លោកអ៊ុំ ... នេះខ្ញុំកំពុងលាងហើយទេតើ

-អើ ! អញឃើញលាងហើយ អញមិនខ្វាក់គ្រាប់ភ្នែកទេ ! តែអញចង់សួរថា តាំងពីព្រឹកម៉េចក៏ឯងមិនលាង ចាំអញដើរមកមើលបានឯងធ្វើជាលាងឥចឹងឬ ?

-ចា៎ ! មិនមែនដូច្នេះទេ លោកអ៊ុំ ពីព្រឹកមិញមីងចន្ទឈឺ ខ្ញុំក៏ទៅផ្សារជំនួសគាត់លុះត្រឡប់មកវិញក៏ចូលទៅរៀបចំបន្ទប់អ្នកប្រុសទៀត ហើយខ្ញុំប្រមូលសំពត់ខោអាវ លោកអ៊ុំប្រុស លោកអ៊ុំស្រី ទៅបោក  ទើបតែអស់មុននេះបន្តិច ក៏រវៀសរវៃមកលាងចានឆ្នាំង និងធ្វើ ម្ហូបលោកអ៊ុំ ...

-មាត់នាងល្អឯងគ្មានចេះទាល់ទេ ! វាសុទ្ធតែឥចេះវាសុទ្ធតែឥចុះ ! នែ ! អញសូមប្រាប់ម្តងទៀតណ៎ា ! បើចង់រស់នៅក្រោមដំបូលផ្ទះនេះដោយសុខសាន្ត  ត្រូវឈប់តាំងខ្លួនជាសាច់សាលោហិតនឹងម្ចាស់ផ្ទះ     ព្រោះត្រកូលនាងឯងឪពុកម្តាយនាងឯងកាលពីដើមវាគូលីអញ  ហើយដល់មកឯងចង់តាំងខ្លួន ធ្វើជាក្មួយអញ តើឱ្យអញ  យកមុខទៅទុកឯណា ? គ្រាន់តែព្រមចិញ្ចឹមនាងឯងឱ្យបាយស៊ី ព្រឹកល្ងាចទុកជាព្រះគុណ ជួយណាស់ទៅហើយ ! ម្យ៉ាងវិញទៀតឯងត្រូវឈប់ស្និទ្ធស្នាលជាមួយសត្យា ឯងធ្វើឥចឹងនាំឱ្យបាវព្រាវក្នុងផ្ទះគេមើល

ងាយកូនអញ ណាមួយលោតែលេចឮទៅដល់ត្រចៀកក្ដួយផល្លីន ឪពុកម្ដាយគេមិនបូរពុកអញស្លាប់ហើយឬ ? ឯងក៏ដឹងដែរថាផល្លីនជាគូដណ្ដឹងរបស់សត្យា ហេតុនេះឯងតូវចេះ ប្រើខួរក្បាលគិតឱ្យវែងឆ្ងាយផង !...

រត្ន-មណី នឹកតូចចិត្តនឹងវាសនានាងគ្មានពាក្យអ្វីឆ្លើយតប ទៅលោកស្រីក្រៅពីអង្គុយសំរក់ទឹកភ្នែក ។

លោកស្រីសេដ្ឋា ឃើញស្ងាត់ស្ងៀមដូច្នេះ ក៏បន្តវាចាថែមទៀត :

-បើអាសត្យា វានិយាយរកឯងត្រូវព្យាយាមគេចចេញពីមុខពីមាត់វាឱ្យបាត់ទៅ កុំនៅអង្គុយអល់អែក ដើមភ្នែកកន្ទុយភ្នែកម្និម្ម៉ក់ កាច់ឫកអួតរាង តែអញឃើញមិនបានទេ ហើយអញប្រៀនប្រដៅនេះតិចយកទៅទូលពិតប្ដីអញចុះ យើងនៅជាមួយគេកុំនាំដើមភ្លើងចុងភ្លើងទៅដុតរោលឱ្យប្ដីប្រពន្ធគេឈ្លោះប្រកែកគ្នា វាមិនប្រសើរទេណា៎ ! ត្រូវយើងតាំងចិត្តថា ខ្លួនអញជាអ្នកបំរើគេតែប៉ុណ្ណឹង វាសុខអស់មួយជីវិតទៅហើយ ម៉េចស្ដាប់ពាក្យអញទាន់ទេ មណី ?

-ចាំ ... !

-អើ ! បើឯងស្ដាប់បាន អញមានសេចក្ដីត្រេកអរណាស់ ! ថារួច លោកស្រីក៏ដើរចេញពីផ្ទះបាយបាត់ទៅ ។

មណី រសេះរសោះទន់ដៃទន់ជើង នាងហ៊ឹងត្រចៀកគ្មានស្ដាប់ឮទិសតំបន់អ្វីក្រៅពីសម្លេងស្ដីបន្ទោសរបស់លោកស្រី សេដ្ឋា ដែលដិតជាប់នៅក្នុងសោតិន្ទ្រីយារម្មណ៍នាងមិនទាន់ភ្លេច ។

ថ្ងៃនេះ ក្រោយពីលាងចានដណ្ដាំស្លរួច មណី ក៏រត់ទៅពួន សម្ងំយំក្រោយផ្ទះបាត់មួយថ្ងៃទល់ល្ងាច ។

..........................................................................................................

មួយសប្ដាហ៍រំលងផុត ...

រត្ន-មណី ព្យាយាមគេចមុខពីសត្យាមិនឱ្យជួប កិច្ចការដែល នាងធ្លាប់ធ្វើពីមុនមក ដូចជាបោកខោអាវរៀបចំគ្រែដេក នាងនៅតែប្រព្រឹត្តគ្មានប្រែប្រួល ខុសប្លែកត្រង់នាង មិនឱ្យជួបមុខគេប៉ុណ្ណោះ ទាំងនេះ ក៏ដើម្បីអនុវត្តន៍ទៅតាមបណ្ដាំលោកស្រី សេដ្ឋា ។

កម្លោះឌុច-សត្យា មានសេចក្ដីសង្ស័យ និងងឿងឆ្ងល់ចំពោះ កិរិយាព្រងើយកន្តើយ លាក់មុខលាក់មាត់របស់ មណី ជាខ្លាំង គេរកនឹកមិនឃើញសោះថា តើគេមានប្រព្រឹត្តអំពើ ឆ្គាំឆ្គង ឬ ពោលពាក្យទ្រគោះបោកអ្វីទៅលើនាង ? បានជានាងធ្វើសោះអង្កើយដាក់គេដូច្នេះ? ទ្រាំលែងបាន ប្រុសកម្លោះក៏ចាំជួប មណី នៅពេលល្ងាចមួយក្នុងបន្ទប់របស់អ្នក ជាពេលដែលលោកប្រុស លោកស្រីត្រូវចេញទៅក្រៅផ្ទះ ទទួលការជប់លៀងក្នុងពិធីបុណ្យរបស់មិត្តលោក ។

-អូនមណី ! បងសង្កេតឃើញអាកប្បកិរិយាអូនប៉ុន្មានថ្ងៃនេះ ខុសប្លែកពីមុនឆ្ងាយណាស់ ! អូនចេះតែគេចមុខពីបង តើអូនអាក់អន់ ចិត្តអ្វីនឹងបងឬ ?

-ចាំ ! អត់ទេអ្នកប្រុស ... !

-ឈប់ហៅបងអ្នកប្រុសទៀត ! បងប្រាប់អូនប៉ុន្មានដងហើយ ថាបងមិនត្រូវការឱ្យអូនហៅដូច្នេះទេ អូនម្ដេចក៏ចូលចិត្តដាក់ខ្លួនម្លេះ !...

-ខ្ញុំមិនមែននិយាយដាក់ខ្លួនទេ ... ខ្ញុំហៅអ្នកប្រុសដូច្នេះ គឺវា សក្ដិសមនឹងឋានៈរបស់ខ្ញុំណាស់ទៅហើយ ! អា .... អ្នកប្រុសអត់ទោស ខ្ញុំសូមលាអ្នកប្រុសទៅធ្វើការខាងក្រោយបន្ដិច ...និយាយរួចមណី បំរុងក្រោកដើរតែត្រូវសត្យាចាប់កដៃជាប់ ។

-ប្រញាប់ទៅណាអូន មណី ! អង្គុយចុះសិនមក អូនមិនទាន់ឆ្លើយប្រាប់បងផងថា ហេតុអ្វីបណ្ដាលឱ្យអូនស្អប់មុខបង ។

មណី សែនតានតឹងក្នុងចិត្ត នាងនឹកអាណិតសត្យាដែលពុំបានដឹងរឿងពិត នាងគ្មានស្អប់គេទេ នាងធ្វើព្រងើយកន្តើយ ដើម្បីបំពេញគោលបំណងរបស់លោកស្រីសេដ្ឋា ។ តើឱ្យនាងទម្លាយការណ៍ពិតប្រាប់គេឬ ? ទេ ! នាងមិនត្រូវនិយាយជាដាច់ខាតបើនាងហ៊ាន

និយាយក៏ដូចជានាងបំផ្លាញសេចក្តីសុខក្នុងគ្រួសាររបស់គេ ។ ហារស្លាក់ខ្ចាក់ស្លែង ទឹកភ្នែកកម្សហូរច្រោកៗកាត់តាមប្រឡាយថ្ពាល់នារី កំសត់ជាចម្លើយឆ្លើយបញ្ជាក់ឱ្យប្រុសកម្លោះដឹងថានាងកំពុងទទួលទុក្ខជាទម្ងន់ ។

-មណីអូន ! បើទុកជាអូនមិនហ៊ានឆ្លើយការពិតប្រាប់បង ពេលនេះបងក៏អាចយល់បានខ្លះៗដែរ .... អូនត្រូវម៉ាក់ហាមឃាត់មិនឱ្យវីរវល់នឹងបងមែនទេ ? បងដូចជាមិនយល់ទាល់តែសោះ ហេតុអ្វីបានជាម៉ាក់ត្រូវធ្វើតចឹង ? ការពិតខ្មោចឪពុកម្តាយអូនមានគុណលើគ្រួសារបងណាស់ ចំពោះបងបើកុំបានទៅបៅដោះម្តាយរបស់អូន ប្រហែលជាបងមិនបានរស់រានមានជីវិតទល់សព្វថ្ងៃឡើយយើងពីរនាក់មានជាប់ខ្សែលោហិតតែមួយណាអូន ....

មាណវី មិនឆ្លើយតប នាងនៅតែអង្គុយជំរុះទឹកនេត្រាដោយសភាពស្ងាត់ស្ងៀមដដែល ។

-អូនមណី ! ពេលនេះជាពេលស្ងាត់ ឪពុកម្តាយបងក៏លោកមិននៅ អូននិយាយរកបងមកបងចង់ស្តាប់សម្លេងអូនណាស់ ហ៊ឺ ! បើអូននៅអង្គុយធ្មឹងធ្មៃដូចរូបចម្លាក់ឥតវិញ្ញាណតទៅទៀត បងមុខជាប្រេះទ្រូងស្លាប់មិនខាន... និយាយរកបងមកអូនមណី !

រត្ន-មណី ទឹកអាណិតសត្យាខ្លោចថ្លើមប្រមាត់ នាងបាន ប្តេជ្ញាក្នុងចិត្តរួចជាស្រេចហើយថា នាងនឹងមិននិយាយស្តីរកសត្យាជាដាច់ខាត លុះត្រូវគេអង្វរនាងក៏កើតការអាណិតទោះជាខុសនឹងក្រឹត្យវិន័យ ដ៏តឹងតែងរបស់លោកស្រី សេដ្ឋា យ៉ាងណាក៏ដោយ នាង ត្រូវតែនិយាយចរចាជាមួយប្រុសកំឡោះក្នុងពេលនេះ :

-អ្នកប្រុស ! ខ្ញុំមិនដែលមានចិត្តទឹកប្រកាន់ខឹងអ្វីលើអ្នកប្រុសទេ ការពិតខ្ញុំស្រឡាញ់កោតគោរពអ្នកប្រុសដូចជាអ្នកបំរើទូទៅដែលតែងតែស្រឡាញ់ចៅហ្វាយនាយតែ ... ខ្ញុំ ... ខ្ញុំ ត្រូវលោក អ៊ុំស្រី ហាមឃាត់មិនឱ្យនិយាយរកអ្នកប្រុសមិនឱ្យនៅជិតអ្នកប្រុស បើខ្ញុំមិនធ្វើតាមបណ្តាំគាត់ទេ គាត់នឹងវាយធ្វើបាបខ្ញុំ ហើយបណ្តេញឱ្យ ខ្ញុំចេញផុតពីផ្ទះនេះ !

-ហ៊ឺះ ! ទឹកចិត្តម្តាយបងកាចសាហាវមែន តើមកពីរឿងអ្វីអូនមានដឹងខ្លះៗទេ ?

-ចា៎ ! ខ្ញុំដឹងត្រឹមតែថា អ្នកប្រុសជិតរៀបការជាមួយអ្នកនាង ផល្លីននៅពេលឆាប់ៗខាងមុខនេះ ។

-ហើយអ្វីទៀត ?

-ចា៎ ! ខ្ញុំ ដឹងត្រឹមប៉ុណ្ណឹង ! ...

-រឿងរៀបការរវាងបងនិងផល្លីន ដូចជាគ្មានអ្វីជាសំខាន់ ល្មមហាមឃាត់មិនឱ្យយើងនិយាយរកគ្នាសោះ ម៉ាក់បងលោកដូចជាអយុត្តិធម៌ណាស់ !

និយាយរួច ទឹកមុខប្រុសកម្លោះស្រស់ស្រាយរីករាយ អំបាញ់មិញក៏ប្រែជាក្រៀមស្រពោនដូចមណីដែរ ។ សត្យាពេលលនេះអ្នកហាក់មានអំណាចចិត្តអ្វីម៉្យាងធ្វើឱ្យអ្នកមើលទៅមុខ មណី កាន់តែគួរឱ្យអាណិតនិងគួរឱ្យស្រឡាញ់ខ្លាំងៗឡើង ។ សេចក្តីស្រឡាញ់របស់អ្នកពេលនេះប្លែកណាស់មិនមែនស្រឡាញ់ក្នុងឋានៈជាប្អូនស្រីដូចពេលមុនៗទេ តែវាជាសេចក្តីស្រឡាញ់ដែលដុះចេញមកពីបេះដូងបរិសុទ្ធ ។

សត្យា ចាប់ទាញប្រាណនារីដៃញ័រទទ្រើក រហ័សដូចផ្លេកបន្ទោរ គេក៏ស្ទុះទៅជម្ពិត ភួងថ្ពាល់របស់ មណី ហើយក៏ឱបរឹតប្រាណនាងជាប់ ។ មណី ក្នុងជីវិតនាង មិនដែលជួបប្រទះនូវហេតុការណ៍ដូច្នេះ ក៏តក់ស្លុតភិតភ័យរកព្រលឹងព្រលះគ្មាន នាងខំប្រឹងរើបំរះចេញពីរង្វង់ដៃប្រុសកម្លោះអស់ទំហឹងតែមិនសំរេច ។

-អ្នកប្រុសលែងខ្ញុំ ! អ្នកប្រុសកំពុងធ្វើអ្វីខ្ញុំហ្នឹង លែងខ្ញុំភ្លាម ទៅអ្នកប្រុស ! លោកអ៊ុំអញ្ជើញមកទាន់ឥឡូវហើយ !

-បងមិនលែងអូនទេ បងស្រឡាញ់អូន មណី វិញហើយពេលនេះ !

-យី ! អ្នកប្រុសស្រឡាញ់ខ្ញុំ

-ត្រូវហើយ មណី បងស្រឡាញ់អូន ស្រឡាញ់លើសផល្លីន រាប់រយសែនដងទៅទៀត ពេលនេះបើទុកជាលោកប៉ា ម៉ាក់មកទាន់បងក៏មិនញញើតនឹងជំរាបការពិតដល់លោកដែរ !

ពោលចប់ប្រុសកម្លោះក៏ផ្តួលប្រាណនារីកំសត់ទៅលើពូក ដោយកំដៅភ្លើងស្នេហាឆេះពុះពោរ ។ មណី នាងខំប្រឹងរួបរួមកម្លាំងពលំ រើបំរះដើម្បីការពារមន្ទិលក្នុងវ័យក្រមុំរបស់នាងម្តងទៀត តែពុំបានសមបំណងឡើយ ។

នៅខាងក្រៅផ្ទះ ពពកខ្មៅ រាប់មិនអស់កំពុងហោះហើរ លឿនស្លៅ ពពាក់ពពូនពេញផ្ទៃមេឃា ។ មួយសន្ទុះប៉ុណ្ណោះព្រះភិរុណក៏បង្អោរភ្លៀងខ្នោក១ ស្រោចស្រពលើផែនដី ។ ព្រះវាយោ បក់កញ្ជ្រោក បោកទ្វារបង្អួច ខ្ទប់បិទជិតឮសូរគ្រាំង ! នៅក្នុងបន្ទប់ សត្យាងងឹតសូន្យសុង ។ សូររើបំរះព្រួស ! ប្រាស ! អំបាញ់មិញ ក៏បាត់ស្ងាត់បន្តិចម្តង១ នៅសល់តែស្នូរដង្ហើមនៃអ្នកទាំងពីរ ទំលុះទំលាយបរិយាកាសស្ងប់ស្ងាត់ ។

វាំងភ្លៀងស្ងប់ខ្យល់ អ្វី១ជាទីហួងហែងនៃវ័យក្រមុំ មណី បានត្រូវបង់ខាតទៅលើសត្យា បុត្រលោកឧត្តមមន្ត្រីគ្មានសល់ ។

មណី ដេកផ្កាប់មុខយំហ៊ូ១ ដូចកូនក្មេង នាងមិនមែនស្អប់ នាយសត្យាទេ តែនាងកំពុងសោកស្តាយព្រហ្មចារីយ ស្តាយអនាគតខាងមុខមិនដឹងជាហេតុការណ៍ក្នុងជីវិតប្រែប្រួលដូចម្តេច ស្នេហានិងវណ្ណៈ ធ្វើឱ្យតរុណីនឹកព្រួយបារម្ភគ្មានពេលល្ហែ ។

-អូនមណី ! អូនឈប់១យំសោកទៅ ទោះជាយ៉ាងណាអូន ក៏ជាប្រពន្ធបងហួសទៅហើយក្នុងជាតិនេះ បងនឹងស្រឡាញ់តែអូនម្នាក់ ទោះជាមានឧបសគ្គមារចាំជ្រែកយ៉ាងដូចម្តេចក្តី បងនឹងខំពុះពារ តស៊ូដរាបជីវិតក្ស័យ ជឿចិត្តបងចុះអូន មណី ....!

-ចាំ ! អូនឥតស្អប់បងទេ អូនស្រឡាញ់បង ... បូជាបងស្មើជីវិត តែវណ្ណៈទេតើ ដែលធ្វើឱ្យអូននឹកភ័យ១គ្មានពេលស្រាកស្រាន្តបើលោកអុំជ្រាបរឿងនេះ អូនមុខជាត្រូវលោកអុំធ្វើទារុណកម្ម ហើយ ខ្ចាតចេញពីដំបូលផ្ទះនេះ ដោយមិនបាច់សង្ស័យ ។

-កុំព្រួយអូន ! ចូរអូនតាំងចិត្តឱ្យនឹងនំចុះ រឿងហេតុគ្រប់យ៉ាងបងទេ ជាអ្នកទទួលខុសត្រូវ មណីអូនជាតិនេះបងមិនអាចរស់នៅខ្វះរូបអូនបានជាដាច់ខាត អូនជាពន្លឺនៃជីវិតរបស់បង ...

-ចាំ ! អូនក៏ដូច្នោះដែរ នៅក្នុងលោកនេះបើគ្មានរូបបង.... អូនក៏គ្មានសេចក្តីសុខ ....

វាំងននជីវិត បានបិទបាំងសេចក្តីស្នេហាវវាងក្រមុំកម្លោះ ឱ្យកប់បាត់ក្នុងស្រមោលទុក្ខរាប់តាំងពីថ្ងៃនេះ ។

ស្នេហានិងវណ្ណៈ មុខជាកើតការប្រឆាំងគ្នានៅពេលណាមួយជាមិនខាន សូមលោកអ្នកអានរង់ចាំមើលតទៅទៀត តើជោគវាសនា នឹងដាក់ទណ្ឌកម្មនាងដល់កំរិតណា ?

~៣~

## គេវាំងខ្ទប់ចិត្ត

| | |
|---|---|
| ខំទៅបំរើផ្កាប់ផ្គន់គេ | ត្រូវវាយត្រូវជេរគ្មានលោះថ្ងៃ |
| ប្រើឱ្យធ្វើការឥតប្រណី | ខាំមាត់មិនខ្ចីស្តីវាចា ។ |
| ស៊ូតែពីទ្រាំរកាំចិត្ត | គួរឱ្យអាណិតនាថកល្យាណ |
| មិនហ៊ានរ៉ាយរ៉ាប់ប្រាប់សង្សារ | ខ្លាចគេជៀលថាខ្លួននាំភ្លើង ។ |

បើទុកជាលោកស្រីសេដ្ឋា វាយដំច្រំធាក់ធ្វើបាប ប្រើឱ្យធ្វើការធ្ងន់ៗ គ្មានមេត្តាត្រាប្រណី មណី នាងនៅតែខាំមាត់អត់ធ្មត់ តស៊ូនឹងអំពើអមនុស្សធម៌ របស់លោកស្រីបានជានិច្ច ។ ថ្ងៃណាក៏ដូចជាថ្ងៃណា ឱ្យតែលោកឌុច-ស៊ីផាន់ និងសត្យាចេញទៅធ្វើការបាត់ មណី តែងត្រូវលោកស្រីសេដ្ឋា វាយទះតប់ ជេរស្តីពាក្យអាសអាភាសនានា មានជួនកាលលោកស្រីយកដល់ទៅអំបោសសំពងក្បាលនាង បែកហូរឈាមរហូតសន្លប់បាត់ស្មារតី ផុតពីសន្លប់លោកស្រីក៏ប្រើនាង ឱ្យធ្វើការទាំងឈឺចាប់តទៅទៀត ។

គួររាប់ថា សំណាងនាងរត្ន-មណី នៅខ្លះសល់បន្តិច គឺលោកស្រីសេដ្ឋា មិនបានជ្រាបរឿងរ៉ាវទាក់ទងរវាងសត្យានិងនាង បើប្រសិនជាលោកស្រីដឹងទៀត មណី មុខជាត្រូវលោកស្រីវាយស្លាប់ជាប្រាកដ ។

ថ្ងៃនេះ ក៏ដូចជាថ្ងៃមុនៗ ក្រោយពីលោកស្រីសេដ្ឋាទៅទទួល យកកញ្ញា ភួង-ផល្លីន អនាគតកូនប្រសារមកលេងផ្ទះ លោកស្រីក៏ចាប់ផ្តើមបើកឆាករករឿងធ្វើទារុណ មណី បង្អួតមុខអនាគត កូនប្រសារដូចពេលមុនៗដែលធ្លាប់ធ្វើមក ។

-មី មណី ! អី ! មីឃ្មី !

-ចាំ ! លោកអុំ !

ផុតសម្លេង ក៏លេចរូប មណី ចេញពីផ្ទះបាយទាំងដៃប្រឡាក់ពពុះ សាប៊ូស្រមក ។

លោកស្រីសេដ្ឋា ឈរសម្លក់សម្លឹង ពីក្បាលរហូតចុងជើង ដោយស្អប់ខ្ពើម ។ លោកស្រីមានប្រសាសន៍ទៅកាន់ មណី ទ្រង់គំហកថា :

-ឯងកំពុងតែធ្វើស្អីហ្នឹង !

-ចាំ ! បោកខោអាវអ្នកប្រុសលោកអុំ ....!

-ស្លាប់អញហើយ ! ម៉ោងជាងដប់ទើបនឹងបោកខោអាវ យី !

មីចោរកំពូជថោក ឯងម្តេចក៏វាខ្ជិលម្ល៉េះ ! មក ! វារចូលមកជិតបាទ ជើងអញ ឱ្យអញវាយបាត់ក្តៅចិត្តបន្តិច ! វរៗអញប្រេះទ្រូងក្អួតឈាមស្លាប់ដោយសារងែងហើយ !

នារីកំសត់ សំរុតខ្លួនចុះវារចូលទៅទាបបាតជើង លោកស្រី ពេលនោះទឹកភ្នែកកម្ម មិនដឹងមកពីណាក៏ហូរហៀរជោគផ្ទៃមុខនាងមួយរំពេច ។ មណី លើកដៃសំពះលោកស្រី ទាំងចុកចាប់ក្នុងទ្រូង :

-លោកអុំ ! ខ្ញុំទើបទំនេរដៃពីជួយធ្វើម្ហូបមីងចន្ទទេតើ ..... ! សូមលោកអុំអភ័យទោស... ឱ្យខ្ញុំផង ...

-ជួយស្តាប់ម៉ាក់ចុះផល្លីន ! សំដីមីខ្ញុំគេនេះ មិនចេះអន់ទេ ! វាប៉ិនប្រសប់ណាស់ខាងដោះស្រាយ

-វាត្រូវជាស្អីនឹងយើងម៉ាក់ ? កញ្ញាផល្លីនសួរ ព្រមទាំងលួចសម្លក់មុខ មណី ។

-ត្រូវជាស្អី ? ត្រូវជាខ្ញុំកញ្ជះបាទជើង យើងណាកូន កំពូជវា ចាប់តាំងពីឪម៉ែវាមកនៅធ្វើខ្ញុំម៉ាក់ទាំងសំបុក តែមីនេះវាប្ញកធំណាស់ ! សព្វថ្ងៃបានប៉ាកូននិងអាសត្យាកាន់ជើង វាចង់ភ្លេចកំណើតខ្លួនអស់ទៅហើយ !

-អ៊ូ ! ឥចឹងទេតើ បានជាខ្ញុំឮបងសត្យាប្រាប់ថា គាត់មានប្អូន ជីដូនមួយស្រីម្នាក់ ខ្ញុំមិនដឹងជានាងស្រីល្អខ្ញុំគេនេះសោះ នែ ! នាងក្រមុំ ! ងើបមើលមុខខ្ញុំបន្តិចមើល៍ មុខនាងឯងវាល្អវិសេសយ៉ាងម៉េច បានជាចង់តាំងខ្លួនធ្វើក្មួយម៉ាក់ !

មណី ក្តៅឈួលចុងច្រមុះ នាងមិនអាចឱ្យនរណាជេរស្តី ត្មះតិះដៀលក្រៅពីរូបលោកស្រីសេដ្ឋាមួយជាដាច់ខាត នាងងើបមើលមុខផល្លីនថ្លាមរណ្តំគ្នាក្រីតៗ សួរទៅនាងក្រមុំខ្ទះសុជីវធម៌ថា :

-សូមនាងផល្លីនមេត្តាកុំមើលងាយខ្ញុំខ្លាំងពេក បើទុកជាខ្ញុំ ខ្ញុំគេក៏ខ្ញុំគេក្នុងផ្ទះលោកអុំប៉ុណ្ណោះ ?

-យើ ! អញគ្រាន់តែថាប៉ុណ្ណឹងមិនបានផង ខ្ញុំមិនសុខចិត្តទេម៉ាក់ ! ម៉ាក់ត្រូវតែរកខុសត្រូវឱ្យខ្ញុំ !

ផល្លីន ទន្រ្ទំជើងប៉ុងៗ មុខក្រហមស្ទើរស្រក់ឈាម ។

លោកស្រី ដើរទៅយករំពាត់ផ្ដៅសៀតគៀនជញ្ជាំងហុច ឱ្យកញ្ញាផល្លីន :

-វាយវាទៅកូន ! មីសត្វហ្នឹង វាមាត់រឹងណាស់ វាយវាឱ្យស្លាប់ ទៅចុះផល្លីន !

-ចា៎ ! ម៉ាក់ !

ផល្លីន ទទួលរំពាត់ផ្ដៅពីដៃលោកស្រីមកកាន់ ហើយក៏វាយវ៉ៃតទៅលើប្រាណនារីកំសត់ដែលនៅក្រាបស្ងៀមគ្មានអាណិតអាសូរ ។

មណី ស្ទុះកញ្ជ្រោលក្រោកឡើង ដោយអាការៈឈឺចាប់ ។ នាងចាប់កន្ត្រាក់រំពាត់ពីដៃកញ្ញាផល្លីនអស់ទំហឹង បណ្ដាលឱ្យបុត្រីលោកមហាសម្បត្តិភ្លូង សំអាន ជ្រុលខ្លួនដួលជ្រមុញជ្រមកបីបួនត្រឡប់ ។

លោកស្រីសេដ្ឋាខឹងណាស់ ស្ទុះទៅលើកទ្រអនាគតកូនប្រសារ ។ លោកស្រីចាប់ទាញសក់ មណី ទាញគ្រវីគ្រវាត់បីបួនជុំ រួចហើយក៏ធាក់នាងចំកណ្ដាលពោះជាច្រើនជើង បណ្ដាលឱ្យនារី កំសត់ចុកចាប់ ដួលដេកទៅនឹងកំរាលឥដ្ឋស្រែកថ្ងូរគួរឱ្យអាណោចអធ័ម ។ មិនទាន់បាត់ក្ដៅ លោកស្រីយកជើងជាន់សង្កត់ត្រង់ក មណី មិនឱ្យនាងស្រែកថ្ងូរបានទៀត ។ នេះបានហៅចំជាឆ្អែមចិត្តឫស្យា រកប្រដូចគ្មានក្នុងលោក ។

-ម៉ែងមាត់រឹងណាស់មីឃ្មី ! មីកញ្ចះអញអស់មួយពូជ ! ថ្ងៃនេះម៉ែងហ៊ានមើលងាយកូនប្រសារអញ អញត្រូវតែវាយម៉ែងជាន់កឱ្យស្លាប់នៅនឹងកន្លែង ! ស្លាប់ឱ្យបាត់ពីមុខពីមាត់អញឱ្យស្រឡះទៅមីឃ្មី ! មីកំពូជខ្ញុំគេ !

ថាហើយ លោកស្រីក៏ធាក់ច្រំលើ មណី តទៅទៀត ។

ពេលនោះ សូររថយន្តលោកឧុច-ស៊ីផាន់ ក៏ចូលមកឈប់ចតមុខផ្ទះ ។ លោកស្រីសេដ្ឋា ប្រញាប់ដកជើងចេញពីកនារីកំសត់ហើយនិយាយសំឡុតថា :

-នែ ! មីឃ្មី ! ប្ដីអញឡើងមកម៉ែងត្រូវឈប់យំនៅស្ងៀមណ៎ា ឥឡូវចូលទៅក្នុងបន្ទប់ទៅកុំឱ្យគេមកឃើញទាន់ !

មណី នារីកំសត់មិនឆ្លើយតប នាងខំប្រឹងរួបរួមកម្លាំងដែលនៅសល់តិចតួច ប្រឹងលូនទៅកាន់បន្ទប់ទាំងឈឺចាប់សព្វមំសា ។

លោកឧុច-ស៊ីផាន់ ឡើងមកដល់លើផ្ទះ កញ្ញាផល្លីនក៏លើកដៃ សំពះសួរ :

-ខ្ញុំជំរាបសួរលោកប៉ា ...!

-អឺ ...អឺ ! ល្អហើយកូន ... អា ... កូនមកយូរហើយឬ ? លោកស៊ីផាន់សួរ ។

-ចា៎ ! ខ្ញុំមកជាមួយម៉ាក់តាំងពីព្រឹកម្ល៉េះ !

លោកប្រមុខគេហដ្ឋាន ដូងតារាគ្រវាស ក្រឡេកទៅជុំវិញផ្ទះក៏ សួរទៅលោកស្រីភរិយាថា :

-ម៉ាក់វា ! ក្មួយមណីទៅណាហើយម្ដេចក៏មិនឃើញ ?

-ចា៎ ! វាមិនសូវស្រួលខ្លួន ខ្ញុំក៏ឱ្យសម្ងំដេកទៅ

-មានដឹងកើតអីទេ ?

លោកឧុច-ស៊ីផាន់សួរ សំដែងអាការៈព្រួយបារម្ភ ។ លោកស្រី បុកពោះភឹប ! ភឹប ! តែខំប្រឹងធ្វើជាស្រាយ ទឹកមុខនិយាយរបៀបធម្មតាថា :

-ខ្ញុំឮមីងចន្ទប្រាប់ថាវាឈឺក្បាល !

-ហ៊ឺ ! ខែនេះផ្លាស់ខ្យល់ ឈឺស្ទើរតែគ្រប់គ្នា ម៉ាក់វាឯងល្មម ប្រើក្មេងឱ្យទៅអញ្ជើញគ្រូពេទ្យគេមកចាក់ថ្នាំឱ្យវាផង លោតែឈឺធ្ងន់ទៅពិបាកចិត្តខ្ញុំស្លាប់ហើយ ! ម្យ៉ាងវិញទៀត កុំសូវប្រើឱ្យក្មួយធ្វើការច្រើនពេក ម្ងៃៗមិនដែលឃើញ មណី បានឈប់សំរាក ដើរលេងអីនឹងគេសោះ ក្មេងក្មាងក្នុងផ្ទះបួនដប់នាក់ប្រើឱ្យវាធ្វើការខ្លះៗផង កុំឱ្យចាំតែម្នាក់ៗ ឥចឹងមិនកើតទេណ៎ា ! ...

លោកស្រីសេដ្ឋាទឹកខ្មាញ់នឹងសំដីប្ដី :

-បងដូចជាកាន់ជើង មណី ជ្រុលបន្តិច ! ក្មេងក្មាងក្នុងផ្ទះបើ យើងមិនទម្លាប់ប្រើឱ្យវាស្គាល់ការងារខ្លះ ថ្ងៃក្រោយចេញពីយើងទៅវាយ៉ាងម៉េចទៅវិញ ?

លោកឧច-ស៊ីផាន់បងចិញ្ចើម :

-អូនឯងនិយាយសំដៅទៅលើអ្នកណា !

-លើនាង មណីហ្នឹង !

-ហ៊ឹះ ! អូនកុំច្រឡំឱ្យសោះ មណី មិនមែនក្មេងបំរើដូចអ្នក ឯទៀត១ទេ បងលើកដំកើងវាទុកដូចជាកូនចៅបង្កើត !

-ថ្ងៃក្រោយគេដឹងរឿងពិត គេមុខជានាំគ្នាសើចរយះមាត់ជា ពុំខាន !

លោកស្រី មានប្រសាសន៍រួចក៏បែរមុខទៅម្ខាង ដោយមិន ពេញចិត្តនឹងវាចាប្តី ។

-អ្នកណាគេចង់សើច ចង់យំស្រេចតែគេចុះ មនុស្សយើងបើ វល់រើសអើងប្រកាន់វណ្ណៈរបៀបនេះ គេមិនហៅថាមនុស្សធម៌ទេ សេចក្តីថ្លៃថ្នូររបស់មនុស្សមិនមែនស្ថិតនៅត្រង់មាន ឬក្រឯណា ?

ម្តងនេះលោកស្រីសេដ្ឋា ទាល់ប្រាជ្ញាមិនដឹងរកពាក្យអ្វីឆ្លើយ តបស្វាមីបាន ក៏ត្រូវបិទមាត់នៅស្ងៀមទាំងក្នុងទ្រូងក្តៅគគុក ។

លោកឧច-ស៊ីផាន់ ផ្លាស់សំលៀកបំពាក់រួចហើយលោកក៏ ដើរទៅកាន់បន្ទប់ មណី ដើម្បីសាកសួរជម្ងឺនាង ។ លោកស្រីសេដ្ឋា និងកញ្ញាផល្លីនឃើញដូច្នោះ នឹកភ័យស្ទើររកព្រលឹងព្រលះក្នុងខ្លួនគ្មាន ចង់ឃាត់ដំណើរលោកប្រុស តែឃើញទឹកមុខបែបមិនស្រួលក៏នាំគ្នាគេចទៅសម្ងំឯបន្ទប់ទទួលភ្ញៀវបាត់អស់។

-គុក ! គុក ! មណី ! បើកទ្វារឱ្យអ៊ុំបន្តិចក្មួយ !

មណី កំពុងដេកផ្កាប់មុខយំ ឮសូរមាត់លោកឧច-ស៊ីផាន់ នាងភ្ញាក់ព្រើត នាងឮអស់ហើយនូវពាក្យចរចារវាងលោកប្រុស និងលោកស្រីអំបាញ់មិញនេះ ។ បើនាងបើកទ្វារឱ្យ លោកឧច-ស៊ីផាន់ ឃើញរាងកាយនាង ស្នាមសុសទៅដោយរំពាត់ ហើមជាំ បែកឈាមរបៀបនេះ លោកឧច-ស៊ីផាន់ និងលោកស្រីសេដ្ឋាមុខជាកើតការវិវាទគ្នា ដោយសារតែរូបនាងម្នាក់ពុំខាន ដូច្នេះការល្អនាងត្រូវតែធ្វើជាដេកលក់ ។

-គុក ! គុក ! គុក ! មណី ! មណី ! បើកទ្វារឱ្យអ៊ុំបន្តិចក្មួយ ! មណីបើកទ្វារឱ្យអ៊ុំ ! គុក ! គុក !

សូរគោះទ្វារស្រែកហៅ ឈ្មោះកាន់តែញាប់រន្ថើនខ្លាំងឡើង១ ទ្រាំពុំបានមណី ក៏ដាច់ចិត្តក្រោកពីលើគ្រែ ដំណើរទ្រេតទ្រោតដើរមកបើកគន្លឹះទ្វារជូនលោក ឧច-ស៊ីផាន់ ។

-យី ! ក្មួយមណី !(លោកឧច-ស៊ីផាន់ឧទាន) ម្តេចក៏មាន ស្នាមរំពាត់ជាំបែកឈាមពេញទាំងខ្លួនឥចឹង ? ប្រាប់អ៊ុំភ្លាមមក ! អ្នកណាគេធ្វើបាបក្មួយ ? អ៊ុំស្រីឯងមែនទេ ?

មណី នៅស្ងៀមមិនព្រមឆ្លើយ មានតែទឹកភ្នែកនាងទេ ហូរស្រក់ចុះមកវិញ១ជាចម្លើយយ៉ាងច្បាស់ បញ្ជាក់ឱ្យប្រមុខគេហដ្ឋានដួងតារាយល់ថា មណី នារីកំសត់ព្រាត់ឪពុកម្តាយត្រូវអ្នកណាម្នាក់ នៅក្នុងផ្ទះនេះធ្វើបាបនាង ហើយអ្នកនោះក៏គ្មានអ្នកណាក្រៅពីលោកស្រី ភរិយាលោកជាដាច់ខាត ។

-មណី ! ក្មួយឆ្លើយប្រាប់ខ្ញុំឱ្យត្រង់មក អ៊ុំស្រីឯងគេវាយធ្វើបាប មែនទេ ? ម្តេចក៏ក្មួយនៅស្ងៀម ទឹកភ្នែកក្មួយគឺជាទឹកភ្នែកអ៊ុំ ! តើក្មួយ ធ្វើអ្វីខុសបានជាគេធ្វើទារុណកម្មក្មួយដល់ថ្នាក់នេះ ?

មណី សែនតានតឹងក្នុងដួងចិត្ត នាងលូនទៅឱបបាតជើង អ្នកមានគុណ ទឹកភ្នែកកម្តៅឧណ្ហពីរតំណក់ស្រក់លើជើងលោក ឧច-ស៊ីផាន់ ប្រៀបបាននឹងទឹកក្រុត ធ្វើឱ្យលោកឧត្តមមន្ត្រីកាន់តែខ្លោចផ្សា រកាំដួងចិត្តនឹកអាណិតនារីកូនកំព្រាកាន់តែខ្លាំងឡើង១

-មណី ! អុំយល់ចិត្តថ្លើមក្មួយហើយ បានជាក្មួយមិនហ៊ាន និយាយការពិត ព្រោះក្មួយខ្លាចគេធ្វើបាបនៅពេលដែលអុំទៅធ្វើការបាត់ពីផ្ទះ ....

លោកឧច-ស៊ីផាន់ យកដៃទៅអង្អែលក្បាលនារីកំសត់បន្តិច១ ដោយសេចក្ដីស្រឡាញ់ និងអាណិតមេត្តា ... រួចហើយលោកក៏មានប្រសាសន៍ថា :

-កាលខ្មោចសែមឪពុកក្មួយនៅរស់ សែមមានគុណលើគ្រួសារអុំច្រើនណាស់ ! លុះ សែមស្លាប់ កូនសែមក៏ត្រូវទទួលអំពើទារុណកម្មគ្រប់ បែបយ៉ាងពីគ្រួសាររបស់អុំ ជាកិច្ចតបស្នងសងគុណទៅវិញ !

មណី សែនស្រឡាញ់សែនគោរព នឹងមធុរសវាចារបស់លោក ឧច-ស៊ីផាន់ ។ ក្នុងផ្ទះនេះបើគ្មាន លោកឧច-ស៊ីផាន់ គ្មានរូបសត្យាបុរស កំពូលស្នេហ៍ ម្ល៉េះនាងរត់ចេញបាត់ទៅហើយ តែនាងទ្រាំទ្ររស់យ៉ាងវេទនាបាន ក៏ដោយសារទឹកចិត្តមេត្តាធម៌របស់លោកឧច-ស៊ីផាន់ សេចក្ដីឈឺចាប់ទាំងប៉ុន្មាន ហាក់រលាយខ្សោកចេញអស់ពីអង្គប្រាណ កាលបើបានឮសំដី លោក ឬ សំដីសត្យាប្រុសបណ្ដូលចិត្ត ។

មណី ឱបជើងលោកឧច-ស៊ីផាន់ យំម្ដងទៀត ទំរាំនាង ដាច់ចិត្តជំរាបទៅលោកថា :

-ក្មួយធ្វើខុស ក្មួយត្រូវតែទទួលទោស ! លោកអុំស្រីវាយនេះ ក៏ដើម្បីឱ្យក្មួយចេះដឹងប៉ុណ្ណោះ មិនមែនដុះចេញពីគំនិតស្អប់គុំគួនអ្វីទេ លោកអុំ ... ក្មួយអាចទ្រាំបានគ្រប់យ៉ាងទាំងអស់ទោះជាត្រូវទទួលការ លំបាកច្រើនជាងនេះម្ដេចក្ដី ...

-ហ៊ឺ ... ! ពិបាកណាស់ ! (លោកឧច-ស៊ីផាន់ដកដង្ហើមធំ) អុំ លួមដឹងរឿងរ៉ាវខ្លះ១ហើយពាក្យក្មួយនិយាយមកប៉ុន្មានសុទ្ធ តែជាពាក្យ មិនពិតទាំងអស់ ! .... ទោះជាយ៉ាងណាក៏ដោយ អុំត្រូវតែរកឫសគល់ រឿងនេះឱ្យទាល់តែឃើញបណ្ដោយឱ្យគេវាយធ្វើបាបរាល់ថ្ងៃ ដូចសត្វធាតុឥចឹងមិនកើតទេ ឡើងទៅគេងលើគ្រែវិញទៅក្មួយ បន្តិចទៀតអុំនឹងទូរសព្ទអញ្ជើញលោកគ្រូពេទ្យឱ្យគេមកព្យាបាល ។

ពោលចប់ លោកឧច-ស៊ីផាន់ ក៏ដើរតំរង់ទៅបន្ទប់ទទួលភ្ញៀវ ដែលលោកស្រីសេដ្ឋា និងកញ្ញា ភួង-ផល្លីន កំពុងអង្គុយបុកពោះ។

លោកឧត្ដមមន្ត្រី អង្គុយសាឡុងទល់មុខភរិយា ទឹកមុខក្រហមងាំងដោយភ្លើងទោសៈ លោកសម្លឹងមើលមុខលោកស្រីមួយសន្ទុះ ទើបសួរថា :

-រឿងហេតុអ្វីបានជាអូនវាយមណី ទាល់តែស្ទើរស្លាប់ ស្ទើររស់ ឥចឹង ? វាមានធ្វើកំហុសអ្វីធ្ងន់រហួត អត់អធ្យាស្រ័យមិនបានឬ ? មណី ឈឺក្បាលឬ ក៏មណីត្រូវគេវាយបែកក្បាល ?

លោកស្រីសេដ្ឋា ខំលាក់អាការភិតភ័យ ធ្វើជានិយាយរបៀបធម្មតាថា :

-អត់ទោសឱ្យខ្ញុំផងប៉ាវ៉ា ....! ខ្ញុំខឹងខ្លាំងពេក ក៏វាយជ្រុលដៃ បន្តិចទៅ ... !

-ហា ! ហា ! ខឹងខ្លាំងវាយជ្រុល ! ហ៊ឺះ ! ខឹងអូនឯងមិនចេះអស់ ! រឿងវាយជ្រុលចេះតែជ្រុលរាល់១ថ្ងៃ ! តើថ្ងៃណាខែណាទៅទើបអូនឈប់ខឹងឈប់វាយជ្រុល ? ឬគិតវាយរបៀបនេះទាល់តែគ្នាស្លាប់ ? មនុស្សអូនគឺមនុស្សប្រកាន់វណ្ណៈ ! ប្រកាន់ពូជពង្ស ! យកលោកប្រាក់ធ្វើជាត្រីមុខ អូនភ្លេចអស់ហើយរឿងដើម កាលអូនឈឺ ដេកកន្ទេលនៅបាត់ដំបង បានអ្នកណាបើកឡាន ទាំងកណ្ដាលអធ្រាត្រទៅ ប៉ោយប៉ែតរកថ្នាំ ហើយអាសត្យាឈឺមិនព្រមបៅទឹកដោះគោ បានអ្នកណា ធ្វើមេដោះ ? មិនមែននាយសែមអ្នករឿន ឪពុកម្ដាយមណីទេឬ ? ចុះឥឡូវម្ដេចក៏អូនឆាប់ភ្លេចរឿងអស់ហ្នឹងម្ល៉េះ ?

លោកស្រីសេដ្ឋា នៅស្ងៀមឱនមុខចុះ ។

លោកឧច-ស៊ីផាន់ ក្រោកឈរក្រពាត់ដៃដើរទៅមាត់បង្អួចមើល អ្នកបំរើកំពុងកាប់គាស់ដីដាំផ្កាក្នុងសួន ។ មួយស្របក់ធំ លោកដើរមក ឈរទល់មុខអ្នកទាំងពីរ ហើយមានប្រសាសន៍ :

-បងសូមប្រាប់ម្ដងទៀតជាលើកចុងក្រោយបំផុត ចាប់តាំង ពីថ្ងៃនេះទៅត្រូវឈប់ធ្វើបាបមណី បើសិនជាអូននៅមិនព្រមស្ដាប់ហ្នឹង ហើយចាស់១ត្រូវឈ្លោះគ្នាម្ដងហើយ !

មានប្រសាសន៍ចប់ លោកឧច-ស៊ីផាន់ ក៏ដើរចេញទៅក្រៅ ។ ក្នុងបន្ទប់ទទួលភ្ញៀវនៅសល់តែលោកស្រីសេដ្ឋានិង កញ្ញាផល្លីន អង្គុយ សម្លឹងមើលមុខគ្នាភ្លឹះៗនឹកតូចចិត្តឆ្អិតឆ្អូងតែពីរនាក់ ។

.........................................................................................................

រាត្រីស្ងាត់ ...

កញ្ញារត្ន-មណី ដេកទទូរភួយដៃជើងញ័រទ្រើតៗ ខ្លួនប្រាណ មុខមាត់ក្តៅងំដូចរងើកភ្លើង ។ អាការរោគគ្រុនក្តៅបណ្តាលមកពីនាង ត្រូវលោកស្រីសេដ្ឋាវាយដំកាលពីព្រឹកម៉ិញជាទម្ងន់នេះឯង ។

នារីកំសត់ ខំមាត់អត់ធ្មត់ទប់នឹងសេចក្តីឈឺចាប់មិនហ៊ានស្រែក ថ្ងូរ ឬប្រាប់អ្នកណាឱ្យគេដឹងឡើយ ។ នៅខាងក្រៅផ្ទះរាត្រីខាងរនោច ប្រាសចាកពន្លឺចន្ទ មានតែពន្លឺផ្កាយព្រិចៗចោលកំទេចរង្សីឆ្លុះចាំងមកផែន ពសុធា តែក៏មិនអាចកំចាត់បង់ស្រមោលអន្ធការដែលងងឹតរកមើលទិស តំបន់អ្វីមិនឃើញ ឱ្យភ្លឺស្វាងដូចជា រាត្រីខាងខ្នើតបានឡើយ ។

ស្រមោលខ្មៅស្លុងមួយដើរងបៗមកក្រោមដើមផ្កាចំប៉ា រួចស្រាប់តែឡើងទៅលើបង្កាបមែកដែលទេទៅរកបង្អួច លោតចូល បាត់ទៅក្នុងបន្ទប់នាង មណី ។

មណី ឮសូរសិរបជើងមនុស្ស នាងប្រញាប់ទាញភួយពីមុខ ចេញរៀបនឹងស្រែក តែក៏ត្រូវអាក់ខាន ។

-អូ ! បងសត្យា !

-អូនមណី !

មណី ប្រឹងទប់ខ្លួនបំរុងក្រោកអង្គុយ តែត្រូវសត្យាចាប់ផ្តេកឱ្យគេងដូចដើមវិញ ។

-មិនបាច់ក្រោកទេអូន ! បងដឹងរឿងពីមីងចន្ទអស់ហើយ បានជា បងខំស្កាត់ចូលមកជួបអូនទាំងយប់អធ្រាត្រ ....

សត្យា ស្ទាបមុខសង្សារ ហើយក៏គ្រវីក្បាលដកដង្ហើមធំដោយក្តីអាណិត ។

-ខ្លួនប្រាណមុខមាត់អូនក្តៅណាស់ ! អូនប្រហែលជាគ្រុនខ្លាំង ហើយ ហ៊ឺ ! ម៉ាក់បងមិនគួរចិត្តអាក្រក់ឃោរឃៅ ធ្វើបាបអូនដល់ម្លឹង សោះ ... !

មណី ខំប្រឹងញញឹមប្រលោមចិត្តប្រុសស្នេហ៍

-កុំបារម្ភអីបង ...! គ្រុនក្តៅបន្តិចបន្តួច ស្អែកមុខជា ជាដូច ធម្មតាវិញទេ ... អា ...! បងសត្យា ចាំ ? សូមបងប្រញាប់ត្រឡប់ទៅបន្ទប់បងភ្លាមទៅ ! គ្រោះអាក្រក់អាចកើតឡើង បើប្រសិនជាលោកអុំ មកឃើញយើងក្នុងសភាពដូច្នោះ អូនមុខជាត្រូវមានទោសទៀតពុំខានឡើយ ....

-មិនថ្វីទេ មណី អូន....! ថ្ងៃនេះប៉ាម៉ាក់ លោកសំរាន្តលក់ អស់ហើយ បើទុកជាលោកមកទាន់ បងក៏គ្មានកោតញញើតនឹងសារភាពការពិតជំរាបលោកដែរ បងបានសំរេចចិត្តរួចជាស្រេចថា ត្រូវតែជំរាបរឿង យើងដល់លោកក្នុងកាលៈទេសៈណាមួយខាងមុខនេះ!...

-មិនបានទេបងសត្យា ! (មណីបែរទឹកមុខស្លឹតស្លាំង)អូនជឿ ជាក់ថា លោកអុំប្រាកដជាមិនព្រមឱ្យបងមករៀបការ នឹងអូនជាដាច់ខាត ... ! ណាមួយទៀត បងក៏ជិតរៀបការជាមួយ ផល្លីនទៅហើយ សូមបងរៀបការជាមួយគេទៅចុះកុំកែប្រែគោលគំនិតរបស់លោកអុំណា បងណា ! ជាតិនេះអូន និងបងមានភ័ព្វសំណាងស្នេហាគ្នាត្រឹមតែចិត្ត នឹងចិត្តប៉ុណ្ណោះ ! ធ្វើម្តេចអូនជានារីវេងកម្ម ! នារីអភ័ព្វក្តីស្នេហ៍ !

និយាយចប់ ទឹកភ្នែករីងហួតហែងកាលពីថ្ងៃ ក៏ហូរហៀរចេញ មកម្ដងទៀត ។ សត្យាអាណិតសង្សារខ្លោចថ្លើមប្រមាត់ អ្នកលើកត្រកង ប្រាណដ៏ល្វតល្វន់ យកឱបផ្ទប់ផ្ទាំងឱរា ឱនថើប ភ្នួងថ្ពាល់ដែលប្រឡាក់ ទៅដោយតំណក់ទឹកភ្នែកកម្ម ហើយនិយាយលួងលោមថា :

-ជាតិនេះបង និងផល្លីន គ្មាននិស្ស័យជាប្ដីប្រពន្ធគ្នាទេ ! ព្រឹក ស្អែកបងនឹងជំរាបប៉ាម៉ាក់ ឱ្យគាត់បោះបង់គំនិតនេះចោលចេញ បើគាត់ មិនព្រម បងក៏មិនខ្វីនៅរស់ក្រោមដំបូលផ្ទះនេះដែរ យើងស៊ូប្ដូរ ស្លាប់រស់ជាមួយគ្នាណាអូន !

-តែអូនមិនចង់ឱ្យបងធ្វើដូច្នោះ ! បងគិតមើលមើល៍ បើផល្លីន ដឹងថា បងប្រកែកមិនព្រមរៀបការជាមួយនាង តើនាងត្រូវខូចចិត្តយ៉ាងណា ? ហើយកិត្តិយសត្រកូលសារបង វាមិនត្រូវអាប់ឱនដោយសាររូបអូនម្នាក់ទៅហើយឬ ?

-គិតច្រើនព្រួយច្រើនទេអូន មណី ! ភារៈទាំងនេះបងត្រូវទទួលខុសត្រូវលើរូបអូនទាំងអស់ ប៉ាម៉ាក់ទៅស្ដីដណ្ដឹងផល្លីនឱ្យបង ក៏បងមិនទាន់បានឆ្លើយថា យល់ព្រមឬយ៉ាងណានៅឡើយ ដូច្នេះកំហុសមិនព្រមរៀបការក៏មិនមែនខ្លួនបងត្រូវទទួលដែរ ... អូន មណី !

-ចាំះ បង ...!

-បងសូមសួរចិត្តអូនទៀតចុះ ...! តើអូនស្រឡាញ់បងទេ ?

-ម្ដេចក៏បងចាំសួរដូច្នេះ ! សព្វថ្ងៃបើគ្មានរូបបងម៉្លេះសមអូនរត់ចេញពីផ្ទះនេះយូរហើយ អូនទ្រាំរស់នៅបានទាំងវេទនា ក៏ដោយសារតែមានបងជាពន្លឺនៃជីវិត ...!

សត្យា ឱនថើបថ្ពាល់សង្សារកំសត់ម្ដងទៀត ។ នរៈនៅអង្គុយកំដរមណី ទាល់តែយាមបី ទើបត្រឡប់មកកាន់បន្ទប់ខ្លួនវិញ ។

-៤-

## បែកការណ៍ដោយសារមានផ្ទៃ

| | |
|---|---|
| កូនប្រុសប្រកែកមិនព្រមការ | ព្រោះមានសង្សារត្រូវនិស្ស័យ |
| ឪម៉ែខឹងណាស់ខ្មាស់ខាងស្រី | ហៅកូនជេរស្ដីដៀលឆ្កែឆ្មា ។ |
| កម្មពារវេរាមិនចេះអស់ | ផ្គន្ទាស្រីស្រស់ស្ទើរមរណា |
| រឿងស្នេហ៍ខំលាក់ច្រើនមាសា | ស្រាប់តែបែកការណ៍ដោយសារផ្ទៃ ។ |

ព្រឹកស្អែកឡើង នាយឌុច-សត្យា ក៏ចូលទៅជួបលោក ឌុច-ស៊ីផាន់ លោកស្រីសេដ្ឋា នៅក្នុងបន្ទប់ផ្ទាល់ខ្លួនរបស់លោក ។ យុវជនបាននិយាយរ៉ាយរ៉ាប់សព្វគ្រប់អំពីហេតុដែលខ្លួនមិនទាន់ចង់មានប្រពន្ធ ហើយ ជាពិសេសមិនពេញចិត្តចំពោះកញ្ញា ភួង-ផល្លីន ។

ដូចយកប្រេងសាំងរាប់រយធុង ទៅចាក់កណ្ដាលគំនរភ្លើង លោកឌុច-ស៊ីផាន់ និងលោកស្រីសេដ្ឋា ខឹងកូនកម្លោះដាច់ក្បាលដាច់កន្ទុយ ។ លោកប្រមុខគេហដ្ឋាន ចង្អុលមុខសត្យា ស្រែកជេរប្រទេច ផ្ដាសាខ្លាំង១គ្មានលាក់កេរ្ដិ៍ខ្មាស់ថា :

-អាសត្យា ! អាកូនលក់កិត្តិយសវង្សត្រកូល ! ឯងទៅរៀនដល់ បរទេស តែឯងគ្មានចេះប្រើសតិសម្បជញ្ញៈតិរិះបន្តិចសោះ ឯងថោកជា ជាងឆ្កែឆ្មាទៅទៀត អញខំដណ្តឹងកូនក្រមុំគេអ្នកមានមុខមានមាត់ទុកឱ្យ ស្រាប់តែជិតដល់ថ្ងៃរៀបការឯងប្រកែក មិនព្រមយកឯងធ្វើដូច្នេះ ឯងយកកាំភ្លើងមកបាញ់ទំលុះទ្រូងអញឱ្យស្លាប់ប្រសើរជាង ! នេះជាកតវេទិការសងគុណរបស់ឯងមកអញដែលខំចិញ្ចឹមលាងអាចម៍ប្រចាច់នោមឯងតាំងពីតូចមក ?

សត្យា មិនទាន់បានឆ្លើយតបបង្ហាញហេតុអ្វី ទៅលោកឌុច-ស៊ីផាន់វិញផង លោកស្រីសេដ្ឋាក៏រះសំដីរ៉ាវដូចគ្រាប់ភ្លៀងមកទៀត :

-អាកូននិរគុណ ! អាកូនបង្អាប់មុខឪពុកម្តាយ ! ទៅ ! ទៅ យកកាំបិតមកចាក់សម្លាប់អញឱ្យហើយទៅ ! អញពីរនាក់ប្តីប្រពន្ធខំទៅសំពះអង្វរស្តីដណ្តឹងកូនគេ ទំរាំតែបានស្ទើរស្លាប់ស្ទើររស់ ! ឥឡូវមួយភ្នំពេញគេដឹងឮអស់ទៅហើយ បើអាឯងប្រកែកមិនព្រមរៀបការ តើឱ្យអញ ក្បាលកញ្ចាស់ពីរនាក់ប្តីប្រពន្ធយកមុខទៅទុកដាក់ឯណា ? កូនក្រមុំគេមិនមានស្នាមមន្ទិលជាស្រីមេម៉ាយខាន់ស្លាដោយសារតែឯងហើយឬ ? ហ៊ឺះ ! បើឯងនៅតែជជេសរឹងក្បាល ឯងត្រូវតែដើរចេញពីផ្ទះអញភ្លាម ! យើងលែងរាប់គ្នាជាកូនជាឪម៉ែអ្វីតទៅទៀត ពេលអញឈឺស្លាប់ ឯងក៏មិនបាច់ មកកាន់ឆ្អឹងអញដែរ !

-ម៉ាក់ ប៉ា ... ! ខ្ញុំដឹងហើយថា ម៉ាក់ប៉ាត្រូវខូចបង់កិត្តិយស ! បង់ពាក្យសំដីដោយសារតែរូបខ្ញុំម្នាក់ តែពេលនេះឱ្យខ្ញុំសុំទោសទៅចុះ .... កាលប៉ាម៉ាក់ ទៅស្តីដណ្តឹងនាងផល្លីនឱ្យខ្ញុំក៏ខ្ញុំមិនបានដឹងជាមុន ពីព្រោះពេលនោះខ្ញុំនៅសិក្សាឯប្រទេសបារាំង លុះដល់មកម៉ាក់ប៉ាកំណត់ថ្ងៃរៀបការទៀត ខ្ញុំក៏នៅតែគ្មានដឹងខ្លួនអ្វីទាល់តែសោះ ! មនុស្សម្នាក់ៗត្រូវស្វែង រកសេចក្តីសុខក្នុងជីវិតអាពាហ៍ពិពាហ៍ស្ថិតនៅលើការបង្ខិតបង្ខំចិត្តឬ ? ហើយបើសិនជាខ្ញុំចេះតែព្រមរៀបការជាមួយនាងផល្លីន ទាំងមិនពេញចិត្តថ្ងៃក្រោយមានរឿងទាស់ទែងបាក់បែកគ្រួសារទៅ តើអ្នកណាហ៊ានចេញ មុខមកទទួលខុសត្រូវក្នុងរឿងនេះ តាមខ្ញុំយល់គ្មានអ្នកណាក្រៅពីរូបខ្ញុំ ម្ចាស់សាម៉ីខ្លួនទេ ដូច្នេះគួរតែម៉ាក់អាណិតបើកសិទ្ធិឱ្យខ្ញុំមានអំណាចក្នុងការរើសមិត្តរួមជីវិតដោយខ្លួនឯងផង ។

លោកឌុច-ស៊ីផាន់ ហាក់ដូចជាស្តាប់ពាក្យពន្យល់សមហេតុសមផលរបស់កូនបាន លោកក៏ស្រាយកំហឹងនៅស្ងៀម។ ចំណែកលោកស្រី សេដ្ឋា ជាមនុស្សប្រកាន់វណ្ណៈដូចអស់លោកអ្នកជ្រាបស្រាប់មកហើយ ក៏រឹតតែមោហោទោសោកាន់តែខ្លាំង ។

-ឯងមិនចាំបាច់ប្រដៅម៉ែទេ ! អញក្បាលកញ្ចាស់ប៉ុណ្ណឹង អញ ទៅរកប្រពន្ធឱ្យឯងខុសឬ ? កូនគេអ្នកមានមហាសម្បត្តិដូចផល្លីន អញ មើលមិនឃើញមានកន្លែងណាគួរឱ្យភិតភ័យទៅថ្ងៃក្រោយសោះ។

-សេចក្តីសុខសុភមង្គលរវាងប្តីប្រពន្ធ មិនមែនកើតឡើង ដោយសារមាសប្រាក់ទេម៉ាក់ រឿងរៀបការជាមួយផល្លីនខ្ញុំសូមប្រកែកមិនព្រមជាដាច់ខាត បើម៉ាក់ស្រឡាញ់ខ្ញុំជាកូន សូមម៉ាក់អាណិតជូនពាក្យទៅគេ វិញទៅ !

-ទេ ! ទេ ! អញធ្វើតាមក្បាលចិត្តឯងមិនកើតទេ ! ឯងត្រូវតែរៀបការជាមួយផល្លីន បើឯងមិនយល់ព្រម ឯងត្រូវដើរចេញឱ្យផុតពីផ្ទះ អញ

-បាទ ! តាមចិត្តម៉ាក់ចុះ បើម៉ាក់បណ្តេញខ្ញុំៗក៏ត្រូវតែដើរចេញ ខ្ញុំសូមលាហើយម៉ាក់ !

ថាហើយ សត្យាក្រោកឈររៀបដើរចេញ លោកស៊ីផាន់ ក៏បក់ដៃ ឱ្យអង្គុយចុះវិញ ។

តាមពិត លោកប្រុស លោកស្រីស្រឡាញ់កូនណាស់ លោកមិនដាច់ចិត្តបណ្តេញកូនចុះចេញពីផ្ទះ ដោយសារតែរឿង ប្រកែកមិនយកប្រពន្ធទេ តែនេះមកពីលោកស្រីក្តៅជ្រុលក៏ចេះតែថាៗឱ្យផុតពីមុខពីមាត់ ទៅ ។

-សត្យាកូនសម្លាញ់ឪពុក ! (លោកស៊ីផាន់និយាយ)ឪពុកគ្មាន កូនពីរបីឯណាក្រៅពីរូបឯងឡើយ ប៉ាក្តីម៉ាក់ឯងក្តីដែលខំដេរស្តីប្រដៅឯង នេះ ក៏ដើម្បីចង់ឱ្យឯងមានសេចក្តីសុខទៅអនាគត ឯងត្រូវនៅក្នុងផ្ទះនេះ តទៅទៀត ចំណែករឿងរៀបការ ប៉ានឹងសូមពន្យាពេលគេទៅឆ្នាំក្រោយ ឥឡូវប៉ាអស់ការនិយាយហើយ ឯងត្រឡប់ទៅផ្ទះវិញចុះ ។

ឌុច-សត្យា ក្រោកដើរចេញពីបន្ទប់លោកប្រុស លោកស្រី ដោយ មានទឹកមុខស្រពាប់ស្រពោន ។

លោកឧុច-ស៊ីផាន់ អង្គុយបៀមខ្សៀបង្គុយផ្សែងអស់ពេលមួយសន្ទុះធំ លោកក៏មានប្រសាសន៍មួយៗ ទៅកាន់លោកស្រីជាភរិយាថា:

-ម៉ាក់វាឯងអំបាញ់មិញក្តៅជ្រុលពេក ! ...ក្មេងសម័យឥឡូវ យកកំហែងទៅទល់កំហាល់មិនបានទេ យើងត្រូវសន្សឹមៗលួងលោមវាទៅប្រហែលជាមានផ្លូវខ្លះ ហ៊ឺ ! ថាមានកូនស្រីទៅវ៉ាវាពិបាក មានកូនប្រុស ដណ្តឹងប្រពន្ធរៀបការឱ្យវាក៏នៅតែពិបាកទៀតអាសត្យាប្រហែលជាវា លួចស្រឡាញ់កូនគេឯណាទេដឹង ?

សមនឹងគំនិតលោកស្រីសេដ្ឋាគិតទុក លោកស្រីក៏មានប្រសាសន៍ យល់ស្របតាមប្តីថា :

-វាប្រាកដណាស់ទៅហើយបងអើយ ! ធម្មតាស្រមោច និង ស្ករ ប្រុសនិងស្រីមិនដែលព្ទស្អប់ខ្ពើមគ្នា អាសត្យាមិនព្រមរៀបការជាមួយក្មួយ ផល្លីន ក៏មកពីវាមានជាប់ចិត្តស្រឡាញ់ស្រីណាផ្សេងទៀត ហើយស្រីនោះ បើតាមយោបល់ខ្ញុំមិននរណាក្រៅពីនាង មណីឡើយ!....

លោកឧុច-ស៊ីផាន់ បើកភ្នែកធំៗទ្រង់ភ្ញាក់ :

-យី ! ម៉េចអូននិយាយឥចឹង ! បងជឿជាក់ថាស្រី ដែលសត្យាស្រឡាញ់មិនមែនរូបមណីជាដាច់ខាត សព្វថ្ងៃវារាប់អានមណីតាមដែល បងសង្កេតមើលទៅ ក៏រាប់អានក្នុងឋានៈជាបងប្អូនទេតើ ?

-មនុស្សគេមិនឱ្យទុកចិត្តមនុស្សទេបង ! បងទៅធ្វើការបាត់ៗ ម្តេចនឹងដឹងរឿងរ៉ាក់ជ្រៅដូចខ្ញុំអ្នកនៅផ្ទះ ខ្ញុំនឹកសង្ស័យមកយូរហើយ តែមិនហ៊ានបង្ហើបមាត់ជំរាបបង ពីព្រោះខ្ញុំដឹងថាបងស្រឡាញ់ មណី ទោះជាខ្ញុំនិយាយទៅក៏គ្មានបានលទ្ធផលអ្វីដែរ ! ....

-ឈប់ ! (លោកស៊ីផាន់រាំងដៃនឹកខឹងភរិយា) អូនឯងឈប់និយាយសំអុយពីមណីទៀតទៅ ! បងដឹងហើយថា អូនស្អប់ មណី ចង់កំចាត់គ្នាឱ្យឃ្លាតចេញពីផ្ទះនេះរាល់តែថ្ងៃ ! អាសត្យាវាបានរៀនសូត្រចេះដឹងជ្រៅជ្រះដែរ វាគង់មិនប្រព្រឹត្តដូចអូនយល់ឡើយ ! យើងមុននឹងនិយាយអ្វីត្រូវឱ្យមានសេចក្តីយុត្តិធម៌នៅក្នុងខ្លួនផង យកកំហឹងយកចិត្តឈ្នានិះមកធ្វើជាការពិតម្តេចកើត បងមិនចូលចិត្តមនុស្សដូចអូនទេ ! រាល់តែលើកដែលបងហៅអូនមកពិភាក្សា ទោះជានិយាយរឿងអ្វីក៏ដោយចុងចប់ត្រូវតែពាក់ព័ន្ធមកដល់រូប មណី ហើយ ទម្លាក់ទុក្ខទោសឱ្យគ្នាទទួលខុស ជានិច្ច !

ដោយអំណាចខឹងខ្លាំង យល់ថាលោកស្រីសេដ្ឋានិយាយសំអុយ បង្ខូចកេរ្តិ៍មណី លោកឧុច-ស៊ីផាន់ ក៏ក្រោកដើរចេញពីបន្ទប់តំរង់ទៅរោង ទុកឡាន បញ្ឆេះម៉ាស៊ីនបើកចេញទៅក្រៅទាំងអារម្មណ៍ហួហ្វង ។

នៅក្នុងលោកនេះ ព្រះព្រហ្មលិខិតហាក់ដូចជាអយុត្តិធម៌ ចំពោះ ជោគវាសនា មណី នារីកំសត់ណាស់ ទុក្ខហើយថែមទុក្ខទៀតផ្ទួនៗលើគ្នា គ្មានស្រាកស្រាន្ត តើជាតិមុន មណីបានកសាងអំពើបាបកម្មអ្វីបានជាជាតិ នេះនាងជួបប្រទះតែទុក្ខសោកវេទនាគ្រាំគ្រាដួងចិត្តដូច្នោះ ។

ឥឡូវវត្ត-មណី នាងមានផ្ទៃពោះបានបួនខែ អាការរោគចាញ់កូនចេះតែធ្វើទុក្ខនាងរាល់ថ្ងៃ ដូចជាវិលមុខ ក្អួតចង្អោរ ចង់ឱ្យស៊ីម្ជូរហើយ ចេះតែហត់អស់កម្លាំងខ្យល់ចាប់ជាញឹកញាប់ ។ នារីកំសត់ខំលាក់រឿងអាថិកំបាំង មិនហ៊ានប្រាប់ឱ្យអ្នកណាដឹងក្រៅពីសត្យាម្ចាស់ដួងចិត្ត និងមីងចន្ទ អ្នកធ្វើបាយ ដែលតែងតែមានមេត្តាធម៌មកលើរូបនាងឡើយ ។

កម្មអកុសល ... ! មិនយូរមិនឆាប់ដំណឹង មណី មានផ្ទៃពោះ ក៏ជ្រួតជ្រាបទៅដល់ត្រចៀកលោកស្រីសេដ្ឋា ។ លោកស្រីក្តៅណាស់ប្រើក្មេង បំរើឱ្យទៅហៅមណីមកសាកសួរមួយរំពេច

-ម៉េចមីមណី ! មីស្រីចង្រៃឧត្បាត ! ង៉ែងទៅផើមជាមួយអ្នក ណាហ្នាមីចង្រៃ !

មណី មិនហ៊ានសារភាពការពិត នាងសុខចិត្តតែលុតក្រាបសំពះ បាទជើងលោកស្រីសេដ្ឋា សំរក់ទឹកភ្នែករាប់លានតំណក់ចេញមកពោរពេញ ទៅដោយសេចក្តីភិតភ័យវិតក្កមា ។

លោកស្រីចិត្តមារ ឃើញមណី នៅស្ងៀមស្ងាត់មិនវាចាដូច្នេះ ក៏ រិតតែឆាបឆេះភ្លើងកំហឹង ។ សមលោកស្រីស្អប់នាងសល់ពីមុនមកស្រាប់ ក៏ស្ទុះទៅវាយវាត់ទាត់ធាក់ចាប់ទាញសក់ទះ តប់ឥតមេត្តាត្រាប្រណី ។

-ឪប ! ឪប ! ឪប !

លោកស្រីតក់ខ្នងមណី ទាល់តែនាងទ្រមខ្លួនដួលដេកក្បែរជើង ស្រែកថ្ងូរសំដែងអាការចុកចាប់គួរឱ្យខ្លោចចិត្ត :

-អូយ ! អូយ ! ... អាណិតខ្ញុំផង លោកអុំ ... ខ្ញុំបានជាប្រព្រឹត្ត ខុសទៅហើយ .... អូយ !

-ង៉ែងកុំស្រែកមី មណី ! អញក្ដៅណាស់ មីសំផឹងសៅដៃ ថ្ងៃនេះ អញវាយង៉ែងឱ្យស្លាប់ ! ង៉ែងទៅសាហាយស្មន់ផើមជាមួយអាណា ! អា ណាជាប្ដីង៉ែងហ្ន ? ប្រាប់អញភ្លាមមក បើង៉ែងមិនចង់ឈឺសាច់ មីចោរ កំពូជខ្ញុំគេ !

មណីនៅស្ងៀមស្ងាត់ដដែលមិនព្រមឆ្លើយ ។

-ឪប ! ឪប ! ម៉េចក៏ង៉ែងមិនឆ្លើយ ! ឆ្លើយប្រាប់អញភ្លាមមក មីឃ្មី ! បើមិនឥចឹងអញអារកង៉ែងហុតឈាមទាំងរស់ឥឡូវហើយ !

មណី ទ្រាំទ្រនឹងអំពើទារុណកម្មរបស់លោកស្រីបានទាំងពិបាក នាងស្ទើរតែផុតដង្ហើមម្ដង១ តែទោះជាយ៉ាងនេះហើយក៏ដោយ នាងទ្រាំខាំ មាត់មិនព្រមប្រាប់ឈ្មោះអ្នកឱ្យកំណើតដល់បុត្រអភ័ព្វក្នុងផ្ទៃនាងជាដាច់ខាត ។

លោកស្រីសេដ្ឋា ចាញ់ចំណេះសាកសួរពីរឿងប្ដី ម្ល៉ោះហើយ លោកស្រីក៏គិតតែវាយរកចម្លើយការពិត ។ វាយផងធាក់ផងលុះត្រាមណី សន្លប់លែងដឹងខ្លួនប្រាណនៅក្បែរជើង ។ មុខមាត់ នារីកំសត់ ហើមជាំ បែកឈាមជាច្រើនកន្លែង ភ្នែកទាំងសងខាងហើមជិតស្ទើរបើកមិនរួច។ លោកស្រីដើរទៅដងទឹកយកមកជះកណ្ដាលមុខស្រីទុគិតឱ្យដឹងខ្លួន រួចហើយលោកស្រីក៏តាំងវាយធ្វើបាបឱ្យនាងឈឺចាប់រហូត សន្លប់បាត់ស្មារតីជាថ្មីម្ដងទៀត ។

ពេលនោះ លោកឧច-ស៊ីផាន់ និងសត្យា ក៏ត្រឡប់មកពីធ្វើការវិញ ។ ប្រុសកម្លោះគ្រាន់តែក្រឡេកឃើញមណីដួលដេកសន្លប់បែកឈាម ហើមពេញខ្លួនក៏ស្ទុះទៅលើកបិត្រកងមុខលោកស្រីសេដ្ឋា ដោយគ្មានកោតញញើត ។

-អូន មណី ! អូន មណី ! យី ! អូន មណីសន្លប់បាត់ស្មារតីទៅហើយ ម៉ាក់ ! ម្ដេចក៏ម៉ាក់កាចសាហាវធ្វើបាបគ្នាអីដល់ថ្នាក់នេះ តើមណី គ្នាធ្វើអ្វីខុសខ្លះ ?

លោកឧច-ស៊ីផាន់ ឃើញសត្យា ស្ដីគំហកឱ្យម្ដាយ ក៏ទៅជាភ្ញាក់ស្រឡាំងកាំងដោយមិនយល់រឿងហេតុ ។ លោកស្រីសេដ្ឋា មិនធ្លាប់ឮសំដីកូននិយាយគំរោះគំរើយដូច្នេះពីមុនមក ក៏មានកាយវិការមិនខុសពីស្វាមីប៉ុន្មាន តែលោកស្រី នឹកឃើញរឿងអ្វីម៉្យាង បែរទៅសង្សកឱ្យកូនវិញថា :

-យើ ! អាសត្យា ! អាកូនអត់ពូជ ! ឯងហ៊ានគំហកឱ្យអញផង តើមណីត្រូវជាអ្វីនឹងឯង បានជាឯងតក់ស្លុតអ្វីខ្លាំងម្ល៉េះ វាផើមអត់ប្ដីណ៎ា បានជាអញវាយ ! អញចង់ដឹងថា វាទៅដេកឱ្យអាណា យកឯងជាប្ដីវាឬ បានជាឯងកាន់ជើងវា ?

-អូស ! មណីផើម ?

លោកឧច-ស៊ីផាន់ភ្ញាក់ឧទានចេញមក។

-ចាស ! ត្រូវហើយ មណីក្មួយសម្លាញ់បងឯងផើម ! វាផើមអត់ប្ដីទៀត ម៉េចពេញចិត្តបងឯងទេ ?

លោកស្រីសេដ្ឋានិយាយដាក់ផ្លែឱ្យប្ដី។

មណី ភ្ញាក់ដឹងខ្លួន បើភ្នែកឃើញលោកឧច-ស៊ីផាន់ នាងប្រឹង ក្រោកលូនទៅរកលោក តែត្រូវសត្យាចាប់ជាប់។ នរៈ និយាយមាត់១ថា :

-អូននៅមិនទាន់ស្រួលខ្លួន មិនចាំបាច់ប្រឹងក្រោកទេ ! ពេលនេះ ការអាថិកំបាំងទាំងប៉ុន្មាន បងត្រូវតែនិយាយឱ្យឃើញសខ្មៅតែម្តងឱ្យ ហើយ !

សត្យា បែរទៅនិយាយរកឪពុក :

-លោកប៉ា ! កូនក្នុងផ្ទៃមណីគឺជាកូនរបស់ខ្ញុំ ! ហើយមណីនេះទៀត គឺជាប្រពន្ធដែលខ្ញុំស្រឡាញ់ពេញចិត្ត ! កំហុសទាំងប៉ុន្មានបណ្តាលមកពីរូបខ្ញុំ ! អូនមណី គ្នាគ្មានខុសអ្វីទេ បើប៉ាម៉ាក់ចង់វាយធ្វើបាបមណី សូមធ្វើបាបខ្ញុំវិញចុះ ខ្ញុំអាចទទួលទុក្ខទោសជំនួស មណីបានគ្រប់យ៉ាងទាំងអស់ ! ចំណែករឿងស្តីដណ្តឹងនាង ផល្លីន ខ្ញុំសូមជំរាបប៉ាម៉ាក់ឱ្យហើយថា ក៏មិនព្រមយកជាដាច់ខាត ពីព្រោះខ្ញុំមិនដឹងជាយកប្រពន្ធពីរបីម្តេចទេក្នុងជាតិនេះ ខ្ញុំមានប្រពន្ធតែមួយគត់ ប្រពន្ធនោះក៏គឺមណីនារីកំសត់ ដែលម៉ាក់វាយធ្វើបាបគ្នាជាងសត្វតិរិច្ឆាននេះឯង !

-ឃើញទេ ! ឮទេប៉ាវ៉ា ! ខ្ញុំនិយាយអីចេះខុសខ្ញុំប្រាប់មកយូរហើយថា ខ្ញុំបណ្តេញមីសត្វឃ្មើនេះចេញពីផ្ទះយើងទៅតែទ្រាំចិញ្ចឹមវាទុក យូរវាមុខជាធ្វើកិច្ចកលមាយាពាក់ព័ន្ធដល់រូបអាសត្យាជាពុំខានឥឡូវឃើញ ដូចពាក្យខ្ញុំនិយាយទាយទុកមុនហើយនៅ !

លោកស្រីសេដ្ឋាបែរទៅសម្លក់កូនប្រុស ព្រមទាំងខាកស្តោះដាក់ មុខមណី ហើយលោកស្រីក៏មានប្រសាសន៍តទៅទៀត

-កាលខ្ញុំនិយាយប្រាប់ប៉ាវ៉ាឯងពីមុន សុទ្ធតែថាខ្ញុំវ៉ាអាក្រក់ វ៉ាចិត្តឫស្យាច្រណែនឈ្នានិះ ឥឡូវឃើញច្បាស់នឹងភ្នែកហើយម៉េចសប្បាយចិត្តទេ បានកូនប្រសារខ្ញុំឯង ពីថ្ងៃនេះទៅគិតយកមុខមាត់ទៅទុកដាក់ឯណា មុខតែទទូរស្បែកឆ្កែទាំងអស់គ្នាហើយ ត្រកូលខ្ពង់តារា ! ...

លោកឧត្តមមន្ត្រី នៅស្ងៀមមិនហ៊ានឆ្លើយតប បិទមាត់ជិតដូចគេចុក ។ លោកមិននឹកស្មានថាហេតុការណ៍វ៉ានឹងប្រែក្លាយពីខ្មៅមកសដូច្នេះសោះ ។ លោកមិនស្អប់ខ្ពើមមណីទេ អនាគតកូនប្រសាររបស់លោក មានចរិយាសម្បត្តិសមសួន ដូចមណី លោកពេញចិត្តណាស់ទៅហើយ ត្រង់វណ្ណៈខ្ពស់ទាបមាន ឬ ក្រ លោកយល់ថាវាជាជោគវាសនារបស់មនុស្សម្នាក់ៗ ដែលកសាងពីអតីតជាតិមក ។ តែលោកនឹកខឹង នឹងសត្យាកូនប្រុសលោក ដែលកសាងអំពើបាបកម្មឱ្យមណី ត្រូវទទួលគ្រោះថ្នាក់ដោយសារខ្លួន ជាពិសេស លោកនឹកស្តាយដល់កិត្តិយសលោក ដែលខំទៅស្តីដណ្តឹងកូនក្រមុំគេទុកឱ្យនៅពេលដែលសត្យានៅសិក្សា ឯបរទេស ។

លោកឧច-ស៊ីផាន់ អង្គុយនឹងថ្កល់ស្ទើរមិនកំរើកខ្លួន អារម្មណ៍ លោកកំពុងអណ្តែកទៅកាន់ភពមួយដ៏សែនឆ្ងាយ។ លោកគិតហើយគិតទៀត លៃសរសៃសក់មួយជាដប់ចំរៀក តើលោកត្រូវបណ្តេញ មណី ចេញ ពីផ្ទះតាមកំហឹងភរិយាលោកឬ ? តើលោកអាចបដិសេធដុំឈាមក្នុងផ្ទៃ មណី ដែលបំរុងនឹងកើតរូបរាងមនុស្ស ហើយត្រូវជាចៅលោកក្នុងអនាគតខាងមុខនេះបានដែរឬ ? បញ្ហាស្មុគស្មាញ ចោទសួរក្នុងខួរក្បាលសោកឱ្យ វក់វល់ ពុលគំនិតគិតមិនឃើញ ទីបំផុតលោកក៏ដកដង្ហើមធំ និយាយទៅកាន់សត្យាទាំងអស់សង្ឃឹមថា :

-ហ៊ឺ ! រឿងនេះស្មុគស្មាញណាស់ ! ...ម៉េចសត្យា ! ចំពោះរូប មណី ឥឡូវឯងគិតយ៉ាងណាវិញ ?

សត្យាឆ្លើយ :

-បាទ ! លោកប៉ា ... ចំពោះអូនមណី ទោះជាអាក្រក់ល្អយ៉ាងណា គ្នាក៏ជាប្រពន្ធខ្ញុំរួចទៅហើយ គ្នាមានទាំងកូននៅក្នុងពោះដូចលោកប៉ាឃើញស្រាប់ ... ! ខ្ញុំបានអង្គុយគិតរួចជាស្រេចថា ត្រូវតែយកអូនមណី ធ្វើជាប្រពន្ធចាប់តាំងពីថ្ងៃនេះ ខ្ញុំមិនអាចបោះបង់វាសនានារីអភ័ព្វម្នាក់ ឱ្យខូចអនាគតដោយសារតែខ្ញុំឡើយ .... សូមលោក ប៉ា ...ម៉ាក់ ... អាណិត ! យោគយល់ដល់ចិត្តខ្ញុំ និង អូនមណីផង ... !

លោកឧច-ស៊ីផាន់ គ្រវីក្បាល បែរមកសួរយោបល់លោកស្រី :

-ម៉ាក់វ៉ាឯងគិតយ៉ាងម៉េច បើរឿងវាជ្រុលហួសមកដល់ថ្នាក់នេះ ទៅហើយ !

-ចុះប៉ាវ៉ាឯង ?

លោកស្រីសេដ្ឋាសួរមកប្តីវិញ ។

-យោបល់ខ្ញុំ ! ... បើយើងបណ្តេញ មណី ឱ្យចុះចេញពីផ្ទះ ពង្រាត់ពង្រាសគូសង្សារគេ តាមធមិព្រះយើងបាបធ្ងន់ណាស់ណា មួយគួរ អាណិតមណីដែរ គ្នាជាកូនកំព្រាឥតឪម៉ែ សព្វថ្ងៃរស់នៅរំពឹងតែលើយើង បើយើងបណ្តេញគ្នាទៀត តើឱ្យគ្នាទៅសង្ឃឹមអ្នកណា ? វរៗខូចចិត្តទៅ ជាចងក លោតទឹកសម្លាប់ខ្លួនឯងក៏មិនដឹង រឿងវាក៏កន្លងហួសមកដល់ ថ្នាក់នេះហើយ គួរតែយើង ....

លោកប្រមុខត្រកូលឌួងតារា មានប្រសាសន៍មិនទាន់ចប់ផង លោកស្រី ក៏ស្រែកវ៉ាវឡើងថា :

-មិនបាន ! មិនបាន ! ហ្អឹងប៉ាវាឯងចង់និយាយថា ឱ្យខ្ញុំយល់ព្រម ទទួលស្គាល់នាង មណីជាកូនប្រសារឬ ? ឱ ! ពុទ្ធោអើយ ពុទ្ធោ ! ខ្ញុំក្អួត ឈាមស្លាប់ឥឡូវហើយ យម្ភបាលនៅឯណាមកអូសកខ្ញុំម្នាក់ចុះក្នុងខ្ទះទង់ ដែងឥឡូវឱ្យហើយទៅ ខ្ញុំមិនចង់រស់នៅឱ្យជួប មុខមីឃ្មីទេ !

មានប្រសាសន៍ចប់ លោកស្រីសេដ្ឋា ក៏ក្រោកក្តោបមុខយំ រត់ចូល ទៅក្នុងបន្ទប់ ទាញទ្វារបិទមកវិញយ៉ាងខ្លាំង ។

លោកឌុច-ស៊ីផាន់ មើលទៅសង្សារទាំងពីរប្រាណពោរពេញទៅដោយសេចក្តីអាណិតមេត្តាធមិ ។ លោកមានប្រសាសន៍តិចៗ ល្មមតែស្តាប់ ឮគ្នាពីរនាក់ថា :

-សត្យា មណី ! ប៉ាមិនពង្រាត់ពង្រាសប្តីប្រពន្ធកូនទេ បើឯងទាំងពីរនាក់បានជាជ្រុលស្រឡាញ់គ្នាហួសទៅហើយ ក៏សូមឱ្យថែរក្សាគ្នារហូតដល់ចាស់ស្លាប់រៀងៗខ្លួនចុះ ! តែការល្អពេលនេះ ម្តាយឯងគេកំពុងខឹងខ្លាំង ឯងគួរនាំមណី ទៅរកជួលផ្ទះឱ្យនៅជាបណ្តោះអាសន្នសិនទៅ ទំរាំពេលណាម្តាយឯងគេបាត់ខឹងសម្បារ ចាំប៉ាជួយគិតឯងជាក្រោយទៀត ... !

មណី លូនទៅឱបជើងលោកស៊ីផាន់ យំននាក់ននាល ដោយមិន ចង់ចាកឃ្លាតឆ្ងាយ ។

សត្យាពេលនេះ ក៏មានទឹកមុខស្រពាប់ស្រពោន ធ្វើភ្នែករលីង រលោងរកកល់ចង់យំតាមមណីដែរ ។

លោកស៊ីផាន់ បែរមើលនាយអាយឃើញស្ងាត់ល្អ លោកក៏ឱនទៅ ខ្សឹបដាក់ត្រចៀកអ្នកទាំងពីរឮសូររអ៊ុសៗ ។ រួចហើយលោកក៏ក្រោកឈរ ស្រែកគំហកឱ្យមណីរបៀបក្រេវក្រោធថា :

-មីមណី ! ពីដើមអញស្មានថាហងល្អ អញឃើញហងកូនកំព្រា តោកយ៉ាកបានជាអញសុខចិត្តទទួលចិញ្ចឹម ស្រឡាញ់ដូចកូនចៅបង្កើត ! ឥឡូវម៉ែងបានផ្ទះធំទ្រទំនខ្ពស់ ម៉ែងហ៊ានមកស្រឡាញ់កូនអញ ដែលមានឋានៈខុសគ្នាមេឃនិងដី ចុះពីផ្ទះអញភ្លាមទៅ មីឈាមឈ្លើង ! ម៉ែងកុំនៅឱ្យខូចកិត្តិយសអញតទៅទៀត ចំណែកអាសត្យាក៏ឥចឹងដែរ បើឯងចង់នៅលើផ្ទះនេះ ឯងត្រូវតែឈប់ទាក់ទងជាមួយមីមណី បើមិនដូច្នោះ ឯងនិងអញត្រូវអស់ឪកូនគ្នាត្រឹមណេះ ! ទៅ ! មីមណីរើតវ៉ាន់ ចុះចេញពីផ្ទះអញ ឥឡូវទៅណា៎ តែបន្តិចទៀតអញមកវិញនៅឃើញនៅដដែល គឺម៉ែងត្រូវស្លាប់ !

មានប្រសាសន៍ចប់ លោកឌុច-ស៊ីផាន់ ក៏ធ្វើជាដើរទន្ទ្រំជើងប៉ុង ! ប៉ុង ! ចេញទៅក្រៅបាត់ទៅ ។

នៅក្នុងបន្ទប់ លោកស្រីសេដ្ឋាកំពុងដេកយំសោកបោលខ្លួន នឹកក្រេវក្រោធនឹងមណី ។ លុះឮពាក្យស្តីបន្ទោសរបស់លោក ឌុច-ស៊ីផាន់ ស្រែកដេរបណ្តេញឱ្យមណីចុះចេញពីផ្ទះ លោកស្រី ក៏ត្រេកអរញញឹម ញញែមចេញមកម្នាក់ឯង ទាំងទឹកភ្នែកនៅហូរសស្រាំ ។

នេះជាឆាកកំប្លែងស្ងួតដែលលោកឌុច-ស៊ីផាន់ ដើរតួឯកជាលើកដំបូងបំផុតក្នុងជីវិតរបស់លោក ។

❀ ❀

❀

ជិតចេញផ្សាយទៀតហើយ !!
រឿង " **ឱ ! ផ្សែងមរណៈ** " របស់អ្នកនិពន្ធ
**ឃាក់ ឆៃហុក** ជាប្រលោមលោកមនោសញ្ចេតនា
នាអំឡុងទស្សវត្ស៦០ ពីបណ្ណាគារ " **អង្គរធំ** "ដដែល ។
ធានាថាល្អពិរោះរណ្តំ ក្នុងអារម្មណ៍យុវវ័យគ្រប់ៗរូប !!!

~៥~

## កំណាចវាសនា

| | |
|---|---|
| កំណាចវាសនាឫស្សាក្រៃ | ស្ទុះមកប្រល័យខ្សែជីវិត |
| គូស្នេហ៍រួមរស់ធ្លាប់ផ្តេកផ្ដិត | ឃ្លាតកាយឆ្ងាយចិត្តដាច់អាល័យ ។ |
| អាសូរមណីស្រីផ្ទៃពោះធំ | ដេកកើតទុក្ខធំដោយព្រាត់ប្តី |
| ស្រាប់តែម្តាយក្មេកចិត្តត្ថិរ្យ | វាយធាក់ធ្លាក់ដីស្មើរក្ស័យជន្ម ។ |

ឌុច-សត្យា បាននាំវត្ត-មណី ភរិយាក្រៅក្របខណ្ឌមកជួលផ្ទះ ឈើមួយនៅខាងក្រោយរោងចក្រធ្វើស្បែកជើងកៅស៊ូ ជីបតុង ទួលគោក ។ លោកឌុច-ស៊ីផាន់ មន្ត្រីចិត្តធម៌តែងលួចផ្តល់លុយកាក់តាមសត្យាឱ្យមកមណីជារឿយៗ ជូនកាលលោកទំនេរ លោកក៏លួច ឆ្លៀតពេលទៅលេងកូនប្រសារកំសត់ដោយខ្លួនឯង ។ លោកស្រី សេដ្ឋា អ្នកមានប្រកាន់វណ្ណៈមិនបានដឹងរឿងហេតុទាំងនេះក៏នឹកត្រេកអរ កាន់តែប្រចុបប្រចែង កញ្ញា ភួង-ផល្លីន អនាគតកូនប្រសារក្នុងការយល់សប្តិឱ្យស្និទ្ធិស្នាលខ្លាំងឡើងៗ ។ ព្រោះលោកស្រីឥតបានជ្រាបថា ប្តីលោកស្រី និងកូនប្រុសលោកស្រីលេង ត្លុកកំប្លែងល្ខោនក្រៅឆាកដាក់លោកស្រីឡើយ ។

ថ្ងៃនេះ ក្រោយពេលត្រឡប់មកពីធ្វើការសត្យាក៏ប្រញាប់ទៅជួប ភរិយាកំសត់របស់គេដូចសព្វមួយដងទៀត ។

គ្រាន់តែនរៈដើរចូលដល់ក្នុងផ្ទះ អ្នកក៏ភ្ញាក់ព្រើតដោយឃើញ មណី ដេកទទូរភួយលើគ្រែញាក់ញ័រដូចកូនសត្វ ។ សត្យាប្រញាប់ សួរភរិយា ទ្រង់តក់ស្លុតថា :

-អូនមណី ! អូនកើតអីហ្នឹង ?

មណី ខំប្រឹងញញឹមទាំងបបូរមាត់ស្លឹតស្លាំង ឆ្លើយតបមកស្វាមី វិញថា :

-ចាំ ! អូនគ្រុន ...តែសូមបងកុំបារម្ភ ជម្ងឺនេះមិនជាធ្ងន់ធ្ងរអ្វីទេ ពីរបីថ្ងៃទៀតអូនមុខជានឹងជាហើយ... !

សត្យា ដាក់គូថអង្គុយលើគ្រែយកដៃស្ទាបខ្លួនប្រាណភរិយា សម្លាញ់ដោយក្តីវិតក្ក ។

-ហ៊ឺ ! ខ្លួនអូនក្តៅណាស់ ! អូនកុំចាំបាច់លាក់បង បងដឹងហើយ ថាអូនមានជម្ងឺធ្ងន់ ចាំបងទៅអញ្ជើញ លោកគ្រូពេទ្យឱ្យគេមក ព្យាបាលអូន ណាំ !...

-កុំអីបង ! ជម្ងឺបន្តិចបន្តួចអូនអាចទ្រាំបាន មិនបាច់ទៅអញ្ជើញ លោកគ្រូពេទ្យមកទេ ....!

ការពិត មណី នាងឈឺបីបួនថ្ងៃមកហើយ តែនាងមិនដែលចេញ ស្តី ឬសំដែងឱ្យសត្យាដឹងថា នាងមានជម្ងឺឡើយ ។ ទាំងនេះមកពីនាងមិន ចង់ឱ្យគេកើតទុក្ខព្រួយបារម្ភអស់ប្រាក់កាសដោយសារតែរូបនាង ទើបតែ ថ្ងៃនេះអាការរោគគ្រុនញាំញីរាតត្បាតក្នុងរាងកាយនាងហួសវិស័យនឹងទ្រាំបាន តែទោះជាយ៉ាងនេះនាងក៏នៅប្រឹងលាក់ប្តីតទៅទៀត ។

សត្យា យល់ចិត្តប្រពន្ធ នរៈឱបមើបភួងថ្ពាល់ដែលក្តៅដូចរងើកភ្លើង ព្រោះឫទ្ធិគ្រុនក្តៅស្រាល១ព្រម ទាំងនិយាយលួងលោមនាងថា :

-បើអូនស្រឡាញ់ប្តីត្រូវតែធ្វើតាមប្តី !... អូនមានផ្ទៃពោះ ចាស់ខែផង ហើយមកមានជម្ងឺក្នុងខ្លួនដូច្នេះ បើអូនមិនព្រមឱ្យបងទៅអញ្ជើញលោកគ្រូពេទ្យមកព្យាបាលមិនមែនអូនធ្វើបាបតែខ្លួនឯងឯណា ! គឺអូនធ្វើ បាបដល់ទៅទារកក្នុងផ្ទៃដែលគ្នាមិនទាន់បានឃើញពន្លឺព្រះអាទិត្យទៀត ! ឱ្យបងទៅអញ្ជើញលោកគ្រូពេទ្យទៅណាអូនណា ! ...

-ចាំ ! តាមចិត្តបងចុះ ...!

មណី ឆ្លើយរួចនាងក៏ទាញដៃប្តីសម្លាញ់មកដាក់លើដើមទ្រូង ។ ស្រីកំសត់សប្បាយចិត្តណាស់កាលបើឃើញថាប្តីនាងពិតជាស្រឡាញ់នាងដោយសុទ្ធចិត្តឥតរង្កៀស ។ នាងញញឹមចេញមកដោយទឹកត្រេកអរសរសើរជោគវាសនាដែលព្រះព្រហ្មលិខិតចេះតម្រូវឱ្យមកជួបលើបុរសកំពូលស្នេហ៍យ៉ាងសត្យាប្តីនាង ។ នៅក្នុងលោកនេះ បើគ្មានរូបសត្យា ជីវិតនាងក៏មិនអាចរស់នៅតែឯកឯងបានដែរ សត្យាជាប្រទីបទិព្វសំរាប់ឆ្លុលបំភ្លឺខ្សែជីវិតអភ័ព្វនាងឱ្យមានសង្ឃឹមរស់នៅលើវាលលោកដ៏ធំធេងប្រកបទៅដោយការប្រែប្រួលគ្រប់កាលៈទេសៈនេះតទៅទៀត ។

អនិច្ចា ! វិមានសុខក្នុងមនោរម្យរបស់នាងស្ថិតនៅមិនបានប៉ុន្មាន ក៏រុញច្រានដួងចិត្តនាងឱ្យកើតទុក្ខព្រួយទៅវិញ នាងព្រួយព្រោះជោគវាសនា ជតាកម្មពេលខាងមុខ នាងមើលមិនឃើញ តើនាងអាចរួមរស់ជាមួយ សត្យារបៀបលួចលាក់ដូច្នេះ បានអង្វែងប៉ុន្មាន ? បើលោកស្រីសេដ្ឋា ស៊ើបសួររកឃើញដឹងថាកូនប្រុស លោកស្រី នៅទាក់ទងពាក់ព័ន្ធនឹងនាងនៅឡើយ តើលោកស្រីវាយដំធ្វើបាបនាងយ៉ាងណាទៅ ហើយជោគវាសនាបុត្រក្នុងផ្ទៃវានឹងត្រូវអណ្តែកឃ្លេងឃ្លោងកណ្តាលសមុទ្រទឹកភ្នែកយ៉ាងម៉េចទៅវិញ ? គិតឃើញច្រើននាងក៏កាន់តែព្រួយច្រើន ទីបំផុតទឹកភ្នែកក៏ត្រូវចេញមកប្រលោមលើផ្ទៃមុខនាងដូចជាពេលមុន១ដដែល ។

-មណី ! អូនយំឬ ?

សត្យាសួរ

-ចាំ ... បង ...!

-ម្តេចក៏អូនយំ ? ឬមួយអូនមានបើអាក់អន់ចិត្តអ្វីនឹងបង ? ប្រាប់បងមកអូនមណី ...

-ចាំ ! អូនឥតមានអាក់អន់ចិត្តអ្វីបងទេ ... ផ្ទុយទៅវិញអូនស្រលាញ់បង អូនសប្បាយចិត្តដោយឃើញបងយកចិត្តទុកដាក់នឹងអូនហួសការគួរ ទឹកភ្នែកនេះជា ទឹកភ្នែកសំដែងអំណរគុណចំពោះបងទេ...!

សត្យា យកដៃជូនទឹកភ្នែកភរិយាដែលកំពុងហូរប្រដេញចេញមកមិនឈប់ឈរ ។ អ្នកឱនថើបថ្ពាល់មណីម្តងទៀតរួចហើយទើបវាចាថា :

-កុំសូវគិតអ្វីឱ្យហួសពីការពិតពេកអូន ... ! សព្វថ្ងៃពិតមែនតែយើងទាំងពីរនាក់រស់នៅដោយលាក់កំបាំងពីភ្នែកអ្នកទាំងពួង តែយើងក៏មានឈ្មោះថា ជាប្តីប្រពន្ធនឹងគ្នាត្រឹមត្រូវតាមច្បាប់ធម្មជាតិហើយទេតើ ....!

-តែអូននៅបារម្ភខ្លាចម៉ាក់បងដឹង ... ! ពេលណាដែលម៉ាក់បង ជ្រាបថាអូននៅកន្លែងនេះ ពេលនោះសេចក្តីសុខរបស់អូនត្រូវរលាយជាផង់ធូលីហើយ ។

-មិនមែនដូច្នោះទេអូន ! ទោះជាយ៉ាងណា បងក៏ត្រូវពុះពារ តស៊ូនឹងឧបសគ្គគ្រប់យ៉ាង ដែលវានឹងកើតឡើងចំពោះមុខយើងទាំងពីរ ជានិច្ច ! ...

និយាយហើយ សត្យាក៏លើកភួយដណ្ដប់ឱ្យមណី ។ បន្ទាប់ពីនោះ អ្នកក៏ប្រញាប់ប្រញាល់បើករថយន្តទៅតាមលោកគ្រូពេទ្យឱ្យមកព្យាបាលភរិយាអ្នកជាបន្ទាន់ ។

ផលកម្មនៅតែតាមផ្ដន្ទាឈ្នានិះ ខ្សែវាសនានាងរត្ន-មណី ឥតស្រាកស្រាន្ត ។

លោកស្រីសេដ្ឋា បានជ្រាបដំណឹងពីលោកគ្រូពេទ្យសំកុល ដែលសត្យាអញ្ជើញទៅព្យាបាលជម្ងឺ មណី ថានាងនៅទួលគោក ហើយនៅជាប់ទាក់ទងនឹងសត្យាកូនប្រុសលោកស្រីនៅឡើយទេ។ លោកស្រីក្ដៅចិត្តស្ទើរហោះទៅទួលគោកស៊ីសាច់ហុតឈាម មណីទាំងថ្ងៃត្រង់ តែចិត្តមួយចូលមកឃាត់លោកស្រី ឱ្យទ្រាំរម្ងាប់ស្ងៀមសិនរង់ចាំពេលវេលាបានឱ្យនឹងទៅកំចាត់នាងឱ្យដាច់ដោចពីកូនប្រុសលោកស្រីមួយរំពេច ។

មិនយូរមិនឆាប់ ថ្ងៃល្អដែលលោកស្រីសេដ្ឋាទន្ទឹងរង់ចាំក៏មកដល់។ សត្យា ត្រូវរាជការបញ្ជូនខ្លួនក្នុងឋានៈជាគណៈប្រតិភូខ្មែរទៅទស្សនាប្រទេសជាមិត្តចំនួនបីខែ ។

សត្យា ប្រញាប់រៀបចំឥវ៉ាន់ធ្វើដំណើរ ហើយឆ្លៀតទៅជួបមណីឯផ្ទះទួលគោកភ្លាមក្នុងថ្ងៃនោះ ដោយពុំបានដឹងថាមានគេលបឃ្លាំងតាមមើលដំណើរអ្នករហូតទៅដល់ផ្ទះឡើយ ។

មណី នាងនៅមិនទាន់ជាខ្លួនស្រួលបួលទេ ណាថ្ងៃសំរាលបុត្រក៏កាន់តែខិតចូលមកជិតជាលំដាប់។ នារីកំសត់គ្រាន់តែបានដឹងដំណឹងនេះ នាងតក់ស្លុតដូចមនុស្សស្លាប់ពាក់កណ្ដាលខ្លួន តែបានសត្យានិយាយប្រលោមលួងលោម បង្ហាញហេតុផលឱ្យនាងរសាយពីសេចក្ដីព្រួយបារម្ភថា :

-កុំតក់ស្លុតអ្វីអូន មណី ! បងទៅចោលអូនតែបីខែទេធ្វើម្ដេច កិច្ចការរាជការតម្រូវចំលើរូបបងហើយ គេចកែងណាកើត បើអូនស្រួលមិនស្រួលយ៉ាងណាចូរអូនប្រញាប់ទៅគេងពេទ្យភ្លាមទៅ បងដឹងថាអូនជិតគ្រប់ខែសំរាលបុត្រ បងមានសេចក្ដីភិតភ័យព្រួយបារម្ភណាស់។

មណី មិនឆ្លើយនាងកាន់តែយំសសឹកខ្លាំងឡើង ធ្វើឱ្យសត្យារិតតែរំជួលចិត្តអាណិតប្រពន្ធខ្លោចថ្លើមប្រមាត់ ។

-ឈប់យំសោកទៅអូន ! បងនឹងខំបន់ស្រន់ដល់គុណព្រះរតនត្រ័យ និងវត្ថុសក្ដិសិទ្ធិក្នុងលោកឱ្យជួយថែរក្សារូបអូន និងកូនយើង សូមឱ្យជួបប្រទះតែសេចក្ដីសុខសប្បាយរីករាយគ្រប់ពេលវេលា បីខែប៉ុណ្ណោះទេ បងបានវិលមកជួបមុខអូនវិញហើយ !

-ខ្លួនអូនឈឺ .... អូនមិនសូវជាព្រួយបារម្ភប៉ុន្មានទេបង តែ ... អូន នឹកព្រួយទៅដល់ថ្ងៃដែលកូនយើងកើត ខ្លួនអូនមិនធ្លាប់មានកូនណាបងទៅឆ្ងាយទៀត អូ ! អូននឹកព្រួយណាស់បង ...

-កុំគិតឥចឹង .... ! អូនត្រូវតាំងចិត្តឱ្យមុតមាំណ៎ា ... ! ពិតមែន តែបងទៅឆ្ងាយពីរូបអូន តែនៅមានលោកប៉ាម្នាក់ទៀតចាំជួយមើលការខុសត្រូវអូនដែរទេតើ បងនឹងអង្វរសូមឱ្យលោកប៉ា មកលេងនឹងអូនឱ្យបានញឹកញាប់បន្ដិច ដើម្បីកុំឱ្យអូនព្រួយ !

មណី នារីកំសត់ មិនបានឆ្លើយតបមកសត្យាវិញទេ ទឹកភ្នែកកម្សួរហូរចេញមកច្រោក១ដូចគ្រាប់ភ្លៀង ជាសញ្ញាដួងចិត្តប្រាប់បញ្ជាក់ឱ្យដឹងថា ទោះជាបានទទួលពាក្យអង្វរប្រលោមលួងលោមយ៉ាងនេះហើយក៏ដោយ គឺនាងនៅតែព្រួយបារម្ភដដែលគ្មានធូរស្រាល ។

ព្រឹកស្អែកឡើងពេលម៉ោង៩ និង៣០នាទី អាកាសយាន (T.A.I) របស់ក្រុមហ៊ុនអាកាសចរបារាំងក៏បានដឹកនាំគណៈប្រតិភូខ្មែរចំនួន ១២ រូប គឺក្នុងចំណោមនេះ មានសត្យាប្ដីមណី នារីកំសត់រួមផងហោះហើរស្ទុះកញ្ជ្រោលទៅលើផ្ទៃអាកាសកប់បាត់ស្រមោល នឹងសមុទ្រពពក ចេញផុតពីខេត្តខណ្ឌសីមាប្រទេសកម្ពុជា ឆ្ពោះទៅកាន់ប្រទេសជាមិត្ត ។

មួយសប្តាហ៍កន្លងផុតទៅដូចជាការយល់សប្តិ។ ថ្ងៃនេះខណៈដែល មណី នាងកំពុងដេកឈឺនៅលើគ្រែ លោកស្រីសេដ្ឋា និងកញ្ញាភួង-ផល្លីន ក៏បានទៅប្រាកដខ្លួននៅលើផ្ទះនារីកំសត់ ។

រត្ន-មណី គ្រាន់តែឃើញមុខអ្នកទាំងពីរ នាងក៏យល់បានថា គ្រោះអាក្រក់ធ្លាក់មកលើខ្លួននាងហើយក្នុងពេលនេះ ។ នាងខំប្រឹងលាក់អាការ តក់ស្លុត ស្ទុះក្រោកចុះពីលើគ្រែអង្គុយបត់ជើងសំពះលោកស្រីសេដ្ឋាដៃ ជើងញ័រញាក់ដូចកូនសត្វ ។

-ជំរាបសួរលោកអុំ ... !

-ហ៊ឺះ ! ចេះគួរសមណាស់មីចង្រៃ ! (លោកស្រីបែរទៅនិយាយរកកញ្ញាភួង-ផល្លីន ) កូនឯងមើលនែ ! នេះហើយនាង មណី ភរិយាសំណប់ចិត្តលោកឌុច-សត្យា ! ព្រះអើយមើលចុះ ! វាយកគ្នាទាល់តែផើមជិតចេញកូនបានឯងដឹងអញក្តៅណាស់ !

-កុំអាលទាន់ច្រឡោតម៉ាក់ ! ម៉ាក់សួរលោកស្រី មណី ហ្នឹងមើល យកគ្នាទាល់តែផើមហ្នឹង មានចុះអេតាស៊ីវិលទេ ហើយកាលពីថ្ងៃការម្តេច ក៏គ្មាននរណាដឹង ?

-អើ ! មែនកូន ! នែ ! នាងមណី ! នាងឱ្យលោកឌុច-សត្យា យកខ្លួនហ្នឹង មានដឹងថាគេជិតរៀបការទេ នាងចុះអេតាស៊ីវិលជាប្តីប្រពន្ធ ជាមួយលោកឌុច-សត្យា បានប៉ុន្មានខែហើយលោកស្រី ?

មណី សែនចុកចាប់នឹងសំដីផ្លែផ្កាស៊កសៀក របស់លោកស្រី នារីកំសត់ឱនមុខយំ លើកដៃសំពះនៅស្ងៀមមិនឆ្លើយតប ។

កាយវិការស្ងៀមស្ងាត់ដូច្នេះកាន់តែធ្វើឱ្យលោកស្រី សេដ្ឋា មោហោទោសោខ្លាំងលើសដើម ។

-ម៉េចនៅស្ងៀមតចឹង មីមណី ! ឯងឮអញសួរទេ ? ឯង ដាក់ស្នេហ៍កូនអញទាល់តែវាឈ្លក់វង្វេង ឆ្កួតលីលាលែងដឹងខុសត្រូវ ! ឯងថ្លើមធំណាស់ ហ៊ានទៅដណ្តើមប្តីគេបំរុងការ មីចោរខ្ញុំគេអស់សាច់ ! កំពូជឯង ខ្ញុំអញទេតើ ម្តេចក៏ឯងចង់តាំងខ្លួនធ្វើកូនប្រសាអញទៅវិញ ! ឯងសម្លឹងឃើញទ្រព្យសម្បត្តិអញហ្នឹងឬមីឈាមថោក ! មើលចុះ ឯងប៉ិនមារយា បោកប្រាសឱ្យកូនអញ ទិញតវ៉ាន់ដាក់ពេញផ្ទះ !

កញ្ញាភួង-ផល្លីន ឃើញលោកស្រីសេដ្ឋាស្តីឱ្យ មណីនៅស្ងៀមមិនហ៊ានត នាងក៏បានចិត្តឈរច្រត់ចង្កេះជួយជេរស្តីបន្ថែមគ្មានញញើតមាត់ :

-នែ ! មីសត្វនេះ ! ឯងដឹងបងសត្យាជាប្តីអញទេ យើ ! ហ៊ាន តែម៉ាក់ជេរស្តីបណ្តេញចុះចេញពីផ្ទះប៉ុណ្ណឹងហើយ ឯងនៅមុខក្រាស់មកសម្ងំពួនលួចប្តីអញទៀតប្រយ័ត្នណ៎ា ! មីស្រីចង្រៃ ! មីស្រីផើមប្តីរាប់រយ !

ហួសវិស័យនឹងអត់ទ្រាំស្តាប់ពាក្យប្រមាថកាតទានរបស់ កញ្ញា ភួង-ផល្លីន តទៅទៀតបាន មណីក៏ដាច់ចិត្តឆ្លើយតបទៅវិញថា :

-អ្នកផល្លីន ... ! អ្នកកំពុងមើលងាយខ្ញុំហួសហេតុហើយ ខ្ញុំមិន មែនជាស្រីចិញ្ចើមថ្នល់ ផើមប្តីរាប់រយដូចអ្នកស្មាននោះទេ !

-យើ ! ឯងហ៊ានតមាត់ជេរកូនប្រសាអញផង មីចោររលាយរូប ស្លាប់នឹងកើតកូន !

លោកស្រីសេដ្ឋា ស្ទុះទៅក្របួចសក់ មណី ចាប់ហែកសំពត់អាវ ព្រមទាំងទះតប់គ្មានត្រាប្រណី :

-ផាច់ ! ផាច់ ! ផាច់ ! ...

-អូយ ! អូយ ! កុំធ្វើបាបខ្ញុំលោកអុំ ! ....

-ទេ ! កុំមកអង្វរស្អី ! ថ្ងៃនេះអញត្រូវយកឈាមក្បាលឯង ឱ្យបាន !

ថាហើយ លោកស្រី ចិត្តបាបក៏ស្ទុះទៅយករនុកទ្វារនៅក្បែរនោះ មកសំពងខ្លួនប្រាណ ក្បាលនាងជាដំណំ ។ ស្រីអភ័ព្វលូនចូលទៅឱបជើង លោកស្រី តែត្រូវលោកស្រី ធាក់ផ្ងារថយក្រោយ ទៅផ្ទប់ជញ្ជាំង កញ្ញា ភួង-ផល្លីន ឈរញញឹមយ៉ាងមានជ័យជំនះ ។

លោកស្រីសេដ្ឋា វាយធ្វើទារុណកម្ម មណីទាល់តែខ្លួនឯងឈឺដង្ហក់ ហត់ខុ១ បែកញើសប៉ុន១គ្រាប់ពោត ។ លោកស្រីខំប្រឹងស្រែកជេរ មណី ខ្លាំង១ឱ្យអ្នកជិតខាងបានដឹងឮថា :

-មីមណី ! អញក្តៅចិត្តនឹងម៉ែងណាស់ ! ម៉ែងត្រូវចុះចេញពីផ្ទះ នេះឱ្យឆាប់ជាទីបំផុត បើសិនជាម៉ែងមិនចង់ឈឺខ្លួនធ្ងន់ ! អញមិនអាចបណ្ដោយឱ្យម៉ែងដាក់ស្នេហ៍កូនអញឱ្យវង្វេងវង្វាន់ដល់ខ្លួនឯង ឱ្យម៉ែងបោកយកទ្រព្យសម្បត្តិអញមកគរទុកក្នុងផ្ទះនេះបានតទៅទៀតទេ! ម៉ែងត្រូវដើរចុះតែសំពត់មួយចង្កេះក្នុងពេលឥឡូវនេះ ឮហើយនៅមីចោររលាយខ្យល់ !

-ខ្ញុំគង់នឹងចុះចេញពីផ្ទះនេះទេ សូមលោកអ៊ុំអាណិតមេត្តាពន្យាពេលឱ្យខ្ញុំបានសម្រាលបុត្រសិនលោកអ៊ុំ !

-មិនបាន ! មិនបាន ! វរ១ចង្រៃឧបទ្រពស្រុកភូមិគេអស់ហើយ ម៉ែងត្រូវចុះចេញម្ដងនេះឱ្យបាត់ស្រមោល កុំឱ្យអញឃើញដូចមុនទៀតទៅ ! ដើរចេញឱ្យផុតទៅម៉ែងនៅសំពះលន់តួសូមទោសដល់ណាអាំ ! ...

-ខ្ញុំចុកពោះណាស់លោកអ៊ុំ ! ខ្ញុំដើរចេញក្នុងពេលឥឡូវមិន ទាន់បានទេ ...

មណី វាចារហើយ នាងក៏យកដៃមកសង្កត់ពោះដែលកំពុង តែចុកខ្ទួល១យ៉ាងឈឺចាប់ ។

-អូ ! មីចង្រៃឯងដើរលេងរួចទៅហើយ ! បើតថឹងចាំអញជួយ អូសយកបុណ្យឱ្យ ! ...

ថាហើយលោកស្រីសេដ្ឋា ក៏ចាប់ទាញដៃមណីអូសតាំងពីក្នុងផ្ទះ រហូតមកដល់មាត់ជណ្ដើរ ។

-ម៉េច ! អញជួយអូសដល់មាត់ជណ្ដើរហើយម៉ែងចុះដើរទៅ រួចទេ ?

-លោក .... អ៊ុំ ... អើយ ... ខ្ញុំហត់ .... ណាស់ ! ....

មណី ឆ្លើយទៅលោកស្រីទាំងហត់ ស្ទើរដកដង្ហើមមិនដល់គ្នា ។

-អ៊ុំ ! ម៉ែងចុះមិនរួចទៀតឬ ? បើម៉ែងនៅធ្វើមារយាចុះមិនរួច មិនអីទេចាំអញជួយបញ្ជូន !

ផុតកន្ទុយពាក្យស្ទើរមិនទាន់ លោកស្រីសេដ្ឋា ក៏ធាក់មណី មួយជើងយ៉ាងខ្លាំង បណ្ដាលឱ្យនាងរងកម្មរមៀលរះតាមកាំជណ្ដើរពីលើផ្ទះរហូតដល់ដីចុកចាប់សព្វសារពាង្គកាយ ។

លោកស្រីធ្វើបាប មណី បានសមគោលបំណងហើយ ក៏បែរមកពិគ្រោះជាមួយកញ្ញាភួង-ផល្លីនថា :

-តែប៉ុណ្ណោះវាមុខជាស្លាប់ បើមិនស្លាប់ពេលឥឡូវក៏គង់ស្លាប់ ពេលកើតកូនដែរ ឥវ៉ាន់ប្រដាប់ប្រដាទាំងប៉ុន្មានក្នុងផ្ទះនេះ ម៉ាក់គិតជួលឡានដឹកទៅផ្ទះយើងមែនទេកូន ? ...

-ចាំ ! ស្រេចលើម៉ាក់ចាត់ការចុះ ! តែប្រយ័ត្នកុំឱ្យលោកប៉ាដឹង វរ១បងសត្យាត្រឡប់មកពីបរទេសវិញ បែកការណ៍មុខជាកើតរឿងរ៉ាវធំហើយ ។

-មិនអីទេកូន ! ស្រេចតែម៉ាក់ !

លោកស្រីសេដ្ឋា និងកញ្ញាភួង-ផល្លីន ពិគ្រោះត្រូវដង ត្រូវផ្លែ រួចហើយ ក៏នាំគ្នាទៅជួលរថយន្តកាមីញ៉ុង (Camion) មួយឱ្យមករើឥវ៉ាន់លើផ្ទះមណីដឹកទៅផ្ទះលោកស្រី ។

គួរអនិច្ចាដល់វាសនាមណីនារីកំសត់ណាស់ ក្រោយពីពួកសត្វតិរិច្ឆាន ស្រោបក្នុងរាងកាយមនុស្សនាំគ្នាជញ្ជូនឥវ៉ាន់ចេញពីក្នុងផ្ទះអស់ហើយ នាងខំប្រឹងទប់ខ្លួនឡើងទៅលើផ្ទះមើលទីកន្លែងដែលធ្លាប់ឱ្យសេចក្ដីសុខកាលនាងនៅជាមួយប្ដីទាំងក្ដីសោកអាល័យ ។

មណី និយាយចេញមកតិច១ម្នាក់ឯងទាំងទឹកភ្នែកហូរសស្រាំនៅមុខរូបថតសត្យាថា :

-ឱ ... ! បងសត្យាប្ដីសម្លាញ់អូនអើយ ... ! តើបងដឹងទេថា ពេលនេះ អូនកំពុងទទួលទារុណកម្មពីម្ដាយបងយ៉ាងសែនកាចសាហាវ សូម្បីតែបុត្រក្នុងផ្ទៃដែលគ្មានមិនទាន់ឃើញពន្លឺព្រះអាទិត្យផង ក៏ត្រូវគេធ្វើបាបប្រាថ្នាជីវិតដែរ...! អូនសូមលាហើយណាប្ដីសម្លាញ់ណា.... សូមបង ត្រឡប់មកពីបរទេសវិញព្រមព្រៀងរៀបការជាមួយនាងផល្លីនចុះ ! ជាតិនេះជាជាតិអភ័ព្វ អូនគ្មានវាសនា បានរួមរស់ជាមួយបងរហូតអវសានជីវិតអូន ... !

ពោលចប់ មណីក៏ខំសម្លឹងមើលមុខរូបថតប្ដីសម្លាញ់យំសោកបោកប្រាណលើទ្រនុំអភ័ព្វរហូតសន្លប់បាត់ស្មារតី ។

មណី ភ្ញាក់ដឹងខ្លួនម្តងទៀតនៅម៉ោង៨យប់ ។ ទារកក្នុងផ្ទៃស្ទុះកញ្ជ្រោល ដោយដល់កំណត់ពេលប្រសូត្រ ។ ផ្ទៃកាន់តែឈឺខ្លាំងឡើង១ជាលំដាប់ ស្ត្រីកំសត់ខំប្រឹងដើរទប់ពោះកាត់ស្បែងងងឹតសន្ធិយារាត្រី ដោយគ្មានគោលដៅទៅកន្លែងណាជាពិតប្រាកដឡើយ ។ ផ្ទៃមេឃខ្មៅស្រអាប់ចាប់ផ្តើមធ្លាក់ខ្យល់ព្យុះ បន្ទាប់មកព្រះភិរុណក៏បង្អុរភ្លៀងមួយមេយ៉ាងធំស្រោចស្រពលើផែនពសុធា ។

មណី ខំត្រាច់ដើរក្រោមសូររន្ទះភ្លៀងផ្គរ ផ្ទៃនាងឈឺចុកចាប់ទ្វេរ ឡើងគ្មានស្រាកស្រាន្ត ណារងារនឹងខ្យល់ភ្លៀង ណាឈឺពោះប្រសូតបុត្រ។ ស្រីកំសត់ខាំមាត់អត់ធ្មត់ យកដៃក្តោបពោះទប់ទល់នឹងសេចក្តីឈឺចាប់ តែទីបំផុតនាងក៏ទ្រាំលែងបានដើរតទៅទៀតលែងរួច។

-អូយ ! អូយ ! ខ្ញុំឈឺពោះណាស់ ! លោកអើយជួយសង្គ្រោះ ខ្ញុំ ផង ... !

សម្រែកដ៏គួរឱ្យអាណោចអាធ័មរបស់ស្រីកំសត់បានរសាត់ទៅកន្ត្រាក់សោតិន្ទ្រីយារម្មណ៍អ្នកនៅក្នុងផ្ទះស្លឹកមួយស្ថិតនៅក្បែរថ្នល់ជិត១នោះ ។ ពូមីងសប្បុរសបើកទ្វារទាំងកំពុងភ្លៀងខ្លាំងចេញមកមើល ។ លុះឃើញនាងអង្គុយក្តោបពោះហាលភ្លៀងញ័រញាក់ ពូម្ចាស់ផ្ទះក៏សួរដោយសេចក្តីងឿងឆ្ងល់ និងព្រួយបារម្ភថា :

-នាងកើតអី ? នាងឈឺពោះសម្រាលកូនឬ ?

មណី លើកដៃសំពះពូមីងសប្បុរស រួចឆ្លើយថា :

-ចាំ ... ! លោកពូលោកមីង ... ខ្ញុំឈឺពោះសម្រាលកូន អូយឈឺណាស់ ! លោកពូ ... សូមអាណិតជួយស្រោចស្រង់យកខ្ញុំទៅដាក់ពេទ្យផង ... អូយ ... !

ពូមីងបែរមើលមុខគ្នាទ្រង់គិត គាត់ចង់សាកសួរដំណើរដើមទង រឿងរ៉ាវរបស់ មណី តែឃើញនាងទុរនទុរាខ្លាំងណាស់ទៅហើយ គាត់ក៏មិនហ៊ានសួរដេញដោលប្រញាប់ប្រញាល់រត់ទៅហៅ តាក់ ស៊ីប៊ិស (TAXIBUS) ដឹកនាងទៅកាន់មន្ទីរពេទ្យសម្ភពផះង៉ាង៉ាមជាបន្ទាន់ ។

## -៦-
## នារីវេទកម្ម

| | |
|---|---|
| អាសូរតែបុត្រកើតឥតឪ | ប៉ាអ្នកលាទៅប្រទេសឆ្ងាយ |
| ជីដូនចិត្តមារដេញកំចាយ | តាំងតែពីម្តាយនៅពរផ្ទៃ ។ |
| គួរឱ្យអាណិតមណីនារីវេទកម្ម | ជីវិតប្រេះស្រាំរស់គ្មានន័យ |
| ព្រាត់អស់ក្តីសុខប្រាស់ទាំងប្តី | ចិញ្ចឹមកូនខ្ចីហប្ញទ័យខ្លោចផ្សា ។ |

មួយអាទិត្យកន្លងផុតទៅ ...

រត្ន-មណី ប្រសូតបានបុត្រប្រុសមួយប្រកបទៅដោយសុខភាពពេញបរិបូណ៌ ។ នាងកាលចេញពីពេទ្យពូមីងសប្បុរសក៏បានទទួលឱ្យមកនៅផ្ទះគាត់ក្រោយពី មណី សារភាពរឿងហេតុនៃជីវិតអភ័ព្វរបស់នាង ជំរាបពូមីងសព្វគ្រប់ គាត់ក៏ឃាត់មណីឱ្យនៅជាមួយគាត់រៀងរហូតទៅ ព្រោះស្រឡាញ់រាប់អាននាងទុកដូចជាកូនគាត់បង្កើត ។

រៀងរាល់ថ្ងៃ ពូធុំមីងយ៉ាន តែងខំរកស៊ីលក់បន្លែប៉ះកង់យកប្រាក់ មកចិញ្ចឹមម្តាយកូនកំព្រាគ្មានឱ្យខ្វះខាតមួយវេលាណាឡើយ តែទុកជាបានទទួលសេចក្តីមេត្តាករុណាពីពូមីងយ៉ាងនេះហើយក៏ដោយ ទម្ងន់ទុក្ខរបស់នារីព្រាត់ប្តីនៅធ្ងន់ធ្ងរដដែល នាងដេកឱបបុត្រកំព្រាយំហើមភ្នែកគ្មានលោះថ្ងៃ ។ នាងនឹកទៅដល់ប្តីសម្លាញ់ដែលព្រាត់ចេញឆ្ងាយពុំបានដឹងរឿងហេតុ ។ នាងព្រួយបារម្ភដល់ទារកតូច ដែលមានវាសនាកើតបានស្គាល់ពន្លឺព្រះអាទិត្យ តែត្រូវខ្វះឪពុកទំនុកបំរុងនៅពេលអនាគត គិតឃើញសព្វគ្រប់ក៏ចង់សម្លាប់ខ្លួនឯងឡើយណាយក្នុងជីវិតរស់នៅ ។

ពូធុំមីងយ៉ាន ថ្ងៃណាឃើញមណីមានអាការស្រពាប់ស្រពោនខុសធម្មតា គាត់ក៏តែងនិយាយលួងលោមនាងឱ្យរសាយពីទុក្ខព្រួយថា :

-ឈប់យំឈប់សោកទៅក្មួយមណី ! បើក្មួយនៅតែកង្វល់ចិត្តយ៉ាងនេះ វាអាចបណ្តាលឱ្យក្មួយទៅជាឈឺទាស់សរសៃ ខ្វះទឹកដោះឱ្យកូនបៅជាមិនខាន បើមិនអាណិតខ្លួនឯងក៏សូមឱ្យអាណិតដល់ទៅកូនដែលគ្មាចង់រស់ឃើញពន្លឺព្រះអាទិត្យផង អ្វីៗនៅក្នុងលោកនេះគ្មានអ្វីជាទៀងទាត់ទេ វាតែងប្រែប្រួលផ្លាស់ប្តូរភ្លាមៗគ្រប់កាលសម័យកាលណា ដែលវាកន្លងហួសមកហើយចូរយើងខំបំភ្លេចវាទៅ យើងរាប់ទុកថាវាជាមេរៀនអភ័ព្វប្រចាំជីវិតរបស់យើង មនុស្សម្នាក់ៗកើតមកក្នុងលោកត្រូវចេះតស៊ូ ទប់ទល់នឹងឧបសគ្គក្នុងដំណើរជីវិតគ្រប់ៗគ្នា សេចក្តីសុខនិងទុក្ខគ្មានអ្នកណាចៀសផុតទេក្មួយគ្រាន់តែតិចឬច្រើន ឬឆាប់និងយូរប៉ុណ្ណោះ ។

កាលបើបានស្តាប់ពាក្យប្រៀនប្រដៅលួងលោមពីពូមីងដូច្នេះ មណី ហាក់ដូចជាចេះដកចិត្តឱ្យរួចផុតពីអន្លង់ទុក្ខមួយខណៈ តែដល់ភ្លេចត្រចៀក ទុក្ខសោកទាំងប៉ុន្មានក៏ចូលមករួបរឹតប្រមាត់បេះដូងនាងវិញដដែល ។

បីខែរំលងផុតទៅ ... ! ឧុច-សត្យា ទៅបំពេញបេសកកម្មឯបរទេសក៏ត្រូវដល់កំណត់ថ្ងៃត្រឡប់មកកាន់មាតុប្រទេសវិញ ។

គ្រាន់តែមកដល់ផ្ទះ ពេលល្ងាចនោះ សត្យាក៏ប្រញាប់ប្រញាល់ ស្កាត់ទៅជួបមណីប្រពន្ធសម្លាញ់ ដោយដក់ទុកនូវសេចក្តីនឹករលឹកក្រៃលែង ។

នរៈញញឹមទុកក្នុងចិត្តនឹងបានឃើញបុត្រសម្លាញ់របស់គេ ដែលមិនទាន់ដឹងជាបុត្រប្រុសឬស្រីនៅឡើយ ។

សត្យា បើករថយន្តបណ្តើរគិតបណ្តើររហូតមកដល់មុខផ្ទះមណី នៅពីដើមដោយមិនដឹងខ្លួន ។ នរៈពន្លត់គ្រឿងយន្តរត់ឡើងជណ្តើរទៅលើផ្ទះ ក្មេងតូចៗពីរបីនាក់រត់ចេញពីក្នុងផ្ទះមកមើលមុខសត្យា ទ្រង់ងឿងឆ្ងល់ បុត្រលោកឧត្តមមន្ត្រីភ្ញាក់ស្រឡាំងកាំងឈរទ្រឹងនៅហ្នឹងមួយកន្លែង គេកំពុងចោទសួរខ្លួនឯងថា តើមណីផ្លាស់ផ្ទះឬ ? បើផ្ទះនេះជាផ្ទះមណី ម្តេចក៏មានក្មេងក្មាង ហើយការរៀបចំក្នុងផ្ទះខុសពីមុនឆ្ងាយម្ល៉េះ កំពុងឈរគិត ភ្លេចខ្លួន ស្ត្រីចាស់ម្នាក់ក៏ដើរចេញពីក្នុងផ្ទះមក សត្យាប្រញាប់លើកដៃសំពះសួរ :

-ជំរាបសួរអ្នកមីង !

-ចាស ! លើកដៃថ្វាយព្រះ លោកអញ្ជើញមករកអ្នកណាដែរ ?

មីងម្ចាស់ផ្ទះសួរមកសត្យាវិញ ។

-បាទ ! អា ... ខ្ញុំ ... អា ... ដូចជាវង្វេងច្រឡំផ្ទះអស់ទៅហើយ អត់ទោសអ្នកមីងមានដែលធ្លាប់ស្គាល់នាងមណីទេ ពីដើមនាងមណី ធ្លាប់នៅផ្ទះនេះដែរ !

មីងចាស់គ្រវីក្បាលបដិសេធ ។

-ទេលោកក្មួយ ! ខ្ញុំមិនដែលស្គាល់ឈ្មោះ នាងមណីហ្នឹងទាល់តែសោះ ខ្ញុំឡើងមកនៅផ្ទះនេះចំនួយជាបីខែហើយ ម្ចាស់ផ្ទះគេនិយាយប្រាប់ខ្ញុំថា ផ្ទះនេះពីដើមជួលឱ្យស្រីកំណាន់គេម្នាក់លុះថ្ងៃក្រោយមកម្តាយខាងប្រុសនិងប្រពន្ធគេស៊ើបសួររកឃើញ គេក៏វាយបណ្តេញខ្ចាត់ខ្ចាយបាត់ទៅ ខ្ញុំឮគេថានាងហ្នឹងផើមជិតគ្រប់ខែផង មិនដឹងជារសាត់អណ្តែតទៅកើតកូនឯណាស្លាប់ឬក៏រស់ទេ លោកក្មួយ..!

សត្យាត្រជាក់ខ្លួនស្រឹត សេចក្តីសង្ឃឹមរីករាយសប្បាយថាបានជួបមុខបុត្រភរិយាត្រូវរលាយអស់រលីង គេកាត់យល់ច្បាស់ថាមណីមុខជាត្រូវលោកស្រីម្តាយគេ និងកញ្ញាផល្លីនមកអុកឡុកវាយបណ្តេញ ឱ្យចុះចេញពីផ្ទះនេះជាប្រាកដ ។ នរៈលើកដៃសំពះលាមីងម្ចាស់ផ្ទះ :

-ខ្ញុំសូមជំរាបលាទៅវិញហើយអ្នកមីង !

-ចាស ! អញ្ជើញលោក !

សត្យា បើករថយន្តចេញពីមុខផ្ទះអតីតភរិយាអ្នកនៅលឿនស្លេវ ដូចផ្លែព្រួញរបូតពីធ្នូ តំរង់ឆ្ពោះទៅកាន់លំនៅដ្ឋានខ្លួនទាំងដួងចិត្តតក់ស្លុត ។

សត្យាទៅដល់ផ្ទះ ជួនជាគ្រោះល្អលោកស្រីសេដ្ឋាមិននៅ អ្នកដើរចូលទៅក្នុងបន្ទប់ទទួលភ្ញៀវ ក៏ជួបនឹងឪពុកកំពុងអង្គុយអានសារព័ត៌មាន ។

លោកឧច-ស៊ីផាន់ គ្រាន់តែក្រឡេកឃើញទឹកមុខសត្យា លោក ក៏កាត់យល់ថា មុខជាមានរឿងអីកើតឡើងមិនខាន ។

-លោកប៉ា ( សត្យាដាក់គូថអង្គុយលើសាឡុងសួរទៅឪពុក ) លោកប៉ា បានជ្រាបទេពីរឿងអូនមណី ? ...

លោកឧច-ស៊ីផាន់ ដូចជាភ្ញាក់នឹងសំដីនេះបន្តិច លោកដាក់កាសែតចុះពីដៃ និយាយទៅកាន់កូនប្រុសលោក ដោយសម្លេងអួលដើមកថា :

-រឿងមណី រត់បាត់ពីផ្ទះ ឪពុកមិនបានដឹងច្បាស់ទេកូន តែឪពុកយល់ថា រឿងនេះគ្មានអ្នកណាក្រៅពីម៉ាក់ឯងឡើយ ប៉ាអាណិតមណីណាស់ ខំស្កាត់ស៊ើបសួរគ្រប់ច្រកល្ហក តែពុំបានដំណឹងដើមដានអ្វីពីមណីបន្តិចសោះ ប៉ាទៅសួររកគ្រប់មន្ទីរពេទ្យសម្រាលកូនទាំងពេទ្យរាជការ ពេទ្យឯកជន ក៏នៅតែមិនឃើញមណីទៀត កាលកូនទើបមកដល់ ប៉ាមិនហ៊ាននិយាយប្រាប់ ប៉ាខ្លាចកូនខូចចិត្ត តែឥឡូវបើកូនបានដឹងរឿងនេះអស់ទៅហើយ ចូរកូនខំស្វាត់ស្វែងរកមណីឱ្យមែនទែនផង សព្វថ្ងៃបើគ្នានៅរស់មានជីវិត ក៏រស់យ៉ាងសែនវេទនាជាទីបំផុត ហ៊ឺ ! ម្តាយឯងចិត្តអាក្រក់ណាស់ ... !

មានប្រសាសន៍ចប់ ទឹកភ្នែកជរាក៏ហូរហៀរមកតាមប្រឡាយថ្ពាល់ក៏ជ្រីវជ្រួញរបស់លោកមន្ត្រី ។

សត្យាឃើញឪពុកដូច្នោះ ក៏កាន់តែរំជួលដួងចិត្តអួលអាក់ខ្លាំងលើសដើម នរៈប្រញាប់ទាញកូនកន្សែងពីក្នុងហោប៉ៅ មកផ្តិតទឹកភ្នែកដែលកំពុងចង់ហូរចេញមក រួចនិយាយទាំងទឹកមុខសោកសៅទៅកាន់បិតាថា :

-លោកប៉ា ... ! អ្នកមកនៅថ្មីគេបាននិយាយប្រាប់ខ្ញុំថា មណីត្រូវម៉ាក់និងផល្លីន វាយធ្វើទារុណកម្មហួសវិស័យមនុស្សតាមតែកាត់ស្មានមើលទៅ អូនមណីប្រហែលជាមិនរស់រានមានជីវិតតទៅទៀតផង តែទោះជាយ៉ាងណាក៏ដោយខ្ញុំត្រូវតាមរកមណី ឱ្យទាល់តែឃើញ ទោះជាស្លាប់ ឬរស់ ម្តេចក្តី ជីវិតខ្ញុំមិនអាចរស់នៅឯកឯង ខ្វះរូបមណីបានទេលោកប៉ា ... !

-ហ៊ឺ ! ក្នុងជីវិតនេះ មណីជួបប្រទះតែនឹងសេចក្តីអស់សង្ឃឹមគ្រប់បែបយ៉ាង ព្រាត់ឪពុកម្តាយ ! ព្រាត់ប្តីសម្លាញ់ ! ព្រាត់អ្វីទាំងអស់ដែលជាទីប្រាថ្នា ! ... ប៉ាអាណិតតែទារកតូចក្នុងផ្ទៃទេ គ្នាគ្មានកំហុសអ្វីសោះក៏ត្រូវ ទទួលទណ្ឌកម្មពីព្រហ្មលិខិតដែរ !

ពីរនាក់ឪពុកកូនកំពុងសន្ទនា សូររថយន្តលោកស្រីសេដ្ឋា ដែលអញ្ជើញទៅផ្សារក៏ត្រឡប់មកដល់ ។ សត្យា សង្កៀតធ្មេញពោរពេញទៅដោយសេចក្តីចុកចាប់ គេស្ទុះក្រោកឈរពីកន្លែងអង្គុយ លាឪពុកដើរចេញពីបន្ទប់ទទួលភ្ញៀវទៅក្រៅមួយរំពេច ។

ចាប់តាំងពីថ្ងៃដែលសត្យា ដឹងរឿងហេតុមណីភរិយាកំសត់មក គេក៏ខំស្កាត់តាមរកស៊ើបសួរគ្រប់ទីកន្លែងមិនថាយប់ថ្ងៃ តែផលកម្មមិនអត់អោនឱ្យអ្នកទាំងពីរបានជួបគ្នាឡើយ ។ ឥឡូវនេះ សត្យាដែលពីដើម មានមាឌមាំ សាច់ឈាមធំធាត់ក៏ប្រែទៅជាស្គមស្គាំងទឹកមុខស្លក់ក្រៀម ស្រពោន គេចេះផឹកស្រា ជក់បារី ដើររាំរែកមួយយប់ៗ ទល់គ្នានឹងពេលភ្លឺរាល់ៗថ្ងៃ រីឯលោកស្រីសេដ្ឋា ជាម្ដាយក៏ចេះតែបង្ខិតបង្ខំឱ្យរៀបការជាមួយ កញ្ញាភួង-ផល្លីន នៅពេលឆាប់ៗ ទីបំផុតការឈ្លោះវិវាទរវាងម្ដាយ និងកូន ក៏ចាប់ផ្ដើមបើកឆាកឡើងក្នុងពេលល្ងាចថ្ងៃមួយជាពេលដែលលោក ឌុច-ស៊ីផាន់ មិននៅផ្ទះ ។

-អាសត្យា អាកូនរមិលគុណ ! ( លោកស្រីជេរទៅកូន ) អញ ខំបង្កើតក្បាលឯងមកសំរាប់តែទុកឱ្យឯងធ្វើបាបអញ រាល់ពេលវេលា !

សត្យា ទប់កំហឹងពុំបានក៏ផ្ទុះតបទៅវិញ :

-ហះ ! ហះ ! ហា ! អាកូនរមិលគុណ ? ធ្វើបាបអញរាល់ពេលវេលា ? ហា ! ហា ! ហា ! ឱ្យខ្ញុំសូមសើចឱ្យអស់ចិត្តបន្តិចចុះម៉ាក់ តើអ្នកណា គេធ្វើបាបម៉ាក់ ? អ្នកណាគេរមិលគុណម៉ាក់ ? ការពិតខ្លួនម៉ាក់ទេតើជាអ្នកធ្វើបាបកូនឯង ! ជាអ្នករមិលគុណគេនោះ ! ម៉ាក់ភ្លេចអស់ហើយឬ កាលម៉ាក់ឈឺដេករង់ចាំតែថ្ងៃស្លាប់បានអ្នកណាទៅរកថ្នាំឱ្យផឹក ? ហើយសព្វថ្ងៃនេះទៀតសោត ខ្ញុំធ្វើបាបម៉ាក់ ឬក៏ម៉ាក់ធ្វើបាបខ្ញុំ ?

-សព្វថ្ងៃអញធ្វើបាបអីឯងខ្លះ ! (លោកស្រីស្ដីចង្អុលមុខសត្យា ខឹងញ័រមាត់ញ័រក) ធ្វើបាបត្រង់មិនឱ្យឯងយកប្រពន្ធខ្ញុំកញ្ជះបាទជើងឯងនោះឬ ?

-ពិតណាស់ហើយម៉ាក់ ! ម៉ាក់ធ្វើបាបធ្វើកម្មមណីហួសវិស័យមនុស្សលោកដែលធ្លាប់ធ្វើមក តើមានមនុស្សណាចិត្តកាចសាហាវឃោរឃៅហ៊ានធ្វើបាបចៅឯងដូចជាម៉ាក់ទេ យ៉ាងហោចណាស់ក៏គួរយកមនុស្សធម៌ដាក់ខ្លួន អាណិតអាសូរដល់ស្ត្រីមានផ្ទៃពោះផង !

-អូ ! ឯងកាន់ជើងមណី ! ឯងដឹងថាមណីវាក្ររហេមរហាមខ្ញុំអញអស់មួយពូជទេ វាគ្មានទ្រព្យសម្បត្តិយសសក្តិស្មើនឹងត្រកូលអញបាន ជាអញមិនឱ្យឯងយកវា !

-ហា ! ហា ! ហា ! កុំមើលងាយអ្នកក្រខ្លាំងពេកម៉ាក់ ! សេចក្ដីស្នេហាគ្មានប្រកាន់សាសន៍ជាតិ ពណ៌សម្បុរ ឬវណ្ណៈខ្ពស់ទាបអ្វីទេ ស្នេហាពិតគឺ ស្ថិតនៅត្រង់ចិត្តស្រឡាញ់ ! អ្នកក្រដូចមណីខ្វះទ្រព្យសម្បត្តិ ខ្វះយសសក្តិកិត្តិយសថ្លៃថ្នូរ គេមិនរាប់ហៅថាមនុស្សទេឬម៉ាក់? តើមនុស្សអ្នកក្រ គេរាប់ទុកជាសត្វធាតុឬអ្វី ? ខ្ញុំយល់ច្បាស់ហើយថា ម៉ាក់ជាមនុស្សមានគំនិតមូលធននិយម តែសូមម៉ាក់ជ្រាបឱ្យច្បាស់ថា អ្នកក្រគ្នាក្រមែនទ្រព្យសម្បត្តិ តែគ្នាអាចមានអ្វីៗដែលអ្នកមានគ្មាន ពោលឱ្យចំគឺគុណសម្បត្តិ និងចរិយាសម្បត្តិ !

លោកស្រីសេដ្ឋាក្ដៅចិត្តណាស់ រាដៃទន្ទ្រាំជើងប៉ុងៗមិនព្រមចុះចាញ់កូន :

-អញស្ដាប់មិនបានទេ ! អញស្ដាប់មិនបានទេ ! មី មណីវាល្អ វិសេសវិសាលត្រង់ណាខ្លះ ហើយផល្លីន គេអន់ថយទាបថោកជាងមី មណី ត្រង់ណា ? ឯងត្រូវតែព្រមព្រៀងរៀបការជាមួយផល្លីនជាដាច់ខាត បើឯង នៅរឹងដែសប្រកែកពុំព្រម ឯងដើរចុះចេញពីអញភ្លាមទៅ ! ទៅនៅជាមួយ មី មណីប្រពន្ធល្អរបស់ឯងចុះអាកូនអកតញ្ញូ !

-បាទ ! ខ្ញុំស្ដាប់បានហើយម៉ាក់ ! ពេលនេះមិនមែនជជែកប្រណាំងប្រជែងដើម្បីនៅផ្ទះនេះតទៅទៀតទេ រឿងតាមរកមណីក៏ម៉ាក់មិនបាច់បញ្ជូនឱ្យខ្ញុំទៅរកដែរ ខ្ញុំបំរុងដើរចេញពីផ្ទះនេះមុនម៉ាក់បណ្ដេញទៅទៀត តែឥឡូវបើបានម៉ាក់មានប្រសាសន៍ច្បាស់លាស់ដូច្នេះ ក៏រឹតឱ្យខ្ញុំស្រួលគិតស្រួលយល់ មិនពិបាកនិយាយគ្នាឱ្យវែងឆ្ងាយ សូមម៉ាក់រស់នៅក្នុងគេហដ្ឋានមនោរម្យទ្រនុំខ្ពស់នេះ តែម្នាក់ឯងចុះ ចំណែកខ្ញុំ ខ្ញុំត្រូវដើរតាមរកមណីប្រពន្ធខ្ញុំឱ្យទាល់តែឃើញ !

ថាហើយ ឌុច-សត្យា ក៏ក្រោកដើរទៅកាន់បន្ទប់ដេកកន្ត្រាក់យកវ៉ាលីដាក់ខោអាវ ដែលគេរៀបចំទុកពីយប់មិញជាស្រេចតំរង់ទៅឡើងត្រីចក្រយានមុខផ្ទះ ត្រង់ឆ្ពោះទៅវិថីព្រះសីហនុដោយពុំទាន់មានគោលដៅពិតប្រាកដ ឈប់សំណាក់នៅកន្លែងណាឡើយ ។

លោកស្រីសេដ្ឋា ពិតមែនតែលោកស្រី ជាមនុស្សប្រកាន់វណ្ណៈ មើលឃើញទ្រព្យសម្បត្តិយសសក្តិជាធំ តែលោកស្រីក៏នៅមានព្រហ្មវិហារធម៌ចំពោះកូនចៅដូចជាម្តាយទូទៅដែរ លោកស្រីចង់ហាមាត់ស្រែកឃាត់ដំណើរសត្យា តែមានគំនិតទិដ្ឋិមានះមួយចូលមកបង្អាក់ធ្វើឱ្យលោកស្រី បិទមាត់នៅស្ងៀមបណ្តោយឱ្យសត្យាចុះចេញពីផ្ទះទាំងរំជួលដួងចិត្ត ។

........................................................................................ មួយឆ្នាំបានកន្លងផុតទៅដូចការយល់សប្តិ។ ឌុច-សត្យា តាំងពីថ្ងៃដើរចុះចេញពីផ្ទះមក គេក៏បណ្តែតបណ្តោយឱ្យខ្សែជីវិតគេឱ្យអណ្តែតត្រសែតទៅលើផ្ទៃសមុទ្រទុក្ខ និងសមុទ្រអបាយមុខគ្រប់បែបយ៉ាង ដោយពុំព្រមឈានជើងត្រឡប់ក្រោយទៅកាន់លំនៅដ្ឋានវិញឡើយ ។

លោកស្រីសេដ្ឋា និងលោកឌុច-ស៊ីផាន់ កើតទុក្ខរីងរៃចំពោះការបាត់ដំណឹងសូន្យឈឹងរបស់កូនប្រុស មិនយូរប៉ុន្មានលោកស្រីក៏ធ្លាក់ខ្លួនឈឺ ត្រាំត្រែង គឺជម្ងឺពិការបេះដូង។ លោក ឌុច-ស៊ីផាន់ បានជូនពាក្យស្តីដំណឹង ទៅលោកភួង-សំអាន ពីរឿងកញ្ញាភួង-ផល្លីន លោកគហបតីក៏ពុំមានអាក់អន់ស្រពន់ចិត្តនឹងលោកឡើយ។ បន្ទាប់ពីជូនពាក្យបានចំនួនប្រាំខែក្រោយមក កញ្ញាភួង-ផល្លីន ក៏បានរៀបការនឹងកូនលោកចៅហ្វាយខេត្តម្នាក់ធ្វើការនៅក្រសួងមហាផ្ទៃ ។

ឥឡូវនេះ យើងបែរទៅមើលនារីកំសត់ និងកូនកំព្រាម្តង។ មណី សព្វថ្ងៃរស់នៅជាមួយពូធុំមីងយ៉ានដដែល កូននាងថ្លោសមានព្រលឹងគួរឱ្យស្រឡាញ់ ចេះហៅតា ហៅយាយមួយម៉ាត់ៗហើយ។ អាជីវកម្មប្រចាំជីវិត របស់នាងគឺធ្វើនំលក់នៅផ្សារគីឡូលេខបួន (ទឹកល្អក់) រឿងចាស់ពិតមែន តែរំលងអស់រយៈពេលជាងមួយឆ្នាំទៅហើយ តែវិប្បដិសារីសេចក្តីចុកចាប់នៅមករុករានទន្ទ្រានទ្រូងនាងគ្រប់ទិនទិវារាត្រីគ្មានដែលធ្វើឱ្យនាងមានសេចក្តីសុខក្នុងឆាកជីវិតឡើយ។ នាងនឹកប្តី នាងតែងអង្គុយយំក្រោយផ្ទះ ពេលល្ងាចៗព្រះទិនករហៀបអស្តង្គត។ ក្នុងលោកនេះ បើនាងរស់នៅខ្វះរូបសត្យាទេវបុត្រកំពូលដួងចិត្ត នាងដឹងខ្លួនឯងថា នាងមិនអាចរស់បានជាដាច់ខាតជួនកាលនាងបំរុងចងកសម្លាប់ខ្លួនឯងម្តងៗ តែនឹកអាណិតដល់កូន នៅពេលណានាងឮសូរកូនហៅម៉ាក់ ហៅតាយាយ នាងហាក់ដូចជាធូរស្រួលក្នុងអារម្មណ៍ហ្នួហ្នងបានមួយគ្រា ទារកតូចដែលមានមុខបេះបិទនឹងមុខសត្យានេះហើយ ធ្វើឱ្យនាងទ្រាំរស់នៅជួយចម្លងអនាគតកូនឱ្យផុតពីគ្រោះលោកីយ៍ក្នុងលោកដ៏សែនចង្អៀតនេះតទៅទៀត ។

ពេលល្ងាចមួយ ក្រោយពីស្រស់ស្រូបបាយរួច ពូមីង សប្បុរស ក៏ហៅមណីទៅអង្គុយលេងរានហាលខាងក្រោយផ្ទះ ជាដំបូងមីងយ៉ានចាប់ផ្តើមសួរទៅមណីថា :

-ក្មួយមណី ! ជាងមួយឆ្នាំហើយដែលក្មួយមកនៅជាមួយមីង មីងពុំដែលឃើញក្មួយសើចញញឹមញញែម សប្បាយរីករាយបានម្តងណាសោះ ហើយប៉ុន្មានថ្ងៃនេះ មីងសង្កេតឃើញទឹកមុខក្មួយខ្មៅជាំចេះតែលួចទៅអង្គុយយំក្រោយផ្ទះពេលល្ងាចៗ តើក្មួយមានរឿងអ្វីមិនសប្បាយចិត្តឬ ?

-បើមានរឿងអ្វីមិនសប្បាយចិត្ត ត្រូវតែប្រាប់ឱ្យពូដឹងភ្លាមណាក្មួយ (ពូធុំនិយាយទៅកាន់មណីកាលឃើញនៅស្ងៀមស្ងាត់ ) ឬមួយក្មួយ មានអាក់អន់ចិត្តនឹងអ្នកណានៅក្នុងផ្ទះនេះ ?

-ចំា ! អត់ទេពូ ! ( មណីឆ្លើយ ) ខ្ញុំសព្វថ្ងៃបានទទួលសេចក្តីសុខ ពីពូមីងយ៉ាងបរិបូណ៌ ពុំដែលនឹកអាក់អន់ចិត្តអ្វីបន្តិចបន្តួចឡើយ តែ... ខ្ញុំព្រួយចំពោះអនាគតកូនដែលគ្មានឪ ខ្ញុំរងារក្នុងដួងចិត្តដោយការព្រាត់ប្រាស់ពីប្តីសម្លាញ់ ពិតតែខ្ញុំដឹងថា ម្តាយប្តីខ្ញុំគេស្អប់ខ្ពើមខ្ញុំ គេវាយធ្វើបាបខ្ញុំរិះមរណាជីពជន្មជាច្រើនគ្រា គេយកប្តីខ្ញុំទៅរៀបការនឹងនារីត្រកូលខ្ពស់ម្នាក់ទៀត តែខ្ញុំក៏រកបំភ្លេចប្តីខ្ញុំមិនកើត ឃើញកូនកាន់តែធំសមមុខមាត់កាត់ទៅរកឪពុកដូចគ្មានខ្ចោះ អនុស្សាវរីយចាស់ៗចេះតែពុះកញ្ជ្រោលក្នុងដើមទ្រូងខ្ញុំឱ្យនឹកដល់គេមិនភ្លេចនៅក្នុងលោកនេះបើគ្មានបងសត្យាជាអ្នកចងក្រងខ្សែវាសនាឱ្យខ្ញុំៗត្រូវស្លាប់ ខ្ញុំមិនអាចរស់នៅកំព្រាឯកាម្នាក់ឯងដូច្នេះបានរហូតអស់មួយជីវិតទេពូ ...!

វាចាចប់ហើយ មណីនារីរងកម្មក៏យំសោកអណ្តើតអណ្តក់ អួលអាក់ក្នុងដួងចិត្តសារជាថ្មីម្តងទៀត។ ពូមីងឃើញដូច្នោះរកទប់ទឹកភ្នែកមិន បានក៏នាំគ្នាពីរនាក់ប្តីប្រពន្ធយំហៀរទឹកភ្នែកសស្រាក់តាមនារីកំសត់ព្រាត់ប្តីដែរ ។

បរិយាកាសក្នុងវង់សន្ទនា ស្ថិតនៅក្នុងសភាពអាប់អួរមួយ ខណៈប្រហែលមួយស្របក់ធំក្រោយមកទើបពូមីងយ៉ាននិយាយឡើងថា :

-ឈប់យំឈប់សោកទៅក្មួយមណី ! វាសនានារីរងកម្មព្រាត់ប្រាស់ប្តីដូចក្មួយនៅក្នុងលោកនេះមានច្រើនណាស់ចូរក្មួយខំកាត់ចិត្តកាត់ថ្លើមឱ្យរសាយពីសេចក្តីទុក្ខខ្លះ១ទៅ បើពិតជាគូព្រេងគូសំណាង កសាងស្នេហ៍ស្និទ្ធគ្នាពីបុព្វជាតិគង់មិនប្រាស់ព្រាត់ចាកឃ្លាតទៅណាទេ យូរឬឆាប់ គង់បានជួបគ្នាវិញពុំខានណាក្មួយ ... !

-ខ្ញុំខំកាត់ចិត្តបំភ្លេចគេណាស់ដែរមីង ...! តែពេលណាខ្ញុំឃើញ អាណារេត (ឈ្មោះកូនប្រុសរបស់នាង) យំឬពេលវាចេះនិយាយហៅតា ហៅយាយ ដួងចិត្តខ្ញុំហាក់ដូចជាក្រៀមស្រពោនអស់មួយរំពេច។

ពូធុំសួរ :

-ចុះសព្វថ្ងៃក្មួយមានបានដឹងថា សត្យាគេរៀបការប្រពន្ធថ្មីគេ ហើយនៅ ?

មណីគ្រវីក្បាល ។

-ចាំះ ! តាំងពីបងសត្យាទៅបរទេសកាលនោះ អាណារេត នៅក្នុងពោះនៅឡើយ រហូតមកដល់ពេលឥឡូវខ្ញុំមិនដែលបានឃើញមុខ ឬទទួលដំណឹងអ្វីពីគេបន្តិចសោះ តែខ្ញុំជឿជាក់ថា សព្វថ្ងៃបងសត្យាបានរៀបការជាមួយនាងភួង-ផល្លីន ជាកូនលោកធនបតីម្នាក់នៅក្រុងភ្នំពេញនេះរួចទៅហើយ ...!

-ហ៊ឺ ! រឿងក្មួយកំសត់ណាស់ !

ពូធុំ និយាយគ្រវីក្បាលដោយជួយអាណិតមណី។

មួយអាទិត្យក្រោយមក ...

ថ្ងៃនេះជាថ្ងៃបុណ្យអុំទូក ជនានុជនគ្រប់ខេត្តខណ្ឌក្នុងកម្ពុជរដ្ឋ បានមកកកស្រទាប់គ្នាពេញរាជធានី តាមដងវិថីនីមួយ១ ណែនណាន់តាន់តាប់ទៅដោយហ្វូងមនុស្ស ដើរចង្អៀតណែនក្តន់ស្ទើរចៀសគ្នាមិនរួចម្នាក់១ មានទឹកមុខញញឹមប្រិមប្រិយ៍ សប្បាយរីករាយ ដែលខ្លួនមានវាសនាល្អ បានមកស្គាល់ភ្នំពេញ ជាពិសេសបានមកលេងទាន់ក្នុងឱកាសព្រះរាជពិធីអុំទូក និងបុណ្យឯករាជ្យជាតិ ។

នៅលើជើងម៉ាថ្មក្រោមដើមស្វាយខាងកើតផ្សារធំថ្មីឃើញបុរសម្នាក់ពាក់វ៉ែនតាខ្មៅអង្គុយសញ្ជប់សញ្ជឹង អស់ពេលជាច្រើនម៉ោងមកហើយ ពុំព្រមក្រោកដើរទៅឯណាសោះបុរសនេះគ្មានអ្នកណាទេគឺ ឌុច-សត្យា ស្វាមីអភ័ព្វរបស់នាងរត្ន-មណី នារីរងកម្ម ដែលយើងកំពុងតែចង់ដឹងចង់ឃើញនោះឯង ។

ក្នុងរយៈពេលជាងមួយឆ្នាំដែលកន្លងផុតទៅ សត្យាគ្មានសេចក្តីសុខនៅក្នុងខ្លួនសូម្បីបន្តិចបន្តួច។ នរៈខំស្កាត់ស៊ើបសួររក មណីភរិយាកំសត់គ្រប់ទិសទីច្រកល្ហក តែកំណាចនៃព្រហ្មលិខិតមិនបើកឱកាសឱ្យអ្នកទាំងពីរបានជួបគ្នាម្តងណាឡើយ ។ មណី នាងយល់ថាប្តីនាងប្រហែលជាព្រមព្រៀងរៀបការជាមួយ កញ្ញាភួង-ផល្លីនតាមការបង្ខិតបង្ខំរបស់លោក ស្រីសេដ្ឋា ជាម្តាយផុតទៅហើយ ។ ចំណែកសត្យា ក៏មានគំនិតប្លែកពីមណី គឺគេយល់ថា មណីប្រពន្ធគេប្រហែលជា ស្លាប់បាត់បង់ជីវិតតាំងពីថ្ងៃសំរាលកូនម្លេះ។ តែដែលអ្នកនៅខំស្វាត់ស្វែងដើររក ក៏ដើម្បីបំភ្លេចទុក្ខ នឹងដោយការមិនទាន់អស់ចិត្តមែនទែននោះឯង ។

នាឡិកាក្នុងផ្សារថ្មីចង្អុលម៉ោង១២គត់។ កំដៅសូរ្យសែងនៃខែ តុលា ជះកំដៅក្តៅស្ទើរលាករលួយប្រាណមនុស្សម្នា ដែលសញ្ជូរពោរពេញ ទៅដោយសេចក្តីសប្បាយរីករាយក្នុងរាជធានីបុណ្យអុំទូក ។

សត្យា ក្រោកឈរពត់ខ្លួនស្វាបមួយសន្ទុះ គេក៏សំរេចចិត្តដើរទៅលេងមុខវាំងមើលគេអុំទូកងរប្រណាំង។ ជើងចេះតែឈានដើរទៅមុខកាត់វិថីមួយទៅវិថីមួយពុំបានយកចិត្តទុកដាក់នឹងលំអផ្ទះ ហាងនានាដែលខំតុបតែងរចនាប្រកួតប្រជែងគ្នា ក្នុងពិធីបុណ្យនេះឡើយ ដួងចិត្តគេគិតតមមៃដល់មណីប្រពន្ធសម្លាញ់ ដែលព្រាត់ពីគ្នាជាងមួយឆ្នាំដោយព្យុះកម្មតែម៉្យាង។

សត្យា ឈរនៅមាត់ទន្លេមុខវាំង បានប្រហែលជាកន្លះម៉ោង មនុស្សម្នាមកមើលបុណ្យអ៊ូអរច្រើនពេក អ្នកក៏ដើរត្រឡប់មកផ្សារចាស់ម្តងវិញ។ ខណៈដែលសត្យាដើរមកដល់មុខរោងភាពយន្តទ្រុងកុកចក្ខុអ្នក ក៏ក្រឡេកទៅឃើញស្ត្រីភាពមួយរូបដើរចេញពីផ្ទះលក់ថ្នាំចិនក្បែរនោះ បំរុងហៅស៊ីក្លូឡើងជិះ ។

-យី ! អ្នកណាឥចេះ ? រាងដូចអូន មណី !

សត្យា ឧទានតិច១ចេញមក រួចហើយអ្នកក៏រត់កាត់ផ្លូវទៅរកស្ត្រី ដែលអ្នកសង្ស័យថាជាមណីមួយរំពេច ។

លុះដល់ទៅជិត សត្យាក៏ស្គាល់ជាក់ជាមណី ប្រពន្ធសម្លាញ់ ដែលគេខំស្វែងរកអស់ពេលរាប់ឆ្នាំនោះឯង។

-អូនមណី ! អូនមណី !

មណី ភ្ញាក់ព្រើតបែរខ្នាប់មករកម្ចាស់សម្លេង។

-យី ! បងសត្យា ! បងសត្យា !

-អូនមណី ! អូនមណីនៅរស់មិនទាន់ស្លាប់ទេឬ ?

យុវស្វាមីភរិយាឥតខាន់ស្លា ស្ទុះប្រវាឱបគ្នាយំទង្គិះខ្សឹកខ្សួលអួលអាក់ ប្រាសចាកការអៀនខ្មាស។ គ្មានពេលណាធ្វើឱ្យគេទាំងពីរនាក់ រំជួលចិត្តដូចជាពេលនេះទេ គេឱបគេរិតដូចមនុស្សស្លាប់បាត់ទៅហើយ បានចាប់កំណើតកើតម្តងទៀត។

មណី បានចាប់រ៉ាយរាប់និយាយរឿងដ៏សែនកំសត់ខ្លោចផ្សាក្នុង ជីវិតរបស់នាងប្រាប់ទៅសត្យាប្តីសម្លាញ់តាំងពីដើមដល់ចប់។ ទីបំផុតនាងក៏និយាយថា :

-បងសត្យា (មណីលាដៃពីចង្កេះប្រុសស្នេហ៍ បែរមើលមុខដោយកែវភ្នែកសោកសៅ) ក្តីស្នេហ៍យើងជាតិនេះគ្រាន់តែជាឆាកល្ខោនដ៏សែនកំសត់របស់នារីរងកម្មម្នាក់ប៉ុណ្ណោះទេបង....! បងរៀបការជាមួយនាង ផល្លីនយូរហើយឬ ?

សត្យាគ្រវីក្បាល :

-ផល្លីនគេរៀបការហើយ តែគេមិនមែនការជាមួយបងទេ ស្ត្រីដែលត្រូវរៀបការជាមួយបង គឺរូបអូននេះឯង បងខំដើររកអូនអស់ពេលជាងមួយឆ្នាំស្ទើរក្រឡាប់ព្រះធរណី បងត្រូវម៉ាក់កាត់កាលបណ្តេញចុះចេញពីលើផ្ទះចាស់ តាំងពីបងត្រឡប់មកពីបរទេសក្រោយបានដឹងថាអូន ចាកចេញពីផ្ទះចាស់ ឥឡូវជួបហើយបងមិនឱ្យអូនព្រាត់ទៅទៀតទេ យើងប្តូរស្លាប់ប្តូររស់ជាមួយគ្នាចាប់តាំងពីពេលនេះទៅណាអូនណ៎ា ! អូនមណី ! កូនយើងយ៉ាងម៉េចទៅហើយ ?

-ចាស ... ! កូនយើងនៅមានជីវិតរស់នៅ វាជាកូនប្រុសដែល មានមុខមាត់កាត់មករកបងគ្មានខុស !

-ឱ ! កូនយើងនៅរស់ ! (សត្យានិយាយចេញមកខ្លាំង១ដោយ សេចក្តីត្រេកអរ) កូនយើងនៅរស់ ! អូនមណី ! បងសប្បាយចិត្តណាស់ !

យុវស្វាមី ប្រវាឱបចង្កេះភរិយា ដោយសេចក្តីសោមនស្សម្តងទៀត ។

អ្នកត្រាច់ចរទៅមកតាមដងវិថី នាំគ្នាងាកបែរមើលអ្នកទាំងពីរ នឹកសង្ស័យ។ មណីឃើញហេតុការណ៍មិនស្រួលដូច្នោះ នាងក៏ចាប់ទាញដៃ ប្រុសសម្លាញ់ចេញនិយាយថា :

-យើងឈរនៅកន្លែងនេះយូរ មិនគាប់ភ្នែកអ្នកដទៃទេបង ....

-បើឥចឹងបងនឹងនាំអូនទៅអង្គុយនិយាយគ្នានៅជើងម៉ាថ្ម មុខ សាលាក្រុងស្រួលទេអូន ?

-ចាំះ ! ស្រេចចិត្តបង ...!

មណី ឆ្លើយយ៉ាងរហ័សមិនចាំបាច់គំនិត ។

បន្ទាប់មកសត្យានិងមណី ក៏បានប្រាកដខ្លួនទាំងពីរប្រាណនៅលើ ជើងម៉ាថ្មកណ្តាលសួនបុប្ផាមុខសាលាក្រុង ។

-អូនមណី !

-ចាំះ ! បង ...!

-ចាប់តាំងពីថ្ងៃនេះទៅ អូនត្រូវនៅរស់ជាមួយបងលុះត្រាអវសាន្តជីវិត ឆាកល្ខោនកំសត់របស់យើងល្មមបញ្ចប់ត្រឹមហ្នឹងហើយ ចំពោះកំហុសម្តាយបង ដែលលោកបានធ្វើបាបធ្វើកម្មលើរូបអូនច្រើនលើកច្រើនគ្រា សូមអូនអភ័យទោសឱ្យលោកផងណាអូនណ៎ា....!

បានស្តាប់ពាក្យអង្វរលួងលោមប្រកបដោយមធុរវាចារបស់ប្រុសស្នេហ៍ ធ្វើឱ្យមណីនារីកំសត់ នឹកអាណិតប្តីរកទប់ទឹកភ្នែកអភ័ព្វពុំបាន ។

-អូនពុំដែលមានចិត្តនឹកខឹងបង ឬលោកអុំប្រុស លោកអុំស្រី ម្តងណាឡើយ ( មណីនិយាយទៅកាន់សត្យាដោយខ្សែភ្នែកសំដែងសេចក្តីស្វាមីភ័ក្តិ) គ្រប់យ៉ាងដែលលោកអុំស្រីធ្វើទៅក៏ដើម្បីសេចក្តីសុខរបស់កូន លោកតែម៉្យាងប៉ុណ្ណោះ.... នៅក្នុងលោកនេះ បើគ្មានបង ... ជាអ្នកចងក្រង ខ្សែវាសនាឱ្យអូន អូនមិនអាចរស់នៅបានទេ... តែបងអើយ ...

មណី វាចាបានតែត្រឹមនេះ ទឹកភ្នែកកម្មក៏ហូរជ្រៀតជ្រែកមក បង្អាក់សំដីនាងឱ្យនៅស្ងៀមស្ងាត់បាត់សម្លេងទៅវិញ ។

សត្យា យកដៃទៅជូតទឹកភ្នែកមណី ដែលហូរមកជាប់នឹងថ្ពាល់ ស្រាល១ព្រមទាំងសួរទៅនាងជាបន្ទាន់ថា :

-តែអ្វីទៅអូន ? អូនខ្លាចបងបោះបង់បណ្តោយឱ្យម៉ាក់គាត់តាម មកឆានៅធ្វើបាបអូនដូចជាពេលមុន១ទៀតឬ ?

-មិនដូច្នោះទេបងអើយ ! តែអូនមិនចង់ឃើញបងវេទនាត្រូវ ម្តាយកាត់កាលចេញពីមតិកដោយសារតែនារីរងកម្មម្នាក់ ដែលមានឋានៈ ត្រឹមទាសីបំរើក្នុងផ្ទះ ....!

សត្យា ប្រញាប់យកដៃខ្ទប់មាត់មណីមិនឱ្យបន្តប្រយោគទៅទៀត ។ នរៈនិយាយអួល១ថា :

-ឈប់យកពាក្យស្លែងនេះ មកនិយាយទៀតទៅអូនមណី....! បងបាននិយាយប្រាប់អូនជាច្រើនលើកច្រើនគ្រាហើយតើ ថាសេចក្តីស្នេហាពិត១នោះមិនមែនកើតឡើងដោយសារមាសប្រាក់ យសសក្តិវណ្ណៈអ្វីទាំងអស់ ស្នេហ៍ពិតគឺស្ថិតនៅត្រង់ចិត្តយើងស្មោះស្ម័គ្រនឹងគ្នាណាអូន ? តម្លៃ ស្នេហាពិតប្រាកដ ទោះជាយកប្រាក់រាប់រយកោដិឃ្លាំងមកទិញក៏ទិញមិនបានដែរ ...!

មណី ខំប្រឹងញញឹមទាំងទឹកភ្នែក វិមានស្នេហ៍ដែលត្រូវព្យុះកម្មបោកបក់ម្តងរួចទៅហើយ ឥឡូវនេះត្រឡប់ជាមានរស្មីចិញ្ចែងភ្លឺថ្លាឡើងវិញ ។ នាងចាប់កដៃប្តីច្របាច់ស្រាល១ហើយឆ្លើយតបថា :

-ពីថ្ងៃនេះទៅ អូនសុខចិត្តរួមរស់ជាមួយបងលុះត្រាអវសាននៃជីវិត យើងល្មមទៅរកមើលកូនហើយណាបង ម៉ែ្លះសមពូមីងគាត់ចាំមើលផ្លូវអូន ។

-យីបងរវល់តែសប្បាយចិត្តពេក ភ្លេចគិតដល់កូនយើងសូន្យ ឈឹងទៅអូន ! បងចង់ឃើញណាស់ !

មណី កាន់ដៃប្តីដើរកាត់វិថីឧកញ្ញាផ្លុង រួចហើយនាងក៏ហៅ ទៅឃីញូ មួយជិះឆ្ពោះទៅកាន់ផ្ទះពូនុំមីងយ៉ានទឹកល្អក់ ។

ប៉ុន្មានថ្ងៃក្រោយមក លោកស្រីសេដ្ឋាក៏ទទួលអនិច្ចកម្មដោយ រោគពិការបេះដូងនៅក្នុងមន្ទីរពេទ្យព្រះកេតុមាលា ។ លោក ឌុច-ស៊ីផាន់ ក្រោយពីបាត់បង់ជីវិតភរិយាកំណាចមក លោកក៏បានស៊ើបសួរ រកសត្យា និងមណីទាល់តែបានជួប ហើយលោកក៏នាំអ្នកទាំងពីរឱ្យមកនៅផ្ទះជាមួយ លោកជាសុខសាន្តរៀបរហូតទៅ ។

-ចប់បរិបូណ៌-

អ្នកនិពន្ធ

**ហាក់ នៃហុក**

## នៅក្នុងលោកនេះបើគ្មានបង

| | | | |
|---|---|---|---|
| បទភ្លេង | ស៊ិន ស៊ីសាមុត | ច្រៀងដោយ | កែវ សេដ្ឋា |
| ទំនុកច្រៀង | ស្វាយ សំអឿ | | |

១-នៅលើក្នុងលោកនេះបើគ្មានរូបបង ជាអ្នកចងក្រងវាសនាឱ្យ ខ្ញុំ ប្រហែលជាស្រីត្រូវកម្មលោកកិយបង្វំ ចាកក្ដីសុខុមទ្រទំចិន្ដា ។

២-រស្មីជីវិតអូនបានភ្លឺស្វាងនេះ គឺភស្ដុតាងចិត្តបងមេត្តា អូន សន្យាំទុកសាងជាសំបុកគ្រួសារ ប្រចាំសង្ខារទុកជាកោះត្រើយ ។

បន្ទរ : អូនសូមសច្ចា ជាថ្មី ណាថ្លៃ បងអើយថាចិត្តអូនស្មោះៗ ឥតកន្ដើយ ជាគ្រាបង្ហើយនៃខ្សែវាសនា

៣-នៅក្នុងលោកនេះបើគ្មានប្រុសថ្លៃ ក៏រស់ខ្វះន័យសម្រាប់ លោកា ស្លាប់ទៅជាជាងគ្រាន់បានលប់លាងទុក្ខា ផុតពាក្យនិន្ទាពីជនប្រុស ស្រី ។ ... នៅក្នុងលោកនេះបើខ្វះរូបបង ....!